សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការអនុវត្តមូលទោស

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **មាស យ៉ាស៊ីន**
**ម៉ាត់ វិសុទ្ធ**

សាស្ត្រាចារ្យណែនាំ
លោក **ម៉ម ចាន់ណែត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **មាស យ៉ាស៊ីន** និងឈ្មោះ **ម៉ាត់ វិសុទ្ធ** ជានិស្សិតជំនាន់ទី២០ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមថ្លែងអំណរគុណ និងសំដែងនូវកតញ្ញូតាធម៌ចំពោះ៖

-លោកឪពុក **មាស វ៉ារី** និងអ្នកម្តាយ **តាំង សុធារី**

-លោកឪពុក **សាស ឡុង** និងអ្នកម្តាយ **យស់ ចាន់ធូ**

កូនៗសូមលំអោនកាយសំដែងនូវការគោរព និងសំដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះលោកអ្នកមានគុណទាំងពីររបស់កូន។ ទន្ទឹមនឹងនេះកូនៗសូមថ្លែងអំណរគុណដល់អ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើតដល់រូបកូន ព្រមទាំងខិតខំពុះពារនូវគ្រប់ឧបសគ្គ ដើម្បីចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានព្រានប្រដៅតាំងពីតូចរហូតដល់ធំ ព្រមទាំងបានលះបង់នូវកម្លាំងកាយ កម្លាំងចិត្ត ផ្តល់ថវិការដើម្បីផ្គត់ផ្គង់ការសិក្សារបស់កូន ជួយផ្តល់កម្លាំងចិត្ត និងជួយទំនុកបំរុងទាំងសម្ភារៈដល់កូនតាំងពីតូចរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រទទួលបានលទ្ធផលដ៏គាប់ចិត្ត។ កូនៗសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះគុណនូបការៈយ៉ាងធំធេងបំផុតរបស់អ្នកទាំងពីរ។ គុណនូបការៈរបស់លោកទាំងពីរ គឺពិតជាធំធេងដែលធ្វើឱ្យកូនៗបំភ្លេចមិនបាននឹងស្ថិតក្នុងចិត្តរបស់កូនៗជារៀងដរាបគ្មានថ្ងៃសូន្យឡើយ។

សូមថ្លែងអំណរគុណដល់ឯកឧត្តមសកលវិទ្យាធិការ **លុយ ចណ្ណា** ព្រមទាំងព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ព្រមទាំងលោកគ្រូ អ្នកគ្រូទាំងអស់ដែលបានជួយបង្ហាត់បង្រៀនឱ្យយើងខ្ញុំទទួលបានចំណេះដឹង ដែលជាប្រទីបបំភ្លឺផ្លូវសំរាប់ជីវិតយើងខ្ញុំរហូតមានដល់ថ្ងៃនេះ។

សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យ **ម៉ម ចាន់ណៃត** ដែលជាសាស្ត្រាចារ្យណែនាំដល់យើងខ្ញុំក្នុងការរៀបចំឯកសារសារណាលើប្រធានបទ **នីតិវិធីនៃការអនុវត្តមូលទោស** ដោយទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កា ដោយលោកបានចំណាយនូវពេលវេលាដ៏មានតម្លៃ ដើម្បីជួយប្រឹក្សា និងផ្តល់អនុសាស្ត្រល្អៗដើម្បីឱ្យឯកសារសារណានេះកាន់តែល្អ និងកាន់តែរលូន។

ជាចុងបញ្ចប់ ខ្ញុំបាទទាំងពីរនាក់សូមបួងសួងដល់វត្ថុស័ក្តសិទ្ធទាំងអស់ដែលមានក្នុងលោកនេះជួយតាមថែរក្សា លោកអ្នកមានគុណ ឯកឧត្តម សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់អោយជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ប្រទេសកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូររបបនយោបាយជាច្រើនលើកច្រើនសារ ដោយក្នុងរយៈកាលត្រឹមតែពាក់កណ្តាលសតវត្សទី២០ ពោលគឺក្រោយពីសម័យសង្គមរាស្ត្រនិយមមក ប្រទេសកម្ពុជាបានបាត់បង់នូវឥទ្ធិពល និងស្ថេរភាពរបស់ខ្លួន ជាពិសេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរលំក្នុងឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសត្រូវបានបង្កើតឡើងដោយរៀបចំឱ្យមានអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា និងក្រុមប្រឹក្សាជាតិជាន់ខ្ពស់។ យោងតាមសេចក្តីសម្រេចចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ បានអនុម័តបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងរយៈពេលអន្តរកាល ដើម្បីបំពេញតម្រូវការការខ្វះខាតក្នុងធានាឱ្យបាននូវរបៀបរៀបរយសណ្តាប់ធ្នាប់សង្គម និងការការពារសិទ្ធិមនុស្ស។ ប្រទេសកម្ពុជាបានស្តារឡើងវិញនូវស្ថេរភាពនយោបាយ ព្រមទាំងការអភិវឌ្ឍរហូតមកដល់សព្វថ្ងៃ ដោយបាននិងកំពុងធ្វើកំណែទម្រង់លើវិស័យជាច្រើន ជាពិសេសវិស័យច្បាប់។ ក្រមព្រហ្មទណ្ឌថ្មី គឺជាសមិទ្ធផលដ៏ល្អមួយដែលត្រូវប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលបានកែសម្រួលឱ្យកាន់តែល្អប្រសើរជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ក្រមព្រហ្មទណ្ឌថ្មីនេះមានលក្ខណៈគោរពសិទ្ធិ និងអនុគ្រោះច្រើនដល់ជនល្មើសដើម្បីធ្វើយ៉ាងណាកែប្រែជនល្មើស និងធ្វើសមាហរណកម្មជនល្មើសឱ្យចូលទៅរួមរស់ក្នុងសង្គមវិញ ជាពិសេសគឺបែបបទនៃការអនុវត្តទោស។ បទល្មើសនីមួយៗ គឺមានធាតុផ្សំខុសៗគ្នាតែយើងអាចទាញបានធាតុផ្សំរួមដូចជា ធាតុនីត្យានុកូលធាតុសត្យានុម័ត និងធាតុអត្តនោម័ត។ នៅពេលដែលមានបទល្មើសមួយបានកើតឡើង មុននឹងឈានដល់ការជំនុំជម្រះ គឺទាមទារឱ្យបំពេញនីតិវិធីជាច្រើនដូចជា ការស៊ើបអង្កេត ការចោទប្រកាន់ និងការស៊ើបសួរជាដើម ដើម្បីស្វែងរកការពិតនៃរឿង និងចេញសេចក្តីសម្រេច។ នៅពេលមានការសម្រេចសេចក្តី ទោសអាចត្រូវបានអនុវត្ត ឬមិនត្រូវបានអនុវត្តដែលអាស្រ័យលើការប្រកាសទោសរបស់តុលាការលើស្ថានភាពនៃបទល្មើសនីមួយៗ។ ទោសព្រហ្មទណ្ឌដែលអាចត្រូវយកមាន៣ គឺមូលទោស ទោសបន្ថែម និងទោសជំនួស។

ចំពោះក្រុមយើងខ្ញុំ គឺជ្រើសរើសប្រធានបទស្តីពី **នីតិវិធីនៃការអនុវត្តមូលទោស** មកធ្វើការ បកស្រាយ គឺដើម្បីស្វែងយល់ពីភាពស៊ីជម្រៅអំពីគោលការណ៍ក្នុងការអនុវត្តនូវមូលទោស ទាំងទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់។ ក្រុមយើងខ្ញុំសូមកម្រិតយកត្រឹមមូលទោសមកធ្វើការបកស្រាយតែប៉ុណ្ណោះ។ ក្រុមយើងខ្ញុំមានសេចក្តីសោមនស្សណាស់ដោយទទួលបានការណែនាំពីសាស្ត្រាចារ្យ **ម៉ម ចាន់ណែត** លើការសិក្សាស្រាវជ្រាវលើប្រធានបទនេះ។ ក្រុមយើងខ្ញុំសង្ឃឹមថា មិត្តអ្នកអាន និងនិស្សិតជំនាន់ក្រោយអាចយកសារណានេះទុកជាឯកសារ និងសិក្សាបន្ថែម។ ទន្ទឹមនឹងនេះយើងខ្ញុំសង្ឃឹមថានឹងមានការយោគយល់ពីមិត្តអ្នកអាននូវចំណុចខ្វះខាត ខុសឆ្គងលើពាក្យពេចន៍ និងខ្លឹមសារក្នុងសារណានេះ។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម** ............ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១

២. ចំណោទបញ្ហា ............ ២

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ............ ៣

៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ............ ៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ............ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៤

**ជំពូកទី១**

**សញ្ញាណទូទៅនៃទោស**

១.១ និយមន័យ ............ ៥

១.១.១. និយមន័យនៃទោសព្រហ្មទណ្ឌ ............ ៥

១.១.២. និយមន័យនៃមូលទោស ............ ៧

១.២ ប្រភេទនៃទោស ............ ៧

១.២.១. មូលទោស ............ ៧

១. ២.១.១. ទោសពន្ធនាគារ ............ ៧

១.២.១.២. ទោសពិន័យជាប្រាក់ ............ ៨

១.២.២. ទោសបន្ថែម (អនុទោស) ............ ៨

១. ២.៣. ទោសជំនួស ............ ១០

១.២.៣.១. ទោសការងារសហគមន៍ ............ ១០

១.២.៣.២. ការស្ដីបន្ទោស ............ ១១

១. ៣ មុខងារនៃការដាក់ទោស ............ ១១

១.៣.១. ការបង្ការទុកជាមុន ............ ១១
១.៣.២. ការបង្ក្រាបបទល្មើស ............ ១២
១.៣.៣. ការអប់រំកែប្រែ ............ ១២
១.៤ ចរិកលក្ខណៈនៃទោស ............ ១៣
១.៤.១. គោលការណ៍នីត្យានុកូលភាព ............ ១៣
១.៤.២. គោលការណ៍ឯកត្តកម្មនៃទោស ............ ១៤
១.៤.៣. ចរិតលក្ខណៈសមភាព ............ ១៥
១.៤.៤. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ............ ១៥

## ជំពូកទី២
## បែបបទនៃការអនុវត្តមូលទោស

២.១ ការអនុវត្តមូលទោសចំពោះរូបវន្តបុគ្គល ............ ១៧
២.១.១ ការអនុវត្តមូលទោសចំពោះនីតិជន ............ ១៨
២.១.២ ការអនុវត្តមូលទោសចំពោះអនីតិជន ............ ១៨
២.១.២.១ អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ ............ ១៩
២.១.២.២ អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ និងក្រោមអាយុ១៨ឆ្នាំ ............ ១៩
២.២ ការអនុវត្តមូលទោសចំពោះនីតិបុគ្គល ............ ២១
២.២.១. និយមន័យនីតិបុគ្គល ............ ២១
២.២.២. ប្រភេទនៃមូលទោសដែលអនុវត្តចំពោះនីតិបុគ្គល ............ ២២
២.២.៣ ការអនុវត្តមូលទោសចំពោះនីតិបុគ្គលជារដ្ឋ ............ ២២
២.២.៤. ការអនុវត្តមូលទោសចំពោះនីតិបុគ្គលឯកជន ............ ២៣

## ជំពូកទី៣
## វិធាននៃការអនុវត្តទោស និងមូលហេតុគតិយុត្តផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស

៣.១. វិធាននៃការអនុវត្តទោសដែលនាំឱ្យមានការប៉ះពាលដល់ការអនុវត្តមូលទោស ............ ២៥
៣.១.១. ការព្យួរទោស ............ ២៥

៣.១.១.១ ការព្យួរទោសធម្មតា ........ ២៥
ក.លក្ខខណ្ឌទាក់ទងនឹងប្រវត្តិនៃការផ្តន្ទាទោសរបស់ជនជាប់ចោទ ........ ២៧
ខ. អានុភាពនៃការព្យួរទោសធម្មតា ........ ២៧
៣.១.១.២. ការព្យួរទោសសាកល្បង ........ ២៩
ក.លក្ខខណ្ឌនៃការព្យួរទោសសាកល្បង ........ ៣០
ខ. វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែករបស់ទណ្ឌិត ........ ៣១
គ.ការដកហូតការព្យួរទោសសាកល្បង ........ ៣២
៣.១.២. ការផ្អាកការប្រកាសទោស ........ ៣២
៣.១.៣ ទោសពាក់កណ្តាលសេរីភាព ........ ៣៣
៣.១.៤. ការបែងចែកទោសជាប្រភាគ ........ ៣៤
៣.២. មូលហេតុគតិយុត្តផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស ........ ៣៥
៣.២.១. អាជ្ញាយុកាលនៃទោស ........ ៣៦
៣.២.១.១. ដែនអនុវត្តអាជ្ញាយុកាលនៃទោស ........ ៣៦
៣.២.១.២. រយៈពេលជ្ញាយុកាលនៃទោស ........ ៣៦
៣.២.២. ការអនុគ្រោះទោស ........ ៣៧
៣.២.២.១. លក្ខខណ្ឌនៃការអនុគ្រោះទោស ........ ៣៧
ក. លក្ខខណ្ឌទាក់ទិននឹងកិរិយាមារយាទរបស់ទណ្ឌិត ........ ៣៨
ខ. លក្ខខណ្ឌទាក់ទិននឹងរយៈពេលនៃការទទួលរងទោស ........ ៣៨
៣.២.២.២. នីតិវិធីនៃការអនុគ្រោះទោស ........ ៣៩
៣.២.៣ ការលើកលែងទោសជាទូទៅ ........ ៤០
៣.២.៣.១. ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ........ ៤០
៣.២.៣.២. អានុភាពនៃការលើកលែងទោសជាទូទៅ ........ ៤១
៣.២.៤ មរណភាពរបស់ជនជាប់ទោស ........ ៤១
៣.២.៥ មូលហេតុផ្សេងទៀតនៃការរំលត់បណ្តឹងអាជ្ញា ........ ៤២

៣.២.៥.១. ការសម្របសម្រួលជាមួយរដ្ឋ ..................... ៤២

៣.២.៥.២. ការដកពាក្យប្តឹង ..................... ៤២

## ជំពូកទី៤
## នីតិវិធីនៃការអនុវត្តសេចក្តីសម្រេចតុលាការពាក់ព័ន្ធនឹងមូលទោស

៤.១. ការអនុវត្តសេចក្តីសម្រេចតុលាការ ..................... ៤៤

៤.១.១. ការអនុវត្តទោសពន្ធនាគារ ..................... ៤៤

៤.១.១.១ ការអនុវត្តទោសចំពោះបុគ្គលជាប់ឃុំ ..................... ៤៥

៤.១.១.២ ការអនុវត្តទោសចំពោះបុគ្គលក្រៅឃុំ ..................... ៤៦

៤.១.២. ការអនុវត្តទោសពិន័យ ..................... ៤៦

៤.១.២.១. ការដាស់តឿនឱ្យបង់ប្រាក់ពិន័យ ..................... ៤៦

៤.១.២.២. ការបង្ខំដល់រូបកាយ ..................... ៤៧

៤.២. ការអនុវត្តសេចក្តីសម្រេចតុលាការដោយអាជ្ញាធរមានសមត្ថកិច្ច ..................... ៤៩

៤.២.១. អយ្យការ ..................... ៤៩

៤.២.២. កងកម្លាំងសាធារណៈ ..................... ៥០

៤.២.៣. អាជ្ញាសាលា ..................... ៥០

៤.២.៤. ក្រសួងយុត្តិធម៌ ..................... ៥១

**សេចក្តីសន្និដ្ឋាន** ..................... ៥៣

**អនុសាសន៍** ..................... ៥៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសប្រកាន់នូវលទ្ធិប្រជាធិបតេយ្យ ដោយមានបែងចែកនូវអំណាចនៃស្ថាប័នដឹកនាំរដ្ឋដាច់ដោយឡែកពីគ្នា គឺអង្គនីតិបញ្ញត្តិ អង្គនីតិប្រតិបត្តិ និងតុលាការ។ យោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងយ៉ាងច្បាស់ អំណាចតុលាការគ្រប់គ្រងទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។ នេះសបញ្ជាក់ឱ្យឃើញថា មានតែអំណាចតុលាការមួយគត់ ដែលមាននូវសិទ្ធិអំណាចនៅក្នុងការសម្រេចសេចក្តីពាក់ព័ន្ធជាមួយនឹងវិវាទដែលកើតមានឡើង ដែលមានស្ថាប័ននេះតែប៉ុណ្ណោះដែលមានសិទ្ធិអំណាចនៅក្នុងការជម្រះក្តីដោយយុត្តិធម៌ ត្រូវធ្វើឡើងក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីច្បាប់ ហើយមានតែចៅក្រមទេ ដែលមានសិទ្ធិនៅក្នុងការជម្រះក្តីដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ អស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ នៅក្នុងចំណោមអំណាចតុលាការ គឺមាននូវមុខងារផ្សេងៗទៀតដែលស្របទៅតាមផ្នែកនីមួយៗ ជាក់ស្តែងដូចជាតុលាការរដ្ឋបាល តុលាការការងារ តុលាការពាណិជ្ជកម្ម តុលាការរដ្ឋប្បវេណី តុលាការព្រហ្មទណ្ឌ ជាអាទិ៍។ល។

ជាគោលការណ៍តុលាការព្រហ្មទណ្ឌ គឺទទួលបន្ទុកនៅក្នុងការដោះស្រាយបញ្ហាដែលមានការពាក់ព័ន្ធតែទៅលើរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ ដែលបញ្ហាព្រហ្មទណ្ឌពិតជាមានលក្ខណៈពិសេសណាស់ ពោលគឺមាននូវទំនាក់ទំនងដែលឈានទៅដល់ការសម្រេច នៃជោគវាសនារបស់មនុស្សក្នុងការទទួលនូវទណ្ឌកម្មព្រហ្មទណ្ឌណាមួយដែលពាក់ព័ន្ធជាមួយការជាប់ពន្ធនាគារ ឬការពិន័យជាប្រាក់ជាដើម។

ហេតុដូច្នេះ ក្រមព្រហ្មទណ្ឌថ្មីមានលក្ខណៈគោរពសិទ្ធិ និងអនុគ្រោះច្រើនដល់ចារី ដើម្បីធ្វើយ៉ាងណាកែប្រែចារី និងធ្វើសមាហរណកម្មចារីឱ្យចូលទៅរួមរស់ក្នុងសង្គមវិញ ជាពិសេសគឺនីតិវិធីនៃការអនុវត្តទោស។ បទល្មើសនីមួយៗ គឺមានធាតុផ្សំខុសៗគ្នាតែយើងអាចទាញបានធាតុផ្សំរួមដូចជា ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។ នៅពេលដែលមានបទល្មើសមួយបានកើតឡើង មុននឹងឈានដល់ការជំនុំជម្រះ គឺទាមទារឱ្យបំពេញនីតិវិធីជាច្រើនដូចជា ការស៊ើបអង្កេត ការចោទប្រកាន់ និងការស៊ើបសួរជាដើម ដើម្បីស្វែងរកការពិតនៃរឿង និងចេញសេចក្តីសម្រេច។ នៅពេលមានការសម្រេចសេចក្តី ទោសអាចត្រូវបានអនុវត្ត ឬមិនត្រូវបានអនុវត្តដែលអាស្រ័យលើការប្រកាសទោសរបស់តុលាការលើស្ថានភាពនៃបទល្មើសនីមួយៗ។ ទោសព្រហ្មទណ្ឌដែលអាចត្រូវយកមាន៣ គឺមូលទោស ទោសបន្ថែម និងទោសជំនួស។ ទន្ទឹមនឹងនេះ ការប្រកាសឱ្យអនុវត្តទោស មិនមែនគ្រាន់តែជាការដាក់បង្ខំបង្ខាំងលើរូបកាយតែប៉ុណ្ណោះទេ តែជាការផ្តល់ឱកាសអប់រំកែប្រែឱ្យចារីធ្វើសមាហរណកម្មចូលក្នុងសង្គមវិញ។

## ២. ចំណោទបញ្ហា

ដោយសារតែការទោសព្រហ្មទណ្ឌមានសារៈសំខាន់ចំពោះចារី ទាំងឡាយណាដែលមានពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ដែលត្រូវបានចោទប្រកាន់ ហើយឈានដល់ការសម្រេចសេចក្តីដោយតុលាការព្រហ្មទណ្ឌនូវទណ្ឌកម្មណាមួយចំពោះពិរុទ្ធជន។ ហេតុនេះហើយ ទណ្ឌកម្មព្រហ្មទណ្ឌ អាចនាំឱ្យមាននូវទោសទណ្ឌចំពោះអ្នកដែលបានប្រព្រឹត្តខុសទៅនឹងអ្វីដែលបានប្បញ្ញត្តិយ៉ាងជាក់លាក់ដោយច្បាប់ព្រហ្មទណ្ឌ ទាំងនេះហើយទើបរាល់ការសម្រេចរបស់តុលាការ គឺមានលក្ខណៈដាច់ខាត នៅក្នុងការប្រកាសឱ្យជនណាម្នាក់ទទួលនូវទោសទណ្ឌ ហើយមានតែតុលាការព្រហ្មទណ្ឌតែមួយគត់ ដែលជាអ្នកមាននូវសិទ្ធិអំណាច នៅក្នុងការសម្រេចសេចក្តីចំពោះជនល្មើសដោយផ្ទាល់ គ្មានតុលាការណាមានសមត្ថកិច្ចនៅក្នុងការសម្រេចចំពោះជនដែលបានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌដូចតុលាការព្រហ្មនេះទេ។ ទាំងនេះវាបញ្ជាក់ឱ្យកាន់តែច្បាស់ថា តុលាការព្រហ្មទណ្ឌពិតជាមានសិទ្ធិផ្តាច់មុខសម្រាប់ជនណាម្នាក់ដែលបានប្រព្រឹត្តខុសទៅនឹង អ្វីដែលបានចែងដោយច្បាប់ ឱ្យធ្វើការទទួលខុសត្រូវទៅលើអំពើរបស់ខ្លួន តាមបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌដែលបានចែងយ៉ាងជាក់លាក់។

ហេតុនេះ នៅក្នុងសារណានេះ យើងខ្ញុំលើកយកប្រធានបទអំពី នីតិវិធីនៃការអនុវត្តមូលទោស មកសរសេរ គឺដើម្បីចង់បង្ហាញឱ្យដល់អ្នកអាន ដូចជានិស្សិតជំនាន់ក្រោយៗទៀត ឱ្យយល់ដឹងថា អ្វីទៅជាមូលទោស? ការអនុវត្តមូលទោសត្រូវអនុវត្តយ៉ាងដូចម្តេចចំពោះបុគ្គល? វិធាន និងមូលហេតុអ្វីខ្លះដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស? ហើយនីតិវិធីនៃការអនុវត្តសេចក្តីសម្រេចតុលាការពាក់ព័ន្ធនឹងមូលទោសត្រូវអនុវត្តយ៉ាងដូចម្តេច?

ដោយហេតុថា មានតែតុលាការព្រហ្មទណ្ឌតែប៉ុណ្ណោះជាអ្នកមានសិទ្ធិស្វ័យសម្រេចនូវ ទោសទណ្ឌចំពោះជនល្មើស ដែលបានប្រព្រឹត្តនូវអំពើណាមួយដែលប្បញ្ញត្តិយ៉ាងជាក់លាក់ក្នុងច្បាប់ព្រហ្មទណ្ឌ។ នៅក្នុងការសម្រេចសេចក្តី អំពីជនណាម្នាក់ដែលត្រូវទទួលទោសប្រភេទណាមួយនោះ គឺមាននូវស្ថានភាពជាច្រើនដែលត្រូវបានតុលាការធ្វើការពិចារណា ពោលគឺដូចជា ស្ថានភាពគ្រួសារ ពេលវេលា ទីកន្លែង ស្ថានភាពហិរញ្ញវត្ថុ ការចេះដឹង ការប្រព្រឹត្តបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនល្មើសនៅមុន និងក្រោយពេលប្រព្រឹត្តបទល្មើសជាដើម។ ដោយសារតែស្ថានភាពទាំងឡាយនេះហើយអាចជាជម្រើសមួយ ដែលជាការធ្វើឱ្យចៅក្រមធ្វើការពិចារណាទៅលើការវិនិច្ឆ័យសេចក្តីដូចជាការផ្តន្ទាទោស ឬប្រើប្រាស់នូវយន្តការផ្សេងៗដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌទៅលើទណ្ឌិត។

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវ និងការរៀបចំតាក់តែងនូវឯកសារដែលជាសារណានេះឡើង គឺនៅក្នុងគោលបំណងសិក្សាស្រាវជ្រាវ ដូចដែលបានលើកឡើងពីខាងលើស្រាប់ ដើម្បីធ្វើការពង្រីកនូវសមត្ថភាពបន្ថែមចំពោះចំណេះដឹងផ្ទាល់ខ្លួនផង និងក៏ជាទុនមួយសម្រាប់ទុកឯកសារដល់និស្សិតជំនាន់ក្រោយៗទៀត ធ្វើការស្វែងយល់ និងជាចំណេះដឹងមួយផ្នែកនៅក្នុងការស្រាវជ្រាវ ឱ្យមានការយល់ដឹងនូវ អ្វីទៅដែលជាទោសព្រហ្មទណ្ឌ ឬមូលទោស? បុគ្គលណាខ្លះដែលត្រូវអនុវត្តទោស? លើសពីនេះទៅទៀត អ្នកសិក្សាក៏អាចស្វែងយល់ផងដែរនូវសេចក្តីសម្រេចរបស់តុលាការត្រូវអនុវត្តបែបណាចំពោះទណ្ឌិតដែលមានបញ្ញត្តនៅក្នុងច្បាប់ជាធរមាន។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងនៅក្នុងចំណោទបញ្ហាខាងលើ យើងខ្ញុំខិតខំធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារជាមូលដ្ឋាន គឺក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមនីតិវិធីក្រមព្រហ្មទណ្ឌ២០០៧ និងឯកសារពាក់ព័ន្ធទាំងឡាយដែលបានលើកឡើងនៅក្នុងឯកសារពិគ្រោះស្រាប់ ដើម្បីសរសេរនូវសារណានេះឡើងដែលមានចំនួន០៤ ជំពូក។

នៅក្នុងការសរសេរសារណានេះ គឺយើងខ្ញុំសរសេរតែអំពីភាពពាក់ព័ន្ធទាំងឡាយណាដែលទាក់ទងជាមួយទៅនឹងមូលទោស ដែលជាផ្នែកមួយនៃទោសព្រហ្មទណ្ឌ។ បន្ថែមពីនេះយើងខ្ញុំក៏បានលើកឡើងនូវយន្តការរបស់តុលាការក្នុងនីតិវិធីនៃការអនុវត្តមូលទោសដោយផ្អែកទៅលើការអនុសេចក្តីសម្រេចរបស់តុលាការ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសរសេរសារណានេះ យើងខ្ញុំធ្វើការសិក្សាបែបពណ៌ា និងវិភាគ។ ការសិក្សាស្រាវជ្រាវបានធ្វើឡើងតាមរយៈការអនុវត្តវិធីសាស្ត្រស្រាវជ្រាវដូចខាងក្រោម៖

វិធីសាស្ត្រប្រមូលឯកសារ គឺបានប្រមូលនៅបណ្ណាល័យនីតិសាស្ត្ររបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគេហទំព័របណ្ណាល័យនីតិសាស្ត្ររបស់សាកលវិទ្យាល័យ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ព្រមទាំងការប្រមូលឯកសារផ្សេងរបស់សាស្ត្រច្បាប់មួយចំនួននៅក្នុងវិស័យច្បាប់។

កត្តាបន្ទាប់បន្សំ គឺប្រមូលព័ត៌មានតាមរយៈបទសម្ភាសន៍ក្នុងវិទ្យុមួយចំនួន ការផ្សព្វផ្សាយតាមទូរទស្សន៍ និងបណ្តាគេហទំព័រច្បាប់មួយចំនួន ដែលបានផ្សព្វផ្សាយគន្លងមក។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សារណានេះអាចនាំឱ្យ អ្នកអានទុកជាជំនួយស្មារតីដល់ការសិក្សាស្រាជ្រាវរបស់ខ្លួន បានយល់ដឹងដល់ការពង្រឹង និងពង្រីកលើវិស័យច្បាប់ព្រហ្មទណ្ឌ គឺបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនឹងទោសព្រហ្មទណ្ឌ ដើម្បីកំណត់ទោសឱ្យបានត្រឹមត្រូវ មានន័យថាទោសដែលសមស្របបំផុតទៅនឹងចំណុចតុល្យភាពរវាងការបង្ក្រាប និងការបង្ការនោះ គេត្រូវគិតមិនត្រឹមតែពីកាលៈទេសៈដែលបទល្មើសនោះត្រូវបានប្រព្រឹត្តប៉ុណ្ណោះទេ តែថែមទាំងបុគ្គលិកលក្ខណៈរបស់ចារីថែមទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងគម្រោងប្លង់នៃសារណាបញ្ចប់ការសិក្សា លើប្រធាបទស្ដីពី នីតិវិធីនៃការអនុវត្តមូលទោស នេះយើងខ្ញុំបានបែងចែកចេញជា ០៤ ជំពូក ដូចខាងក្រោម៖

- **ជំពូកទី១** សញ្ញាណទូទៅនៃទោស
- **ជំពូកទី២** បែបបទនៃការអនុវត្តមូលទោស
- **ជំពូកទី៣** វិធាននៃការអនុវត្តទោស និងមូលហេតុគតិយុត្តផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស
- **ជំពូកទី៤** នីតិវិធីនៃការអនុវត្តសេចក្ដីសម្រេចតុលាការពាក់ព័ន្ធនឹងមូលទោស។

# ជំពូកទី១
# សញ្ញាណទៅនៃទោស

# ជំពូកទី១
# សញ្ញាណទូទៅនៃទោស

បន្ទាប់ពីបានកំណត់នូវអត្ថិភាពនៃបទល្មើស និងពិរុទ្ធភាពរបស់ចារីរួចហើយ ចៅក្រមត្រូវផ្តន្ទាទោសចារីទៅតាមច្បាប់កំណត់។ ទោសដែលច្បាប់បានកំណត់ទុករួចជាស្រេចហើយនោះ មានចំនួនច្រើនប្រភេទ។ ការស្វែងយល់អំពីនិយមន័យអំពីទោស (**១.១**) ជាប្រការចាំបាច់ មុនឈានទៅដល់ប្រភេទនៃទោស (**១.២**) មុខងារនៃការដាក់ទោស (**១.៣**) និងចរិកលក្ខណៈនៃទោស (**១.៤**)។

## ១.១ និយមន័យ

ពាក្យថាទោស គឺជាទណ្ឌកម្មដែលត្រូវផ្តន្ទាដោយសង្គមតាមរយៈច្បាប់ទៅលើជន ឬបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស។[1] ទោស គឺជាកំហុស កម្មវិបាក ឬផលដែលចេញពីអំពើអាក្រក់ ឬទណ្ឌកម្មដែលតម្រូវលើជនណាម្នាក់ឱ្យរាងចាលឈប់ប្រព្រឹត្តល្មើសតទៅមុខទៀត។ ទោសដែលច្បាប់បានកំណត់រួចមកហើយនោះ មានចំនួនច្រើនប្រភេទ។ ដើម្បីការស្វែងយល់អំពីសញ្ញាណនៃទោស គឺប្រការចាំបាច់មុននឹងឈានដល់ប្រភេទនៃទោសព្រហ្មទណ្ឌផ្សេងៗទៀត គឺត្រូវស្វែងយល់អំពីនិយមន័យនៃទោសព្រហ្មទណ្ឌជាមុនសិន។

### ១.១.១. និយមន័យនៃទោសព្រហ្មទណ្ឌ

បើពិនិត្យទៅលើនិយមន័យតាមបែបទស្សនៈវិទ្យា ឬសង្គមវិទ្យា ទោសព្រហ្មទណ្ឌ គឺជាទណ្ឌកម្មរបស់សង្គម ឬជាការឆ្លើយតបរបស់សង្គមទៅអ្នកប្រព្រឹត្តបទល្មើស ឬប្រឆាំងនឹងចារីនៃបទល្មើស។ មានន័យថានៅក្នុងសង្គមទាំងអស់ តែងតែមានការកំណត់ច្បាប់ដើម្បីគ្រប់គ្រងសង្គម និងជាការធានាសណ្តាប់ធ្នាប់សង្គមដោយកំណត់នូវវិធានការ ឬសកម្មភាពមួយចំនួនដែលច្បាប់ហាមឃាត់ ហើយចំពោះការប្រព្រឹត្តផ្ទុយទៅនឹងអំពើដែលត្រូវបានហាមឃាត់របស់សង្គម នោះសង្គមនឹងមានវិធានការតបវិញ។ តាមន័យម្យ៉ាងទៀត ទណ្ឌកម្មត្រូវបានចាត់ទុកជាវិធានការរបស់រដ្ឋ ដែលត្រូវសម្រេចផ្តន្ទាទោសចំពោះជនណាម្នាក់ដែលត្រូវតុលាការសម្រេចថាជាជនមានពិរុទ្ធក្នុងអំពើណាមួយ ដោយសារការប្រព្រឹត្តអំពើរបស់ខ្លួន ប្រឆាំងនឹងច្បាប់ដែលកំពុងស្ថិតនៅជាធរមាន។ ការហាមឃាត់របស់ច្បាប់ព្រហ្មទណ្ឌជាបទល្មើសព្រហ្មទណ្ឌ ហើយការប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌត្រូវទទួលទោសព្រហ្មទណ្ឌ។

ចំពោះនិយមន័យតាមផ្លូវច្បាប់ ជាពិសេសផ្អែកទៅលើក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ទោសព្រហ្មទណ្ឌ គឺជាទោសដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌដើម្បីបង្ក្រាបបទល្មើសព្រហ្មទណ្ឌ ហើយដែលត្រូវប្រកាសទោសទោសដោយតុលាការព្រហ្មទណ្ឌ។ មាត្រា ១ នៃក្រមព្រហ្មទណ្ឌបានកំណត់ថា ច្បាប់ព្រហ្មទណ្ឌមានគោលដៅកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់

[1] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ២៩២ ។

ទោស ព្រមទាំងបែបបទនៃការអនុវត្តទោស។ ទោសព្រហ្មទណ្ឌត្រូវកំណត់ដោយច្បាប់ដែលឆ្លើយតបទៅនឹងគោលការណ៍ទូទៅ គឺគោលការណ៍នីត្យានុកូលភាពនៃច្បាប់ព្រហ្មទណ្ឌ។ ចរិកលក្ខណៈទី២ នោះគឺ ទោសព្រហ្មទណ្ឌត្រូវប្រកាសដោយតុលាការព្រហ្មទណ្ឌ។ មាត្រា ៦ នៃក្រមព្រហមទណ្ឌចែងថា គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះ មិនត្រូវបានប្រកាសទោសដោយតុលាការទេ។ តាមគតិច្បាប់ព្រហ្មទណ្ឌ ត្រូវបានចាត់ទុកទណ្ឌកម្មជាវិធាន ដែលត្រូវសម្រេចដោយតុលាការ ដើម្បីពិគ្រោះអំពីភារៈនៃការអនុវត្តទោសឱ្យដល់ចារីនូវបទល្មើសដែលខ្លួនបានប្រព្រឹត្ត។[2]

**គោលការណ៍ការមិនមានទោសប្រហារជីវិត**

សិទ្ធិរស់រានមានជីវិត គឺជាសិទ្ធិមេ ក្នុងន័យថា មានជីវិតទើបមានសិទ្ធិដទៃទៀត។ មាត្រា ៦ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ មិនបានហាមឃាត់ទោសប្រហារជីវិតទេ។ ប្រទេសមួយចំនួន បានប្រកាសលុបនូវទោសប្រហារជីវិត សូម្បីក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលខណៈដែលប្រទេសខ្លះបានរក្សាទោសប្រភេទនេះ ទោះបីបានចូលជាភាគីនៃកតិកាសញ្ញាក្តី។[3]

ក្នុងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានលុបចោលនូវទោសប្រហារជីវិតទាំងស្រុងដោយទោសប្រហារជីវិតមិនត្រូវមានឡើយ។[4] មូលហេតុចម្បង គឺប្រទេសកម្ពុជាធ្លាប់រងនូវការសម្លាប់រង្គាលក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩។ មានមូលហេតុសំខាន់មួយទៀតដែរនោះ គឺដោយសារប្រទេសកម្ពុជាជាភាគីនៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ មុនពេលដែលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានប្រកាសឱ្យប្រើ។ បន្ថែមពីនេះ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មានចែងដាក់ទោសបទប្រល័យពូជសាសន៍ ប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម គឺជាបទល្មើសក្រោមច្បាប់អន្តរជាតិ គ្មានអាជ្ញាយុកាលកំណត់នោះទេ គឺមានត្រឹមតែទោសជាប់ពន្ធនាគារមួយជីវិតតែប៉ុណ្ណោះ។[5]

ទោសព្រហ្មទណ្ឌដែរធ្ងន់បំផុត គឺការដាក់ពន្ធនាគារអស់មួយជីវិត ក៏មានប្រសិទ្ធភាពបង្ក្រាបបទល្មើសផងដែរ ប្រសិនបើការអនុវត្តច្បាប់មានប្រសិទ្ធភាព យុត្តិធម៌ និងស្មើភាព។ ការប្រើទោសប្រហារជីវិតដែលមិនអាចកាត់បន្ថយការកំណើននៃបទល្មើសនោះ បង្ហាញឱ្យឃើញថាជាការដាក់វិធានការមិនមានប្រសិទ្ធភាពដោយសារគេមិនបានគិតពីមូលហេតុដែលនាំឱ្យមានបទល្មើសធ្ងន់ធ្ងរ។[6]

---

[2] យោងតាមប្រសាសន៍របស់ ឯកឧត្តម ជូវ សំភី នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" រៀបចំដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា។

[3] មាស បូរ៉ា និង នូ ចន្ថា, អំពីទោសប្រហារជីវិត តើកម្ពុជាគួររក្សាការលុបទោសប្រហាជីវិត ឬប្រើទោសប្រភេទនេះឡើងវិញ?, ២០១៩, ១

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រា ៣២ កថាខណ្ឌទី ២ ។

[5] មាស បូរ៉ា និង នូ ចន្ថា, អំពីទោសប្រហារជីវិត តើកម្ពុជាគួររក្សាការលុបទោសប្រហាជីវិត ឬប្រើទោសប្រភេទនេះឡើងវិញ?, ២០១៩, ៧

[6] មាស បូរ៉ា និង នូ ចន្ថា, អំពីទោសប្រហារជីវិត តើកម្ពុជាគួររក្សាការលុបទោសប្រហាជីវិត ឬប្រើទោសប្រភេទនេះឡើងវិញ?, ២០១៩, ៩

### ១.១.២. និយមន័យនៃមូលទោស

មូលទោស គឺជាទោសដែលតុលាការបានសម្រេចអំពីទោសកម្ម ដើម្បីផ្តន្ទាទោសលើជនល្មើសណាម្នាក់ ដែលបានប្រព្រឹត្តល្មើសនឹងបញ្ញត្តិច្បាប់ដែលបានកំណត់ទុក។ មូលទោស គឺជាប្រភេទនៃទោសដែលតុលាការ មានសិទ្ធិសម្រេចដាច់ដោយឡែកតែឯកឯងបាន ដោយមិនចាំបាច់បញ្ចូលទោសបន្ថែមក៏បាន ឬបញ្ចូលមូល ទោសក៏បាន។

## ១.២. ប្រភេទនៃទោស

តាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើសព្រហ្មទណ្ឌ អំពើណាមួយដែលអាចជាបទល្មើស លុះត្រាតែអំពើនោះមានចែងក្នុងច្បាប់ជាធរមាន។ ចំពោះទោសដែលអាចប្រកាសបានក៏ទាល់តែមានចែងក្នុងច្បាប់ដែរ។ ហេតុនេះនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ សម្រាប់រាល់បទល្មើសទាំងអស់ គឺតែងតែមានចែងអំពីនិយមន័យ ធាតុផ្សំនៃបទល្មើស និងអំពីទោសដែលត្រូវអនុវត្តចំពោះអំពើល្មើសនោះ។ នៅក្នុងក្រមព្រហ្មទណ្ឌថ្មី ទោសត្រូវបានលើកយកមកពិចារណាក្នុងលក្ខណៈទូទៅ ហើយចែកចេញជាបីប្រភេទគឺរួមមាន មូលទោស( **១.២.១** ) ទោសបន្ថែម( **១.២.២** ) និងទោសជំនួស( **១.២.៣** )។

### ១.២.១. មូលទោស

គ្រប់បទល្មើសទាំងអស់សុទ្ធតែត្រូវផ្តន្ទាទោសយ៉ាងហោចណាស់ដោយមូលទោស។ បើយោងតាមមាត្រា ៩៩ នៃក្រមព្រហ្មទណ្ឌ បានបញ្ជាក់យ៉ាងច្បាស់ពីលក្ខណៈនៃទោសបន្ថែមដូចដែលមានចែងថា កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមលើមូលទោស។ បន្ថែមពីលើមូលទោស និងទោសបន្ថែម ក្រមព្រហ្មទណ្ឌក៏បានបង្កើតនូវប្រភេទនៃទោសមួយផ្សេងទៀត គឺទោសជំនួស។ មូលទោសរួមមាន ទោសដាក់ពន្ធនាគារ ( **១.២.១.១** ) និងទោសពិន័យជាប្រាក់ ( **១.២.១.២** )។[7]

#### ១. ២.១.១. ទោសពន្ធនាគារ

ទោសដាក់ពន្ធនាគារ គឺជាទោសដែលត្រូវបំបាត់ស្ទើរតែអស់នូវសេរីភាពជាមូលដ្ឋាន ដោយមានពេលកំណត់។ ការដកសេរីភាពមានន័យថា ទោសពន្ធនាគារដែលបញ្ញត្តទាំងក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ នៅក្នុងការកំណត់អំពីទោសដាក់ពន្ធនាគារ ក្រមព្រហ្មទណ្ឌកំណត់អំពីកម្រិតអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ។[8] ដោយទោសដាក់ពន្ធនាគារអាចជា ទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេល។ ទោសដាក់ពន្ធនាគារមានរយៈពេលអាចជាទោសដាក់ពន្ធនាគារមានរយៈពេលចាប់ពី ១ថ្ងៃ រហូតដល់ ៣០ឆ្នាំ។[9]

---

[7] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៩៣ កថាខណ្ឌទី១ ។

[8] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៩៤ កថាខណ្ឌទី១ ។

[9] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៩៦ កថាខណ្ឌទី១ ។

យោងតាមមាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌ ទោសដាក់ពន្ធនាគារ ១ថ្ងៃ ត្រូវគិត ២៤ម៉ោង ទោសដាក់ពន្ធនាគារ ១ខែ ត្រូវគិត ៣០ថ្ងៃ ទោសដាក់ពន្ធនាគារលើសពីមួយខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមានក្នុងខែនោះ ចំណែកឯទោសដាក់ពន្ធនាគារ ១ឆ្នាំ ត្រូវគិត ១២ខែ។ កាលបើទណ្ឌិតបានទទួលទោសនៅក្នុងពន្ធនាគារចប់សព្វគ្រប់ហើយ តាមថិរវេលាដូចបានកំណត់ក្នុងសេចក្តីផ្តន្ទាទោសហើយ ទណ្ឌិតនឹងត្រូវដោះលែងឱ្យមានសេរីភាពវិញ ប៉ុន្តែទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលបញ្ញត្តក្នុងច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ។[10]

### ១.២.១.២. ទោសពិន័យជាប្រាក់

ទោសពិន័យ គឺជាទោសដែលតម្រូវឱ្យទណ្ឌិតបង់ចំនួនប្រាក់កំណត់ដោយច្បាប់។ ទឹកប្រាក់នេះត្រូវកំណត់ជាប្រាក់រៀល។[11] ប្រាក់ជាផលនៃពិន័យត្រូវបង់ចូលថវិការដ្ឋ ដោយត្រូវបង់ចូលក្នុងរតនាគារជាតិ ពោលប្រាក់ពិន័យនេះមិនមែនជា ប្រាក់សំណងរដ្ឋប្បវេណីដែល ភាគីបង្កបង់សងជម្ងឺចិត្ត ទៅជនរងគ្រោះទេ។

### ១.២.២. ទោសបន្ថែម (អនុទោស)

ទោសបន្ថែម គឺជាទោសដែលត្រូវបន្ថែមទៅលើមូលទោស។ មានន័យថា គឺជាទោសបន្ទាប់បន្សំ ឬអនុទោសដែលចៅក្រមសម្រេចបន្ថែមក្នុងមូលទោស ហើយទាល់តែតុលាការសម្រេចថា បុគ្គលរូបណាមានមូលទោសហើយ ទើបតុលាការអាចសម្រេចដាក់ទោសបន្ថែមពីលើមូលទោសនោះបាន ពោលគឺទោសបន្ថែមនឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។[12] ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវប្រកាសសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។[13] ដូចនេះ ទោសបន្ថែមបង្កើតឡើងក្នុងគោលបំណង ដើម្បីឱ្យការដាក់ទណ្ឌកម្មមានភាពសមស្របទៅនឹងអំពើល្មើសច្បាប់ ដែលបុគ្គលរូបនោះបានប្រព្រឹត្ត ឬធានាដល់ការអនុវត្តគោលការណ៍ឯកត្តកម្មនៃទោស។

ឧទាហរណ៍៖ លោក ក ជាគ្រូពេទ្យ ហើយលោកបានប្រព្រឹត្តខុសទៅនឹងវិជ្ជាជីវៈរបស់ខ្លួន ដែលបណ្តាលឱ្យអ្នកជំងឺរងគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរ។ ដូចនេះយោងតាមមាត្រា៥៣ តុលាការអាចប្រកាសទោសបន្ថែម ដោយហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈដែលបានប្រព្រឹត្តក្នុងពេលប្រកបវិជ្ជាជីវៈ ឬព្យួរអាជ្ញាប័ណ្ណរបស់គាត់ជាដើម។

[10] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៥០ ។
[11] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៤៣ កថាខណ្ឌទី ២ ។
[12] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៥៤ កថាខណ្ឌទី ១ ។
[13] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៥៤ កថាខណ្ឌទី ២ ។

អនុទោស ឬ ទោសបន្ថែម មានដូចជា៖[14]

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ។

៤-ការព្យួរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណា ចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្ត បទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែល បទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ ។

[14] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៥៣ ។

ក្រៅពីទោសបន្ថែមដែលបានរៀបរាប់ខាងលើ ក៏មានទោសបន្ថែមដែលមានចែងក្នុងច្បាប់ដោយឡែកផង ដែរ។ ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង ៧ ខាងលើនេះ ត្រូវអនុវត្ត នៅពេលផុតទោសពន្ធនាគារ លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ។[15]

### ១. ២.៣. ទោសជំនួស

ទោសជំនួស គឺជាទោសដែលតុលាការយកមកប្រកាសជំនួសឱ្យមូលទោស។ ក្នុងករណីនេះ តុលាការ មិនអាចប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ។[16] តាមក្រមព្រហ្មទណ្ឌ ទោសជំនួសមានពីរ ប្រភេទ គឺ ទោសការងារសហគមន៍ ( **១.២.៣.១** ) និងការស្តីបន្ទោស (**១.២.៣.២**) ។

#### ១.២.៣.១. ទោសការងារសហគមន៍

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ម៉ោង ទៅ ២០០ម៉ោង នូវការងារ គ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល។[17] ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ។

ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងារបស់ស្ត្រី។ ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាព វិជ្ជាជីវៈ។[18]

តុលាការអាចប្រកាសទោសការងារសហគមន៍បាន កាលណាជនជាប់ចោទត្រូវទទួលការផ្តន្ទាទោស ដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬស្មើ ៣ឆ្នាំ។[19] ទោសអតិបរមាក្នុងន័យនេះ គឺសំដៅយកទោសដែល បញ្ញត្តិដោយច្បាប់ មិនមែនសំដៅទៅលើទោសដែលប្រកាសដោយតុលាការនោះទេ។

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយជនជាប់ចោទយល់ព្រមធ្វើការងារនេះផង។[20] តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់ អំពីចិរវេលានៃការងារ និងរយៈពេលដែលត្រូវបំពេញ ដោយរយៈពេលមិនអាចលើសពី ០១ ឆ្នាំទេ។[21] ការអនុវត្ត

[15] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៧១ ។
[16] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៩៨ ។
[17] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៧២ កថាខណ្ឌទី ២ ។
[18] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៧៤ ។
[19] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៥២ កថាខណ្ឌទី ១ ។
[20] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ១០១ ។
[21] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ១០២ ។

ទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាជាអ្នកចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ។ ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។[22]

### ១.២.៣.២. ការស្តីបន្ទោស

តុលាការអាចប្រកាសការស្តីបន្ទោស កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ០៣ ឆ្នាំ ហើយប្រសិនបើបានបំពេញលក្ខខណ្ឌបីយ៉ាងដែលមានដូចជា[23]៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈបង្កដោយបទល្មើសបានបញ្ចប់។
- ការខូចខាតត្រូវបានជួសជុលហើយ និង
- ជនជាប់ចោទបង្ហាញការធានាក្នុងការចូលទៅរួមរស់ក្នុងសង្គមវិញ។

តុលាការគ្រាន់តែស្តីបន្ទោសដល់ជនល្មើសដែលបានប្រព្រឹត្ត ពោលគឺមិនផ្តន្ទាទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់ឡើយ កាលបើជនល្មើសបានសងការខូចខាតរួចរាល់ហើយ ។

## ១. ៣ មុខងារនៃការដាក់ទោស

ច្បាប់ព្រហ្មទណ្ឌកំណត់និយមន័យនៃបទល្មើស ដោយចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោសព្រមទាំងបែបបទនៃការអនុវត្តទោសនេះ។ ច្បាប់ព្រហ្មទណ្ឌ គឺជាច្បាប់ដែលមានកម្មវត្ថុបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើស។ ដោយពិនិត្យទៅលើច្បាប់ព្រហ្មទណ្ឌនេះ សឱ្យឃើញផងដែរថា បទល្មើសត្រូវបានកំណត់ដោយច្បាប់ មានន័យថាកំណត់ដោយសង្គមដែលសម្រេចបង្ក្រាបឥរិយាបថណាមួយ។ ការធ្វើដូច្នេះ សង្គមក៏សម្រេចបង្កើតឱ្យមានឡើងនូវវិធានទាំងឡាយដែលមានឧបនិស្ស័យជានារក្សាការពារបង្ការទុកជាមុនសណ្តាប់ធ្នាប់សង្គម (**១.៣.១**) បន្ថែមពីលើកិច្ចការពារដល់ប្រយោជន៍ឯកជន។ ប៉ុន្តែ នៅពេលបទល្មើសមួយកើតឡើង សង្គមក៏ត្រូវមានប្រតិកម្មភ្លាមតបតដោយធ្វើការបង្ក្រាបទៅលើអំពើបំពាននោះ (**១.៣.២**) ។ បន្ទាប់ពីនោះ វិធានចុងក្រោយ គឺការដាក់ឱ្យចារីក្រោមវិធានការអប់រំកែប្រែនៅក្រោយពេលការប្រកាសទោសរបស់ខ្លួន (**១.៣.៣**) ។

### ១.៣.១. ការបង្ការទុកជាមុន

អំពើចលាចលដល់សង្គម ស្ថិតនៅក្នុងបេះដូងនៃបទល្មើសព្រហ្មទណ្ឌ និងតម្រូវឱ្យមានអន្តរាគមន៍ពីនីតិនិពន្ធ បានបំផុសឡើងនូវការពិចារណាមួយចំនួន ជាអាទិ៍លើចំណុចដែលសួរថាតើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីលុបបំបាត់ភាពចលាចលនេះឱ្យបានទាំងស្រុង ឬយ៉ាងហោចណាស់សាកល្បងកាត់បន្ថយជាអតិបរមា។ វត្ថុ

[22] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ១០៣ ។

[23] ក្រមព្រហ្មទណ្ឌ ២០០៩, មាត្រា ៧៦ ។

បំណងនេះ គឺសម្រេចឱ្យបាននូវការបង្ការទប់ស្កាត់កុំឱ្យមានបទល្មើស ដោយធ្វើយ៉ាងណាឱ្យបទល្មើសលែងត្រូវបានប្រព្រឹត្តតទៅទៀត និងតាមរយៈអន្តរាគមន៍ជាមុន។

នៅមុនពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត អន្តរាគមន៍នេះតម្រូវឱ្យមានប្រតិកម្មដ៏សមស្របមួយដែលត្រូវអនុវត្តចំពោះជនទាំងឡាយណាដែលអាចនឹងប្រព្រឹត្តបទល្មើសនៅពេលខាងមុខ។ ប្រតិកម្ម គឺជាកិច្ចបង្ការនេះ ជាក់ស្តែងមានភាពស្មុគស្មាញខ្លាំងណាស់ ម្យ៉ាងគេមិនប្រាកដទាំងស្រុងថា ជនណាម្នាក់នឹងប្រព្រឹត្តបទល្មើសឡើយ បើទោះបីជននោះស្ថិតនៅក្នុងលក្ខខណ្ឌដែលអនុគ្រោះដល់ការប្រព្រឹត្តបទល្មើសក៏ដោយ។ ម្យ៉ាងទៀត ប្រតិកម្មដែលជាកិច្ចបង្ការដែលអនុវត្តចំពោះបុគ្គលនេះនឹងតម្រូវឱ្យមានជាចាំបាច់នូវការបង្ខឹតបង្ខំដ៏ជាក់លាក់មួយចំនួនចំពោះបុគ្គលនោះ ប៉ុន្តែនៅក្នុងករណីនេះ ជននោះពុំទាន់បានប្រព្រឹត្តបទល្មើសនៅឡើយទេ។[24]

### ១.៣.២. ការបង្រ្កាបបទល្មើស

នៅក្នុងការអនុវត្តជាក់ស្តែង ការបង្រ្កាបបទល្មើសនៅក្រោយពេលមានការប្រព្រឹត្តបទល្មើស ងាយស្រួលជាងបង្ការនៅមុនពេលប្រព្រឹត្តបទល្មើស។[25] មធ្យោបាយដ៏សំខាន់បំផុតក្នុងការបង្រ្កាប គឺការដាក់ទោសដែលធ្វើឱ្យចារីត្រូវនៅឃ្លាតឆ្ងាយពីសង្គម លែងអនុញ្ញាតឱ្យចារីអាចមានឱកាសនឹងប្រព្រឹត្តបទល្មើសដែលប្រាថ្នាតទៅទៀត។[26]

### ១.៣.៣. ការអប់រំកែប្រែ

ការដាក់ទោសលើចារី ពុំមែនសុទ្ធតែមានគោលដៅក្នុងការបណ្តេញចារីឱ្យចាកចេញពីសង្គមជាស្ថាពរនោះទេ ក៏ប៉ុន្តែគឺគ្រាន់តែជាការក្រើនរំលឹកអប់រំដល់ចារីឱ្យដឹងខុសដឹងត្រូវឡើងវិញ ហើយខិតខំកែប្រែខ្លួនឱ្យក្លាយជាពលរដ្ឋល្អសម្រាប់សង្គមជាតិ និងមិនមែនត្រូវប្រព្រឹត្តបទល្មើសតទៅទៀតតែប៉ុណ្ណោះ។ ហេតុដូច្នេះ មុខងារចុងក្រោយនេះ គឺជាមុខងារដែលធ្វើយ៉ាងណាសម្រួល អប់រំកែប្រែ និងធានាឱ្យទណ្ឌិតអាចធ្វើសមាហរណកម្មចូលក្នុងសង្គមវិញបាន។ ការអប់រំកែប្រែទណ្ឌិតនេះជាមុខងារសំខាន់ ព្រោះការដាក់ព្រហ្មទណ្ឌដែលមានគោលដៅដាក់ទណ្ឌកម្មតែមួយមុខនោះ គឺពុំមានផលប្រយោជន៍ដល់សង្គមខ្លាំងនោះទេ។ ដូច្នេះហើយ បានជាត្រូវពិនិត្យលើទណ្ឌិតដែលបានទទួលទោសរួចអាចកែប្រែ អាចធ្វើសមាហរណកម្មចូលក្នុងសង្គមវិញ ទើបមានផលប្រយោជន៍ដល់សង្គម។ បន្ថែមពីនេះ ចំពោះទណ្ឌិតដែលអនុវត្តទោសរួច អាចធ្វើសមាហរណកម្មចូលក្នុងសង្គមវិញ ហើយកែប្រែខ្លួនទៅជាមនុស្សល្អ សង្គមនោះនឹងមានសន្តិសុខនិងស្ថេរភាពខ្ពស់ ដោយមិនមានបទល្មើសក៏កើតទៀត។ ប៉ុន្តែផ្ទុយទៅវិញ ករណីទណ្ឌិតដែលចេញពីពន្ធនាគារ ហើយត្រឡប់បែរជាទៅប្រព្រឹត្តបទល្មើសទៀត

[24] សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ, មេរៀននីតិព្រហ្មទណ្ឌ, អត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧, ៧ ។

[25] សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ, មេរៀននីតិព្រហ្មទណ្ឌ, អត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧, ៧ ។

[26] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ២៩៣ ។

ដែលនាំឱ្យប៉ះពាល់ខ្លាំងដល់សង្គម ឬអាចសន្និដ្ឋានបានថាប្រព័ន្ធការពារ ឬបង្ក្រាបរបស់សង្គមមិនទាន់មានប្រសិទ្ធភាពខ្ពស់ និងធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្ត និងសន្តិសុខសណ្តាប់ធ្នាប់សង្គម។ ហេតុដូច្នេះហើយ ក្នុងក្របខ័ណ្ឌក្នុងការធានាអប់រំកែប្រែទណ្ឌិត និងធានាសមាហរណកម្មទណ្ឌិតទៅក្នុងសង្គមវិញ ក្រមព្រហ្មទណ្ឌផ្តោតជាពិសេសទៅលើមុខងារអប់រំកែប្រែនេះ ដោយបានកំណត់នូវគោលការណ៍ជាច្រើន ដូចជា គោលការណ៍ឯកត្តកម្មនៃទោស គោលការណ៍ និងយន្តការផ្សេងៗទៀតដើម្បីជ្រើសរើសទោសឱ្យសមស្របទៅនឹងបុគ្គលភាពនៃជនល្មើស ហើយអាចកែសម្រួល ឬធ្វើសមាហរណកម្មទណ្ឌិតចូលក្នុងសង្គមវិញ។

## ១.៤ ចរិកលក្ខណៈនៃទោស

ជាមូលដ្ឋានទូទៅ ទាក់ទងទៅនឹងបញ្ញត្តិអំពីទោសនេះ ក្រមព្រហ្មទណ្ឌកំណត់នូវគោលការណ៍ និងមានចរិកលក្ខណៈដែលជាគ្រឹះសំខាន់រួមមាន គោលការណ៍នីត្យានុកូលភាព (**១.៤.១**) គោលការណ៍ឯកត្តកម្មនៃទោស (**១.៤.២**) ចរិកលក្ខណៈសមភាព (**១.៤.៣**) និងគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ (**១.៤.៤**) ។

### ១.៤.១. គោលការណ៍នីត្យានុកូលភាព

យោងតាមកថាខណ្ឌទី១ មាត្រា៣១នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុញ្ញាតទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ដូចនេះ យើងមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានទទួលស្គាល់នូវគោលការណ៍ នេះតាមរយៈមាត្រា១១ ដោយកំណត់ថា គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌដោយអំពើ ឬការខកខានមិនបានធ្វើ បើអំពើ ឬការខកខាននេះមិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិថាជាបទល្មើសព្រហ្មទណ្ឌ នៅពេលធ្វើអំពើ ឬមានការខកខាននេះ។ ដូចនេះ អំពើមួយអាចក្លាយជាបទល្មើសបាន លុះត្រាណាតែមានចែងច្បាស់លាស់ក្នុងច្បាប់ជាមុន ដើម្បីឱ្យពលរដ្ឋអាចយល់ដឹងផង។ ការធ្វើដូចនេះ គឺអាចឱ្យពលរដ្ឋបែងចែកអំពើណាខ្លះជាបទល្មើស អំពើណាខ្លះជាសេរីភាពរបស់ខ្លួន។ ក្នុងន័យនេះ ច្បាប់ហាក់ដូចជាស្តែងនូវព្រំដែននៃសិទ្ធិ ហើយអ្នកច្បាប់ជាច្រើនយល់ថា ការធ្វើដូច្នេះអាចជួយទប់ស្កាត់ ការប្រព្រឹត្តបទល្មើស នៅក្នុងសង្គមផង និងជួយការពារសិទ្ធិសេរីភាពបុគ្គលផង ព្រោះការបែងចែកកំណត់ជាមុនគឺអាចឱ្យជនទាំងនោះខ្លាចរអានឹងប្រព្រឹត្តបទល្មើស និងការទទួលទោស។[27]

[27] ការផ្សាយរបស់ក្រុមត្រាជូ អត្ថបទសាកល្បងស្តីពីនីតិព្រហ្មទណ្ឌទូទៅ, គោលការណ៍នីត្យានុកូលភាពនៃបទល្មើសនិងទោស, ប្រែសម្រួលដោយ ផៃ ចេងសេង, ២០១៦, ២ ។

នៅក្នុងគោលការណ៍គ្រឹះនេះ គឺត្រូវបានគេយកមកពីពាក្យថា គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង។ យោងទៅតាមអត្ថន័យនៃពាក្យនេះ យើងអាចបែងចែកជាពីរប្រភេទផ្សេងទៀតនៃគោលការណ៍នីត្យានុកូល គឺ គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស។

នីត្យានុកូលភាពនៃបទល្មើស គឺសំដៅលើអំពើណាមួយ ដែលគេអាចចាត់ទុកថាជាបទល្មើសបាន លុះត្រាតែអំពើនោះមានចែងជាមុនយ៉ាងច្បាស់លាស់ក្នុងច្បាប់ជាបទល្មើស បើមិនដូច្នោះទេ តុលាការមិនអាចផ្តន្ទាទោសជនប្រព្រឹត្តនោះបានឡើយ ហេតុនេះហើយបានជាមានគោលការណ៍មួយកំណត់ថា គ្មានបទល្មើសណាដែលច្បាប់មិនបានចែងឡើយ។ នោះយើងអាចយល់បានថាគោលការណ៍នេះបានតំរូវឱ្យច្បាប់ព្រហ្មទណ្ឌកំណត់ឱ្យបានច្បាស់លាស់នូវនិយមន័យនៃបទល្មើសនីមួយៗ ជាពិសេសសញ្ញាណនៃធាតុផ្សំ។[28]

នីត្យានុកូលភាពនៃទោស គឺមានន័យថា ដើម្បីយកទោសណាមួយទៅផ្តន្ទាទោសលើជនណាម្នាក់បាន លុះត្រាតែទោសនោះមានចែងទុកជាមុនក្នុងច្បាប់ព្រហ្មទណ្ឌ បើមិនដូច្នោះទេ គេមិនអាចអនុវត្តទោសទៅលើបុគ្គលណាម្នាក់បានឡើយ។ ដូចនេះ គឺដាច់ខាតត្រូវតែតំរូវឱ្យមានចែងពីបទប្បញ្ញត្តិនៃទោស បើមិនដូច្នោះទេចៅក្រមមិនអាចប្រកាសលើជនណាមួយបានឡើយ គឺមិនអាចបង្កើតទោសទណ្ឌដោយខ្លួនឯងនោះទេ ទោះជាច្បាប់កំណត់ថាអំពើនោះជាបទល្មើសក៏ដោយ។[29]

### ១.៤.២. គោលការណ៍ឯកត្តកម្មនៃទោស

គោលការណ៍ធំមួយទៀត គឺគោលការណ៍ឯកត្តកម្មនៃទោស ដែលមានចែងនៅក្នុងបទប្បញ្ញត្តិនៃមាត្រា ៩៦។ គោលការណ៍ឯកត្តកម្មនៃទោស គឺជាគោលការណ៍ដែលមានន័យថា ទោសដែលចៅក្រមត្រូវសម្រេច ឬត្រូវប្រកាស ឬត្រូវកំណត់សម្រាប់បុគ្គលនីមួយៗដែលប្រែប្រួលទៅតាមបុគ្គលនីមួយៗ និងប្រែប្រួលទៅតាមកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសរបស់បុគ្គលនោះតែម្តង។ តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុក ទៅលើមូលហេតុ ព្រមទាំង ទៅលើកិរិយាមាយាទរបស់ជនរងគ្រោះ។[30] ចំណុចនេះបញ្ជាក់អំពីមូលដ្ឋានសំខាន់ៗទាក់ទងជាមួយនឹងអ្វីដែលចៅក្រម ត្រូវដាក់ទោសមួយឱ្យសមស្របទៅនឹងស្ថានភាពរបស់បុគ្គលម្នាក់ៗ។ ឧទាហរណ៍ បុគ្គលដែលចូលរួមប្រព្រឹត្តបទល្មើសមានច្រើន ដែលមានខ្លះចូលរួមក្នុងឋានៈជាចារី ឬក៏

[28] ការផ្សាយរបស់ក្រុមត្រាជូ អត្ថបទសាកលល្បងស្តីពីនីតិព្រហ្មទណ្ឌទូទៅ, គោលការណ៍នីត្យានុកូលភាពនៃបទល្មើសនិងទោស, ប្រែសម្រួលដោយ ផៃ ចេងសេង, ២០១៦, ៤ ។

[29] ការផ្សាយរបស់ក្រុមត្រាជូ អត្ថបទសាកលល្បងស្តីពីនីតិព្រហ្មទណ្ឌទូទៅ, គោលការណ៍នីត្យានុកូលភាពនៃបទល្មើសនិងទោស, ប្រែសម្រួលដោយ ផៃ ចេងសេង, ២០១៦, ៤ ។

[30] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ៩៦ ។

អ្នកខ្លះចូលរួមក្នុងឋានៈជាសហចារី អ្នកខ្លះចូលរួមក្នុងឋានៈជាអ្នកផ្ដើមគំនិត ចំណែកអ្នកខ្លះចូលរួមក្នុងឋានៈជាអ្នកសមគំនិត។

ដូច្នេះ នៅពេលដែលចៅក្រមសម្រេចគ្រប់ពេលទាំងអស់ គឺត្រូវគិតទៅលើទឡ្ហីករណ៍ ដែលមានចែងក្នុងមាត្រា៩៦ និងមាត្រា២៤ ដែលជាមូលដ្ឋានក្នុងការដែលជ្រើសរើសយកទោសណាមួយ ឬរូបមន្តណាមួយ ទៅប្រើឱ្យត្រូវនៅក្នុងស្ថានភាពរបស់បុគ្គលម្នាក់ៗ ពីព្រោះថាអ្នកដែលប្រព្រឹត្តបទល្មើសអាចខុសគ្នាដូចជា អ្នកខ្លះប្រព្រឹត្តបទល្មើសលើកទីមួយ អ្នកខ្លះប្រព្រឹត្តបទល្មើសរួចហើយ ក៏ប្រព្រឹត្តទៀត រីឯជនខ្លះគឺជាជនកាចសាហាវ អ្នកខ្លះប្រព្រឹត្តដោយសារតែខ្លួនរំជួលចិត្តជាដើម។ល។ ដូច្នេះ ចំណុចទាំងអស់នេះ គឺសុទ្ធសឹងតែជាមូលដ្ឋានដែលចៅក្រមយកទៅធ្វើការពិចារណា ដើម្បីផ្ដន្ទាទោសទៅលើបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

### ១.៤.៣. ចរិតលក្ខណៈសមភាព

ការចែងពីទោសពុំមានមូលដ្ឋានផ្អែកទៅលើលក្ខខណ្ឌសង្គម ដែលរួមមានដូចជារូបសម្បត្តិ ភេទ ទ្រព្យសម្បត្តិ ។ល។ នៃបុគ្គលដែលត្រូវផ្ដន្ទាទោសនោះទេ ។[31] នេះជាការអនុវត្តនូវគោលការណ៍សមភាពរវាងពលរដ្ឋគ្រប់រូប។[32]

ឧទាហរណ៍ មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ បានកំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ សម្រាប់បទឃាតកម្ម ដែលមិនបានបញ្ជាក់ថា ទោសនេះត្រូវអនុវត្តតែទៅលើបុរស ឬស្ត្រី អ្នកមាន ឬអ្នកក្រឡើយ ។

### ១.៤.៤. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ឯកត្តកកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺសំដៅដល់ការទទួសខុសត្រូវចំពោះអំពើផ្ទាល់ខ្លួន។ អំពើផ្ទាល់ខ្លួន មានន័យថា បើបុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើស ដូច្នេះបុគ្គលនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ ករណីបែបនេះ គឺខុសពីរឿងក្ដីរដ្ឋប្បវេណី ដែលច្បាប់បានអនុញ្ញាតឱ្យអ្នកដទៃទទួលខុសត្រូវជំនួសបាន។ ប៉ុន្តែក្នុងរឿងព្រហ្មទណ្ឌ អ្នកដែលប្រព្រឹត្តបទល្មើស គឺជាអ្នកទទួលខុសត្រូវ ឬដែលនិយាយជាទូទៅថា អ្នកណាធ្វើ អ្នកនោះទទួល។ ហេតុនេះមិនអាចឱ្យបុគ្គលផ្សេងចូលខ្លួនមកទទួលទោសជំនួសបាននោះទេ ទោះបីជាប្រភេទទោសអ្វីក៏ដោយ។ ករណី មូលទោស គឺត្រូវបានបែងចែកជាពីរប្រភេទ គឺទោសដាក់ពន្ធនាគារ

[31] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ២៩៤ ។

[32] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,១៩៩៣, មាត្រា ៣១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ : ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។

និងទោសពិន័យជាប្រាក់។ ត្រង់ចំណុចនេះ ករណីត្រូវផ្តន្ទាទោសជនណាម្នាក់ដាក់ពន្ធនាគារ គឺច្បាប់មិនអនុញ្ញាតឱ្យបុគ្គលចូលមកទទួកទោសជំនួសឱ្យអ្នកប្រព្រឹត្តនោះទេ សូម្បីតែការបង់ប្រាក់ពិន័យ ក៏ច្បាប់មិនអនុញ្ញាតឱ្យអ្នកដទៃទៅបង់ប្រាក់ជំនួសដែរ មានន័យថាបុគ្គលនោះត្រូវទៅបង់ប្រាក់ពិន័យខ្លួនឯង ដែលត្រូវកំណត់អំពីគោលការណ៍មួយថា ការទទួលខុសត្រូវផ្ទាល់ខ្លួន ដែលជាគោលបំណងនៃទោសព្រហ្មទណ្ឌដែលមានគោលដៅធ្វើឱ្យជននោះ ខ្លាចរអា និងដើម្បីបង្ការដល់សាធារណៈជន។

# ជំពូកទី២
# បែបបទនៃការអនុវត្តមូលទោស

# ជំពូកទី២
# ប្រភេទនៃការអនុវត្តមូលទោស

យោងតាមក្រមព្រហ្មទណ្ឌ មាត្រា ២ ចែងថា ច្បាប់បញ្ញត្តថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស។ បន្ថែមពីនេះទៅទៀត ទាំងរូបវន្តបុគ្គល និងទាំងនីតិបុគ្គលសុទ្ធតែទទួលខុសត្រូវព្រហ្មទណ្ឌនៅពេលដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ចំពោះការអនុវត្តមូលទោស ក្រមព្រហ្មទណ្ឌបានបញ្ញត្តយ៉ាងច្បាស់លាស់ចំពោះការអនុវត្តមូលទោសចំពោះរូបវន្តបុគ្គល (**២.១**) និងការអនុវត្តមូលទោសចំពោះនីតិបុគ្គល (**២.២**) ដែលមានលក្ខខណ្ឌខុសៗគ្នា។

## ២.១. ការអនុវត្តមូលទោសចំពោះរូបវន្តបុគ្គល

រូបវន្តបុគ្គល គឺសំដៅទៅដល់បុគ្គលម្នាក់ៗដែលមានជីវិត មានសាច់ មានឈាមពិតៗដែលផ្ទុយពីនីតិបុគ្គល។ ជាគោលការណ៍ នៅពេលដែលបានប្រព្រឹត្តអំពើល្មើសណាមួយហើយ បុគ្គលនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដោយឆ្លងកាត់នីតិវិធីជាច្រើនរហូតឈានដល់ការអនុវត្តមូលទោស តាមរយៈការប្រកាសពីតុលាការប៉ុន្តែរាល់ការប្រកាសមូលទោសនីមួយៗវាអាស្រ័យទៅលើនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌព្រមទាំងស្ថានភាពដទៃទៀតផងដែរ។

បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅមានទម្ងន់នៃបទល្មើសនោះ។[33] ដើម្បីកំណត់បទល្មើសមួយជាបទឧក្រិដ្ឋ ឬជាបទបជ្ឈិម ឬជាបទលហុ គឺត្រូវពិនិត្យមើលទៅលើការប្រកាសមូលទោស មានន័យថាអតិបរមានៃទោសដាក់ពន្ធនាគារដែលក្រមព្រហ្មទណ្ឌកំណត់សម្រាប់បទល្មើសនោះ ។

ជាទូទៅ ដោយអនុលោមតាមក្រមព្រហ្មទណ្ឌ៖

- បទឧក្រិដ្ឋ ៖ យោងទៅតាមមាត្រា៤៦ នៃក្រមព្រហ្មទណ្ឌ ក្នុងបទឧក្រិដ្ឋគេមានកំណត់២យ៉ាង គឺទោសដាក់ពន្ធនាគារអស់មួយជីវិត និងអតិបរមានៃទោសដាក់ពន្ធនាគារលើសពី៥ឆ្នាំឡើងទៅនិងក្រោមឬ ស្មើនឹង៣០ឆ្នាំ ។[34] ឧទាហរណ៍ ៖ បទរំលោភសេពសន្ថវៈនៅក្នុងមាត្រា២៣៩ ដោយត្រូវដាក់ពន្ធនាគារពី៥ឆ្នាំដល់១០ឆ្នាំ ។

- បទមជ្ឈិម ៖ នៅក្នុងមាត្រា៤៧ គឺបទមជ្ឈិម គេបានកំណត់អតិបរមានៃទោសដាក់ពន្ធនាគារលើសពី៦ថ្ងៃ និងក្រោមឬស្មើនឹង៥ឆ្នាំ ។[35] ឧទាហរណ៍ ៖ បទលួច នៅក្នុងមាត្រា៣៥៦ ដោយត្រូវដាក់ពន្ធនាគារពី៦ខែដល់៣ឆ្នាំ។

[33] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ២ វាក្យខណ្ឌ២ ។

[34] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ៤៦ ។

[35] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ៤៧ ។

- បទលហុ ៖ ក្នុងមាត្រា៤៨ គឺយើងមើលទៅលើគោលការណ៍ពីរយ៉ាង ដែលគោលការណ៍ទី១ ត្រូវមើលទៅលើអតិបរមានៃទោសដាក់ពន្ធនាគារគឺមានរយៈពេលក្រោម ឬស្មើ៦ថ្ងៃ ។ ចំណែកគោលការណ៍ទី២ គឺត្រូវមើលទៅលើបទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។[36] ឧទាហរណ៍ ៖ បទស្រវឹងជាក់ស្តែង ក្នុងមាត្រា ២៩៧ និងបទហៅអ្នកដទៃនៅទីសាធារណៈក្នុងមាត្រា ២៩៨ ។

ចំពោះនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលអាចជានីតិជន (**២.១.១**) និងអនីតិជនដែលរបបនៃការអនុវត្តមូលទោសគឺមានភាពខុសពីគ្នាផងដែរ (**២.១.២**) ។

### ២.១.១ ការអនុវត្តមូលទោសចំពោះនីតិជន

មូលទោសគឺជាទោសមូលដ្ឋានមួយសម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស ហើយតាមរយៈមាត្រា៤៣ នៃលក្រមព្រហ្មទណ្ឌបានកំណត់ថា មូលទោសមានទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់។ តាមរយៈមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌបានចែងថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ១៨ឆ្នាំឡើងទៅ។ ជាគោលការណ៍ទាក់ទងជាមួយការប្រកាសមូលទោសចំពោះនីតិជនគឺមានចែងបញ្ជាក់ក្នុងមាត្រ ៩៧ នៃក្រមព្រហ្មទណ្ឌបានចែងថានៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផងតុលាការអាចប្រកាស៖

- ទោសដាក់ពន្ធនាគារផង និងទោសពិន័យជាមួយគ្នា ឬ
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

កាលណាតុលាការប្រកាសទោសព្រហ្មទណ្ឌចំពោះនីតិជន ទោសនោះត្រូវយកមកអនុវត្តក្នុងចន្លោះពេលដែលប្រកាសនោះ តាមបទល្មើសនីមួយៗដែលច្បាប់បានចែងកំណត់ទុកជាមុន។

### ២.១.២ ការអនុវត្តមូលទោសចំពោះអនីតិជន

យោងតាមសន្ទានុក្រមច្បាប់ អនីតិជនគឺសំដៅទៅដល់ជនទាំងឡាយណាដែល៖

- ជនដែលច្បាប់មិនទាន់ឱ្យទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។
- ជនដែលច្បាប់កំណត់ឱ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមានកម្រិត។

អនីតិជនគឺសំដៅដល់បុគ្គលទាំងឡាយណាដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជាបុគ្គលដែលមានអាយុក្រោម១៨ឆ្នាំ។[37] អនីតិជនត្រូវបានបែងចែកជាអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ (**២.១.២.១**)

[36] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ៤៨ ។

[37] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី។

អនីតិជនដែលមានអាយុពី១៤ឆ្នាំទៅក្រោមអាយុ១៨ឆ្នាំ (**២.១.២.២**) ។ ជាគោលការណ៍អនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ដោយយោងតាមមាត្រា៣៩ នៃក្រមព្រហ្មទណ្ឌបានចែងថាអនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ ការការពារ និងការឧបត្ថម្ភ។ ប៉ុន្តែមិនមែនមានន័យថានៅពេលដែលអនីតិជនប្រព្រឹត្តបទល្មើសសុទ្ធសឹងតែរួចផុតពីការទទួលខុសត្រូវនោះទេ ក្នុងចំណោមអនីតិជនដែលបានរៀបរាប់ខាងលើ មានអនីតិជនមួយដែលតុលាការអាចប្រកាសទោសព្រហ្មទណ្ឌបាន ហើយចំណុចនោះនឹងត្រូវយកមកបកស្រាយដូចខាងក្រោម។

### ២.១.២.១ អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ វាជាលក្ខណៈពិសេសចំពោះអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំគឺមិនត្រូវបានកំណត់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ចៅក្រមអាចប្រើប្រាស់បានតែវិធានការដូចដែលមានចែងក្នុងមាត្រា៣៩ នៃក្រមព្រហ្មទណ្ឌតែប៉ុណ្ណោះ។ ដូចនេះ អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ មិនត្រូវបានប្រកាសទោសព្រហ្មទណ្ឌដែលរួមមាន មូលទោស និងទោសពិន័យជាប្រាក់នោះទេ។

### ២.១.២.២ អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ និងក្រោមអាយុ១៨ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ និងក្រោមអាយុ១៨ឆ្នាំ ជាវិធានការច្បាប់ទុកលទ្ធភាពឱ្យចៅក្រមធ្វើការពិចារណាលើវិធានការពីរគឺ

ក. កាលណាតុលាការសម្រេចមិនប្រកាសទោសព្រហ្មទណ្ឌចំពោះអនីតិជន តុលាការអាចប្រើប្រាស់នូវវិធានសំរាប់ប្រើប្រាស់ចំពោះអនីតិជនដូចដែលមានចែងក្នុងមាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ។ ជាទូទៅរាល់អនីតិជនអាយុពី១៤ ដល់ក្រោម ១៨ឆ្នាំ ដែលប្រព្រឹត្តបទល្មើសទាំងអស់ តុលាការអាចសម្រេចដាក់គាត់ក្នុងវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដែលមានដូចជា[38]៖

១- ការប្រគល់អនីតិជនទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលិកដែលថែរក្សា អនីតិជននោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២- ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣- ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤- ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥- ការដាក់អនីតិជនឱ្យនៅក្រោមការការពាររបស់តុលាការ ។

[38] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ៤០ ។

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការនឹងចាត់តាំងបុគ្គលមួយរូបដែលត្រូវទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ស្ដីពី កិរិយាមារយាទរបស់ អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មានដល់ព្រះរាជាអាជ្ញា អំពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឱ្យ មានការកែប្រែនូវវិធាននេះ ។[39]

ខ. តុលាការអាចប្រកាសទោសព្រហ្មទណ្ឌបានលើអនីតិជន ប្រសិនបើកាលណាកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ ប៉ុន្តែទាក់ទងទៅនឹងការអនុវត្តនូវមូលទោសរបស់អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំទៅក្រោមអាយុ១៨ឆ្នាំនោះ គឺមានលក្ខណៈពិសេសជាងនីតិជនធម្មតា នេះបើតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌដោយបានចែងកំណត់ថា កាលណាតុលាការ សម្រេចផ្ដន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅៈ

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្ដាល។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកជាពន្ធនាគារ២០(ម្ភៃ)ឆ្នាំ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល ប្រសិនបើអប្បបរមានេះលើសពី១ ថ្ងៃ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល។ បន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ០៥ (ប្រាំ )ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។

មាត្រានេះគឺអាចអនុវត្តចំពោះតែអនីតិជនហើយចៅក្រមសម្រេចប្រកាសទោសព្រហ្មទណ្ឌបានកាលណាការប្រព្រឹត្តបទល្មើសរបស់អនីតិជនមានភាពកាចសាហាវដូចនេះចៅក្រមមានជម្រើសតែមួយគឺប្រកាសទោសព្រហ្មទណ្ឌ។ ឧទាហរណ៍ អនីតិជនអាយុ១៦ឆ្នាំបានប្រព្រឹត្តបទរំលោភសេពសន្ថវៈ រួចហើយក៏សម្លាប់នារីរងគ្រោះ។ ចំពោះបទល្មើសនេះ មានលក្ខណៈកាចសាហាវដែលទាមទារឱ្យចៅក្រមត្រូវតែប្រើប្រាស់វិធានការដាក់ទោសព្រហ្មទណ្ឌជាដាច់ខាត ដើម្បីធានាថាអនីតិជនដែលបានប្រព្រឹត្តបទល្មើសនោះនឹងមិនទៅប្រព្រឹត្តបទល្មើសម្ដងទៀតបាន ហើយដើម្បីធ្វើសមាហរណកម្មជននោះឱ្យកែប្រែខ្លួននឹងអាចចូលមករួមរស់ក្នុងសង្គមវិញបាន។ បើចៅក្រមហ៊ានប្រើវិធានការណាផ្សេងក្រៅពីវិធានការដាក់ទោសព្រហ្មទណ្ឌនោះ ជនដែលបាន

[39] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ៤១ ។

ប្រព្រឹត្តបទល្មើសនឹងមិនខ្លាចច្បាប់ ព្រោះបើទោះបីជាគេបានប្រព្រឹត្តបទល្មើសក៏ដោយក៏មិនទទួលទណ្ឌកម្មព្រហ្មទណ្ឌ។

## ២.២ ការអនុវត្តមូលទោសចំពោះនីតិបុគ្គល

ចំពោះនីតិបុគ្គល នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ នីតិបុគ្គលអាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើស ដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។[40] វាស្តែងចេញពីគោលការណ៍នៃភាពស្មើគ្នាចំពោះមុខច្បាប់។ គោលការណ៍នេះត្រូវបានសម្តែងឡើងនៅក្នុងវាក្យខណ្ឌទី១ នៃមាត្រា២ នៃក្រមព្រហ្មទណ្ឌច្បាប់បញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស។

### ២.២.១. និយមន័យនីតិបុគ្គល

នីតិបុគ្គល គឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្តហើយជាម្ចាស់ ឬប្រធាននៃសិទ្ធ និងកាតព្វកិច្ច។[41] នីតិបុគ្គលគឺត្រូវបានបង្កើតឡើងដោយច្បាប់ ហើយវាជាបុគ្គលអរូបិយ៍ ដែលមានន័យថានីតិបុគ្គលគឺមិនមែនជាមនុស្សទេ តែវាជាក្រុមហ៊ុន សមាគម សំដៅដល់អង្គការជាដើម។ល។ ជាគោលការណ៍ មិនថានីតិបុគ្គល ឬរូបវន្តបុគ្គលនោះទេ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌប៉ុន្តែជាលក្ខណៈពិសេសនីតិបុគ្គលដែលជារដ្ឋត្រូវបានអនុញ្ញាតមិនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ហើយគោលការណ៍នេះត្រូវបានចែងក្នុងមាត្រា៤២នៃក្រមព្រហ្មដោយចែងថា៖

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើស ដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ។[42] ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលគឺពុំច្រានចោលនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលចំពោះអំពើដដែលរបស់រូបវន្តបុគ្គលនោះទេ។ អត្ថបទច្បាប់នេះអាចអនុវត្តចំពោះគ្រប់នីតិបុគ្គលទាំងអស់ ទោះជាសញ្ជាតិខ្មែរ ឬសញ្ជាតិបរទេសក្តីឱ្យតែអំពើរបស់នីតិបុគ្គលនោះត្រូវបានហាមឃាត់ និងកំណត់កំណត់ក្នុងច្បាប់កម្ពុជានោះនីតិបុគ្គលនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។

---

[40] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ៤២ កថាខណ្ឌទី ២ ។

[41] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, លេខរៀងទី ៧១ ។

[42] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ៤២ កថាខណ្ឌទី ២ ។

នៅក្នុងក្របខ័ណ្ឌនៃការដាក់ឱ្យអនុវត្តនូវការទទួលខុសត្រូវព្រហ្មទណ្ឌ អត្ថបទច្បាប់កំរិតនៃការទទួលខុសត្រូវរបស់នីតិបុគ្គល ឱ្យមកនៅត្រឹមករណីបទល្មើសដែលប្រព្រឹត្តដើម្បីជាប្រយោជន៍របស់នីតិបុគ្គលដោយស្ថាប័ន ឬអ្នកតំណាងរបស់នីតិបុគ្គលនោះប៉ុណ្ណោះ នោះបានសេចក្តីថា នីតិបុគ្គល ទាំងឡាយពុំទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះគ្រប់បទល្មើសទាំងអស់ដែលអាចប្រព្រឹត្តដោយអ្នកដឹកនាំសំរាប់នីតិបុគ្គល។ ដើម្បីឱ្យនីតិបុគ្គលទាំងឡាយអាចទទួលខុសត្រូវព្រហ្មទណ្ឌបានលុះត្រាតែមានចែងក្នុងច្បាប់ជាធរមាន ហើយការប្រព្រឹត្តបទល្មើសគឺសំរាប់ជាប្រយោជន៍នៃនីតិបុគ្គល។ ប្រសិនបើការប្រព្រឹត្តបទល្មើសជាប្រយោជន៍ត្រឹមជាប្រយោជន៍របស់ចារីផ្ទាល់ នោះនីតិបុគ្គលក៏ពុំមានការទទួលខុសត្រូវព្រហ្មទណ្ឌ។ ប៉ុន្តែបើចារីបំរើប្រយោជន៍សំរាប់នីតិបុគ្គល នោះនីតិបុគ្គលក៏និយោជិកនោះមិនអាចទម្លួលអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

### ២.២.២. ប្រភេទនៃមូលទោសដែលអនុវត្តចំពោះនីតិបុគ្គល

ទោសមួយចំនួនអាចអនុវត្តបានចំពោះនីតិបុគ្គលដូចជាទោសពិន័យជាប្រាក់ក្នុងនាមជាមូលទោស ឬការដកហូតសិទ្ធិសេរីភាពក្នុងនាមជាទោសបន្ថែម។ ទោសមួយចំនួនទៀតមិនអាចអនុវត្តចំពោះនីតិបុគ្គលបាននោះទេ ដូចជាទោសដាក់ពន្ធនាគារ ឬទោសការងារសហគមន៍។ នីតិបុគ្គលក៏អាចត្រូវ បានរំលាយដោយតុលាការបាន។ ដូចនេះ យើងឃើញថា ទោសអនុវត្តចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលខុសគ្នាដោយយោងទៅតាមលក្ខណៈពិសេសរបស់នីតិបុគ្គល។

នីតិបុគ្គលទទួលរងនូវទោសពិន័យក្នុងឋានៈជាមូលទោស។[43] ទោសពិន័យក្នុងឋានៈជាមូលទោសនេះមិនមែនមានន័យថា រាល់បទល្មើសដែលចោទប្រកាន់លើនីបុគ្គលជាបទលហុនោះទេ។ បទល្មើសប្រព្រឹត្តដើម្បីជាប្រយោជន៍របស់នីតិបុគ្គល ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ គឺអាស្រ័យទៅតាមទម្ងន់នៃបទល្មើសនីមួយៗដែលច្បាប់តម្រូវឱ្យនីតិបុគ្គលទទួលខុសត្រូវ បើទោះបីជាទោសដែលនីតិបុគ្គលត្រូវទទួលរងខុសគ្នាអំពីទោសដែលរូបវន្តបុគ្គលត្រូវទទួលរងក៏ដោយ។

### ២.២.៣ ការអនុវត្តមូលទោសចំពោះនីតិបុគ្គលជារដ្ឋ

នីតិបុគ្គលជារដ្ឋ ឬអាចហៅម្យ៉ាងទៀតបានថា នីតិបុគ្គលសាធារណៈ គឺជាក្រុមមនុស្សដែលច្បាប់បានអនុញ្ញាតឱ្យធ្វើសកម្មភាពដូចជាបុគ្គល ដើម្បីជាផលប្រយោជន៍សាធារណៈ។[44] នីតិបុគ្គលជារដ្ឋ ឬនីតិបុគ្គលសាធារណៈ គឺជាស្ថានប័នដែលត្រូវបានបង្កើតឡើង និងគ្រប់គ្រងដោយច្បាប់សាធារណៈដែលមានសិទ្ធិអំណាចក្នុង

[43] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៦៧ ។

[44] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, លេខរៀងទី ៤៦ ។

ការអនុវត្តកិច្ចការរដ្ឋបាល។[45] នីតិបុគ្គលជារដ្ឋ ឬនីតិបុគ្គលសាធារណៈ មានដូចជា រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) និងគ្រឹះស្ថានសាធារណៈ (គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាល និងឧស្សាហកម្ម ពាណិជ្ជកម្ម)។

ចំពោះ រដ្ឋ គឺជានីតិបុគ្គលនៃនីតិសាធារណៈត្រូវបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដូចនេះរដ្ឋមិនទទួលខុសត្រូវព្រហ្មទណ្ឌដែរ។ ដោយហេតុថា ច្បាប់ព្រហ្មទណ្ឌមិនអាចចែងដើម្បីរំលាយ រដ្ឋ ចោលបានឡើយ ដោយសាររដ្ឋជាអ្នកគ្រប់គ្រងសង្គម ដូចនេះរដ្ឋត្រូវតែបង្កើតច្បាប់ព្រហ្មទណ្ឌ ដើម្បីដាក់ទោសទៅលើសមាជិកសង្គមទាំងឡាយណាដែលប្រព្រឹត្តបទល្មើស។

ដូចនេះ រដ្ឋដែលជានីតិបុគ្គលនៃនីតិបុគ្គលជារដ្ឋ ឬនីតិបុគ្គលសាធារណៈ មិនត្រូវទទួលទោសព្រហ្មទណ្ឌឡើយ ដែលនាំឱ្យរដ្ឋក៏មិនអាចត្រូវបានប្រកាសទោស ឬអនុវត្តទោសដែលមានទាំងមូលទោស និងទាំងទោសបន្ថែមបានឡើយ។

ប៉ុន្តែ ករណីជាសមូហភាពដែនដី អាចទទួលខុសត្រូវព្រហ្មទណ្ឌតែក្នុងករណីដែលសមូហភាពដែនដីនោះអាចជាកម្មវត្ថុនៃការធ្វើប្រតិភូកម្មនៃសេវាសាធារណៈ។ ដូចនេះនីតិបុគ្គលនៃនីតិសាធារណៈ លើកលែងតែរដ្ឋចេញ នីតិបុគ្គលនៃនីតិសាធារណៈដែលធ្វើសកម្មភាពដូចគ្នា ឬស្រដៀងគ្នានឹងសកម្មភាពរបស់នីតិបុគ្គលនៃនីតិបុគ្គលឯកជន ដែលមានដូចជា គ្រឹះស្ថានសាធារណៈ (EPIC , EPA) ក្រុមហ៊ុនរដ្ឋ សមូហភាពដែនដី ហើយធ្វើសកម្មភាពក្នុងនាមជាអ្នកគ្រប់គ្រងប្រយោជន៍របស់សមូហភាពដោយអាចធ្វើប្រតិភូកម្មនៃអំណាច ឬជាអ្នកធានាដោយខ្លួនឯងត្រូវទទួលទោសព្រហ្មទណ្ឌ ដែលនាំឱ្យនីតិបុគ្គលនៃនីតិសាធារណៈក៏អាចត្រូវបានប្រកាសទោស ឬអនុវត្តទោសដែលមានទាំងមូលទោស និងទាំងទោសបន្ថែមបានដូចទៅនឹងនីតិបុគ្គលឯកជនដែរ។[46]

### ២.២.៤. ការអនុវត្តមូលទោសចំពោះនីតិបុគ្គលឯកជន

នីតិបុគ្គលនៃឯកជន ឬនីតិបុគ្គលដែលមិនមែនជារដ្ឋ គឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិនិងកាតព្វកិច្ច និងស្ថិតនៅក្រោមវិធានទាំងឡាយដែលគ្រប់គ្រងទំនាក់ទំនងគតិយុត្តរវាង បុគ្គលឯកជន និងបុគ្គលឯកជន ហើយមិនស្ថិតនៅក្រោមនីតិសាធារណៈទេ។[47] ដូចនេះក្រៅពីរដ្ឋ នីតិបុគ្គលឯកជនមានដូចជា អង្គការ ក្រុមហ៊ុន សមាគមន៍ សហជីបរោងចក្រ។ល។ ដែលច្បាប់កំណត់ថា ជាប្រធាននៃបទល្មើសនៅក្នុងសង្គម ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសព្រហ្មទណ្ឌ។

[45] សទ្ធានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ២០០៨ ។

[46] ចក សម្បត្តិ,ការផ្សាយរបស់ក្រុមត្រាជូ"ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនិងរបបនៃទោសដែលត្រូវអនុវត្ត",២០១៥,៣-៤ ។

[47] ទីស្តីការគណៈរដ្ឋមន្ត្រី, សទ្ធានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី, ២០០៧, លេខរៀង៧១ និង ៧៦ ។

យោងតាមមាត្រា១៦៧ នៃក្រមព្រហ្មទណ្ឌ ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលដែលមានទោសពិន័យជាប្រាក់ដែលស្ថិតនៅក្នុងជាមូលទោស។ បន្ថែមពីនេះ ក៏មានទោសបន្ថែមសម្រាប់អនុវត្តចំពោះនីតិបុគ្គលដែលមានរៀបរាប់ក្នុងមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌ។

ឧទាហរណ៍ មាត្រា២៧៣ នៃក្រមព្រហ្មទណ្ឌ នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តិក្នុងមាត្រា២៦៥ (បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ ឬសេវា) និងមាត្រា២៦៩ (បទបណ្តេញចេញ ឬដកហូតដោយមូលហេតុនៃការរើសអើង)។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀលទៅ ១០.០០០.០០០(ដប់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន។

# ជំពូកទី៣
# វិធាននៃការអនុវត្តទោស
# និងមូលហេតុគតិយុត្តផ្សេងៗដែលនាំ
# ឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស

# ជំពូកទី៣

# វិធាននៃការអនុវត្តទោស និងមូលហេតុគតិយុត្តផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស

វិធានការឯកត្តកម្មនៃទោស អនុញ្ញាតឱ្យចៅក្រមសម្រុះសម្រួលនូវភាពចាំបាច់នៃការបង្ក្រាបដោយការប្រកាសទោស ជាមួយនឹងការសម្របដ៏ចាំបាច់នៃទោសនេះទៅនឹងអំពើល្មើស ជាពិសេស សម្របទៅនឹងបុគ្គលិកលក្ខណៈរបស់ចារី។ ចៅក្រមអាចចាត់វិធានការមួយចំនួន ដើម្បីកំណត់ទោសដែលត្រូវផ្តន្ទាទោសលើចារីក្នុងលក្ខខណ្ឌច្បាស់លាស់កំណត់ដោយច្បាប់ដែលអាចប្រើប្រាស់ កាលណាយល់ឃើញថាមានប្រយោជន៍ដោយពុំមានជាប់កាតព្វកិច្ចអ្វីឡើយ។[48]

វិធានការរបស់ចៅក្រមក្នុងការប្រកាសទោសលើចារីដើម្បីឱ្យអនុវត្តទោសរបស់ខ្លួន (**៣.១**) និងមានមូលហេតុផ្សេងទៀតដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តទោស (**៣.២**) ជាពិសេសក្នុងការអនុវត្តទោសនេះ។

## ៣.១. វិធាននៃការអនុវត្តទោសដែលនាំឱ្យមានការប៉ះពាលដល់ការអនុវត្តមូលទោស

ចៅក្រមអាចប្រើប្រាស់នូវជម្រើសដែលជាវិធានសំរាប់ការអនុវត្តទោសរួមមាន ការព្យួរទោស(**៣.១.១**) ការផ្អាកការប្រកាសទោស(**៣.១.២**) ទោសពាក់កណ្តាលសេរីភាព(**៣.១.៣**) និងការបែងចែកទោសជាប្រភាគ(**៣.១.៤**)។

### ៣.១.១. ការព្យួរទោស

ការព្យួរទោស គឺជាលើកចោលដោយមានលក្ខខណ្ឌនូវការអនុវត្តមូលទោស ដែលបានប្រកាសដោយតុលាការ។ បើផ្អែកតាមក្រមព្រហ្មទណ្ឌបានកំណត់ធ្វើការបែងចែកការព្យួរទោសជាពីរប្រភេទរួមមាន ការព្យួរទោសធម្មតា (**៣.១.១.១**) និងការព្យួរទោសសាកល្បង (**៣.១.១.២**)។

#### ៣.១.១.១ ការព្យួរទោសធម្មតា[49]

ការព្យួរទោសធម្មតា មិនបានតម្រូវឱ្យចារីត្រូវតែគោរពនូវកាតព្វកិច្ចពិសេសណាមួយទេ លើកលែងតែកាតព្វកិច្ចដែលបានហាមមិនឱ្យប្រព្រឹត្តបទល្មើសណាមួយក្នុងរយៈពេលសាកល្បង។ ការព្យួរទោស គឺជាវិធានការមួយដែលតុលាការអាចយកទៅអនុវត្តចំពោះជនជាប់ចោទណាម្នាក់បាន ពោលគឺ តុលាការជាអ្នកសម្រេចដោយប្រុងប្រយ័ត្ន ថាគួរអនុញ្ញាតឱ្យព្យួរទោស ឬមិនគួរយល់ព្រមឱ្យព្យួរទោស។ ប៉ុន្តែ ទន្ទឹមគ្នានឹងការប្រើប្រាស់នូវសិទ្ធិនេះ តុលាការក៏ត្រូវតែពិនិត្យពិច័យទៅលើលក្ខខណ្ឌនានាដែលច្បាប់បានកំណត់ឱ្យប្រាកដប្រជា និងច្បាស់លាស់។

[48] សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ, មេរៀននីតិព្រហ្មទណ្ឌ, អត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧, ៨៥ ។
[49] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ៤០៤-៤១៣ ។

ម្យ៉ាងវិញទៀត ការព្យួរទោសធម្មតាដែលអនុលោមតាមក្រមព្រហ្មទណ្ឌគឺខុសប្លែកពីការព្យួរទោសដែលមានចែង និងកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌមុនៗ រួមមាន ច្បាប់ព្រហ្មទណ្ឌអន្តរកាល និងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ យ៉ាងណាមិញ ក្រមព្រហ្មទណ្ឌបានកំណត់អំពីលក្ខខណ្ឌដែលត្រូវតែគោរព ដើម្បីអនុញ្ញាតឱ្យមានការប្រកាសការព្យួរទោសធម្មតា ដែលនឹងមានអានុភាពលើកចោលនូវការអនុវត្តទោស។

ដើម្បីសម្រេចអនុញ្ញាតយល់ព្រមឱ្យមានការព្យួរទោសធម្មតា តុលាការត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់អំពីទោសដែលត្រូវព្យួរ និងអានុភាពនៃការព្យួរទោសធម្មតា។ ជាទូទៅ ការព្យួរទោសធម្មតាមិនអាចអនុវត្តទៅលើទោសគ្រប់ប្រភេទបានឡើយ។ សម្រាប់បទឧក្រិដ្ឋ ឬបទមជ្ឈិម គឺមានតែទោសដែលប្រកាសផ្តន្ទាទោសជនជាប់ចោទឱ្យជាប់ពន្ធនាគារតិចជាង ឬស្មើនឹង ៥ (ប្រាំ)ឆ្នាំ ឬក៏ទោសដែលប្រកាសជាទោសពិន័យតែប៉ុណ្ណោះ ដែលអាចត្រូវបានអនុញ្ញាតយល់ព្រមឱ្យព្យួរទោសធម្មតាបាន។ ជាពិសេសទៅទៀត គួរតែកត់សម្គាល់ថា នៅក្នុងការកំណត់ពីទោសដែលអាចព្យួរបាន ក្រមព្រហ្មទណ្ឌតម្រូវឱ្យយក ទោសដែលប្រកាស មកធ្វើជាមូលដ្ឋានសម្រាប់កំណត់។ ដូច្នេះ ប្រសិនបើតុលាការបានសម្រេចប្រកាសទោសដាក់ពន្ធនាគារចំនួនលើសពី ៥ (ប្រាំ)ឆ្នាំ ដោយសារតែជនចោទបានប្រព្រឹត្តបទមជ្ឈិមណាមួយនោះ ទោសនេះមិនអាចអនុវត្តការព្យួរទោសបានឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើតុលាការបានសម្រេចប្រកាសដាក់ទោសពន្ធនាគារចំនួន ៤ (បួន)ឆ្នាំ ពីបទមជ្ឈិម ទោសនោះអាចឱ្យព្យួរទោសធម្មតាបាន។

ចំពោះបទលហុវិញ ក្រមព្រហ្មទណ្ឌមិនបានបញ្ជាក់កំណត់អំពីចិរវេលានៃទោសដែលប្រកាស ដែលជាលក្ខខណ្ឌនៃការអនុញ្ញាតឱ្យមានការព្យួរទោសធម្មតានោះឡើយ គឺទោសដែលត្រូវបានប្រកាសផ្តន្ទាទោសទាំងអស់ចំពោះបទលហុ អាចជាកម្មវត្ថុនៃការព្យួរទោសធម្មតាបាន ពោលគឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ចំពោះបទលហុ គឺសុទ្ធសឹងតែអាចអនុញ្ញាតឱ្យព្យួរទោសធម្មតាបានទាំងអស់។[50]

ចំពោះទោសដែលត្រូវអនុវត្តលើនីតិបុគ្គលក៏អាចជាកម្មវត្ថុនៃការព្យួរទោសធម្មតាបានដែរ។ ទោះបីមិនមានបទបញ្ញត្តិដ៏ជាក់លាក់ណាមួយនៃក្រមព្រហ្មទណ្ឌ ដែលអនុញ្ញាតឱ្យមានការព្យួរទោសដែលត្រូវអនុវត្តលើនីតិបុគ្គល ក៏តាមការបកស្រាយលើមាត្រា ១០៤ និងមាត្រា ១៨២ នៃក្រមព្រហ្មទណ្ឌ អាចឱ្យមានការយល់ឃើញថា មូលទោសយកទៅអនុវត្តលើនីតិបុគ្គល អាចត្រូវបានអនុញ្ញាតឱ្យមានការព្យួរទោសធម្មតាបាន។ យោងតាមមាត្រា១៨២ នៃក្រមព្រហ្មទណ្ឌចែងថា បទបញ្ញត្តិនៃមាតិកាទី១ មាតិកាទី២ និងមាតិកាទី៣ នៃគន្ថីទី១ នៃក្រមនេះដែលទាក់ទងនឹងរូបវន្តបុគ្គលត្រូវអនុវត្តទៅលើនីតិបុគ្គល ក្នុងកម្រិតដែលបទបញ្ញត្តិនេះមិនផ្ទុយជាមួយនឹងបទបញ្ញត្តិនៃជំពូកនេះ។ រីឯខ្លឹមសារនៃមាត្រា១០៤ នៃក្រមព្រហ្មទណ្ឌ អនុញ្ញាតឱ្យតុលាការបង្គាប់ឱ្យព្យួរការអនុ

[50] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១១៣ ។

វត្ថុមូលទោស។ មូលទោសដែលត្រូវទទួលរងដោយនីតិបុគ្គលគឺជាទោសពិន័យជាប្រាក់។[51] ដូច្នេះ តុលាការអាចបង្គាប់ឱ្យមានការព្យួរទោសពិន័យដែលត្រូវប្រកាសសម្រាប់នីតិបុគ្គលបាន កាលលក្ខខណ្ឌនៃការព្យួរទោសត្រូវបានបំពេញគ្រប់គ្រាន់រួច។

## ក.លក្ខខណ្ឌទាក់ទងនឹងប្រវត្តិនៃការផ្តន្ទាទោសរបស់ជនជាប់ចោទ

ការព្យួរទោសធម្មតា មិនត្រូវបានអនុញ្ញាតផ្តល់ឱ្យជនល្មើសដែលបានប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀតឡើយ។ ហេតុដូច្នេះហើយទើបក្រមព្រហ្មទណ្ឌបានផ្តល់សារៈសំខាន់ដល់ប្រវត្តិនៃការផ្តន្ទាទោសលើជនជាប់ចោទ។ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម តុលាការអាចសម្រេចផ្តល់ការព្យួរទោសធម្មតាបាន លុះត្រាតែជនជាប់ចោទមិនទាន់បានទទួលរងនូវការផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារ ក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំ មុនពេលបទល្មើសបានកើតឡើង។[52] ចំណែកឯបទលហុ តុលាការអាចសម្រេចយល់ព្រមឱ្យមានការព្យួរទោសធម្មតាបាន ល្គឹកណាតែជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសជាស្ថានឱ្យជាប់ពន្ធនាគារ ក្នុងរយៈពេល ១ (មួយ)ឆ្នាំ មុនពេលបទល្មើសបានកើតឡើង។[53]

ឧទាហរណ៍ នៅដើមឆ្នាំ២០០៦ មានជនជាប់ចោទម្នាក់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចំនួន ១ (មួយ)ឆ្នាំ ពីបទលួច។ បន្ទាប់មកទៀត ការផ្តន្ទាទោសនេះក៏បានចូលជាស្ថាពរនៅចុងឆ្នាំ ២០០៦ ។ លើសពីនេះទៅទៀត នៅឆ្នាំ២០១០ ជនជាប់ចោទដដែលខាងលើត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាព បទរំលោភលើទំនុកចិត្ត ជាបន្ថែមទៀត។ ក្នុងករណីនេះ ជនជាប់មិនអាចទទួលបាននូវអត្ថប្រយោជន៍ពីការព្យួរទោសធម្មតាបានឡើយ ពីព្រោះថា ជនជាប់ចោទធ្លាប់មានប្រវត្តិត្រូវបានតុលាការផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៤ (បួន)ឆ្នាំ មុនពេលដែល បទរំលោភលើទំនុកចិត្ត បានកើតឡើង។

## ខ. អានុភាពនៃការព្យួរទោសធម្មតា

ការព្យួរទោសធម្មតា មានន័យស្មើនឹងការលើកលែងមិនឱ្យអនុវត្តទោសមួយផ្នែក ឬទាំងស្រុង។ ជនជាប់ចោទអាចទទួលបានការលើកលែងមិនឱ្យអនុវត្តទោសនេះភ្លាមតែម្តង ក៏ប៉ុន្តែការលើកលែងមិនឱ្យអនុវត្តទោសនេះបាន គឺត្រូវមានលក្ខខណ្ឌ ដោយទណ្ឌិតដាច់ខាតមិនត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយផ្សេងទៀតឡើយនៅក្នុងរយៈពេលនៃការព្យួរទោស។

ទន្ទឹមនឹងនេះ ជនជាប់ចោទដែលទទួលបាននូវការព្យួរទោសធម្មតា និងត្រូវតម្រូវឱ្យតុលាការដោះលែងភ្លាមពីពន្ធនាគារ ប្រសិនបើជនជាប់ត្រូវបានសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នមុនពេលប្រកាសទោស។ ទោះបីជា

[51] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៦៧ ។

[52] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១០៦ ។

[53] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១១២ ។

យ៉ាងណាក្តី ទោសនៅតែមានអត្ថិភាពជាធម្មតា មានន័យថា ទោសដែលត្រូវព្យួរនឹងត្រូវបានកត់ត្រាចូលក្នុងព្រឹត្តិបត្រលេខ១ នៃបញ្ជីថ្កោលទោស[54] ហើយទោសនេះត្រូវយកមកពិចារណាសម្រាប់ការកំណត់អំពីភាពមិនរាងចោលផងដែរ។

ការព្យួរការអនុវត្តទោសតាមរយៈការព្យួរទោសធម្មតា គឺជាការព្យួរទោសដោយមានលក្ខខណ្ឌ ពោលគឺថាទណ្ឌិតមិនត្រូវឱ្យមានការទទួលរងនូវការផ្តន្ទាទោសជាថ្មីទៀតទេនៅរយៈពេលកំពុងសាកល្បង។ ចំណែកឯរយៈពេលសាកល្បងនៃការព្យួរទោសធម្មតាគឺ ៥ (ប្រាំ)ឆ្នាំ សម្រាប់បទឧក្រិដ្ឋ ឬបទមជ្ឈិម និងមានរយៈពេល ១ (មួយ) ឆ្នាំ សម្រាប់បទលហុ។[55] ចំពោះរយៈពេលសាកល្បងនេះត្រូវចាប់ផ្តើមគិតពីពេលដែលសេចក្តីសម្រេចផ្តន្ទាទោសបានចូលជាស្ថាពរ។

យ៉ាងណាមិញ ប្រសិនបើរយៈពេល ៥ (ប្រាំ)ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយមានការព្យួរទោសធម្មតា ហើយបើគ្មានការផ្តន្ទាទោសដោយផ្តន្ទាទោសជាថ្មីមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិមចូលជាស្ថាពរនោះទេ ការផ្តន្ទាទោសដោយមានការព្យួរទោសនេះ ត្រូវតែចាត់ទុកថាជាអសារបង់ទាំងអស់។ បន្ថែមពីលើនេះទៅទៀត កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកណាមួយនៃទោសនោះ ការផ្តន្ទាទោសក៏ត្រូវចាត់ទុកជាអសារបង់ដែរ បានសេចក្តីថាទោសដែលតុលាការបានសម្រេចផ្តន្ទាទោស មិនអាចយកមកអនុវត្តបានទៀតឡើយ។ មួយវិញទៀត ប្រសិនបើទណ្ឌិតត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង ក៏ប៉ុន្តែមានតែទោសដាក់ពន្ធនាគារប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យព្យួរទោស ដូច្នេះ ទណ្ឌិតនៅតែមានកាតព្វកិច្ចត្រូវបង់ប្រាក់ពិន័យតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការដដែល។ ដោយឡែក ប្រសិនបើតុលាការសម្រេចឱ្យព្យួរទោសពិន័យតែមួយផ្នែក មានន័យថា ទណ្ឌិតនៅតែមានកាតព្វកិច្ចត្រូវបង់ប្រាក់ពិន័យមួយផ្នែកផ្សេងទៀត ដែលមិនត្រូវបានព្យួរទោស។

ផ្ទុយមកវិញ ក្នុងករណីដែលតុលាការបានសម្រេចឱ្យមានការផ្តន្ទាទោសថ្មីពីបទឧក្រិដ្ឋ ឬបទមជ្ឈិមមួយទៀតនៅក្នុងរយៈពេលសាកល្បង ហើយការផ្តន្ទាទោសថ្មីនេះបានចូលជាស្ថាពរ ការព្យួរទោសនឹងត្រូវដកហូតមកវិញ មានន័យថា ទណ្ឌិតត្រូវតែអនុវត្តទោសទីមួយដែលតុលាការបានសម្រេចព្យួរទោសកន្លងមកផង និងទោសទីពីរដែលតុលាការបានសម្រេចផ្តន្ទាទោសសម្រាប់បទល្មើសថ្មីទៀត ដោយមិនមានលទ្ធភាពនឹងអនុវត្តនូវគោលការណ៍ស្រូបទោសបានឡើយ។[56]

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥៤៧

[55] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១១១ ដល់ មាត្រា ១១៦ ។

[56] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១០៩ កថាខណ្ឌទី ២ ។

ឧទាហរណ៍ ជនម្នាក់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាក្នុងរយៈពេល ១ (មួយ)ឆ្នាំ ពី បទឆបោក ដោយទោសនេះត្រូវបានតុលាការសម្រេចឱ្យព្យួរទោសធម្មតា។ លុះពីរឆ្នាំក្រោយមក ជនដដែលនេះបានប្រព្រឹត្តបទល្មើសថ្មីមួយទៀត ហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលចំនួន ៣ (បី) ឆ្នាំ។ ឧបមាថា ការផ្តន្ទាទោសបានចូលជាស្ថាពររួចហើយនៅពេលនោះ ទណ្ឌិតត្រូវតែអនុវត្តទោសដោយបូកបញ្ចូលគ្នាជាចាំបាច់ ពោលគឺ ៣ (បី)ឆ្នាំ ទោសដែលត្រូវបានផ្តន្ទាទោសសម្រាប់បទល្មើសថ្មី បូកនឹង ១(មួយ)ឆ្នាំ ទោសដែលត្រូវបានព្យួរកាលពីលើមុន។ ដូច្នេះ សរុបមកឃើញថា ជនល្មើសត្រូវតែអនុវត្តទោសដាក់ពន្ធនាគាររយៈពេលចំនួន ៤(បួន)ឆ្នាំ។

ប៉ុន្តែជាបដិបញ្ញត្តិទៅនឹងវិធានខាងលើ ក្រមព្រហ្មទណ្ឌបានផ្តល់លទ្ធភាពទុកឱ្យតុលាការជាអ្នកសម្រេចថាតើគួរតម្រូវឱ្យការផ្តន្ទាទោសបទល្មើសថ្មីនេះ នឹងជម្រុញនាំឱ្យមានការដកហូតមកវិញនូវការព្យួរទោស សម្រាប់បទល្មើសមុន ឬក៏យ៉ាងណា។ ក្នុងករណីដែលតុលាការបានសម្រេចថា ការផ្តន្ទាទោសថ្មី គឺពិតជាមិនតម្រូវឱ្យមានការដកហូតការព្យួរទោសកាលពីលើកមុនទេ ពោលតុលាការត្រូវតែគូសបញ្ជាក់ពីមូលហេតុជាពិសេសនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន។ ដូច្នេះក្នុងករណីបែបនេះ ជនល្មើសនឹងត្រូវអនុវត្តតែទោសដែលនឹងប្រកាសផ្តន្ទាទោសសម្រាប់តែបទល្មើសថ្មីប៉ុណ្ណោះ។

### ៣.១.១.២. ការព្យួរទោសសាកល្បង[57]

ការព្យួរទោសសាកល្បង គឺខុសពីប្លែកពីការព្យួរទោសធម្មតាដោយការព្យួរទោសសាកល្បងមានអានុភាពធ្វើឱ្យទណ្ឌិតត្រូវតែស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងត្រូវតែគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលកំពុងសាកល្បងដែលត្រូវបានកំណត់ចាប់ពីរយៈពេល ១ (មួយ)ឆ្នាំ រហូតដល់ ៣(បី)ឆ្នាំ។[58] មិនតែប៉ុណ្ណោះ ក្នុងរយៈពេលសាកល្បងដែលបានកំណត់សម្រេចដោយតុលាការ ជនជាប់ចោទត្រូវទទួលរងនូវវិធានការត្រួតពិនិត្យមួយចំនួន និងត្រូវតែគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនដែលច្បាប់បានកំណត់រយៈពេលកំពុងសាកល្បងនេះ។

ឃើញថាក៏ដូចជាការព្យួរទោសធម្មតាដែរ ការសម្រេចផ្តល់នូវការព្យួរទោសសាកល្បង ត្រូវតែបំពេញនូវលក្ខខណ្ឌចាំបាច់មួយចំនួន ហើយជាងនេះទៅទៀត នៅក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវតែស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងត្រូវគោរពដោយខានមិនបាននូវកាតព្វកិច្ចដោយឡែកដែលច្បាប់បានកំណត់ ហើយការមិនព្រមគោរពតាមវិធានការដែលបានកំណត់នឹងនាំឱ្យមានការដកហូតមកវិញនូវការព្យួរទោសនោះ។

---

[57] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំ ស៊ីណាត, ២០១២, ៤១៣-៤១៨ ។

[58] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១១៧ ដល់មាត្រា ១២៣ ។

## ក.លក្ខខណ្ឌនៃការព្យួរទោសសាកល្បង

មាត្រា១១៧ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌចែងថា តុលាការអាចសម្រេចព្យួរសាកល្បងនូវទោស ដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ)ខែ ទៅ ៥ (ប្រាំ)ឆ្នាំ។ យោងតាមបទបញ្ញត្តិនៃមាត្រានេះសឱ្យឃើញថា មានតែការផ្តន្ទាទោសដាក់ពន្ធនាគារប៉ុណ្ណោះ ដែលអាចធ្វើជាកម្មវត្ថុនៃការព្យួរទោសសាកល្បងបាន។ ការសម្រេចចែងយ៉ាងដូច្នេះនាំឱ្យមានការសន្និដ្ឋានបានថា នីតិបុគ្គលដែលត្រូវផ្តន្ទាទោសឱ្យបង់ជាប្រាក់ពិន័យ ក្នុងឋានៈជាមូលទោសនឹងមិនអាចទទួលនូវប្រយោជន៍ពីការព្យួរទោសសាកល្បងឡើយ។

យោងតាមមាត្រា ១១៧ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ បានកំណត់ថា ការព្យួរទោសសាកល្បង មានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង។

ចំណែកឯរយៈពេលសាកល្បងវិញ មិនអាចតិចជាងរយៈពេល ១ (មួយ)ឆ្នាំ និងមិនត្រូវលើសពីរយៈពេល ៣ (បី)ឆ្នាំ ឡើយ។ ហេតុនេះតុលាការត្រូវតែកំណត់ពីរយៈពេលសាល្បងឱ្យបានច្បាស់លាស់ នៅក្នុងសេចក្តីសម្រេច។[59] ការព្យួរទោសសាកល្បង អាចធ្វើទៅបានលុះត្រាតែមានការសម្រេចរបស់តុលាការ និងបន្ថែមពីនេះមានតែព្រះរាជអាជ្ញា ដែលជាអ្នកឃ្លាំមើលនូវការអនុវត្តដែលត្រូវបានសម្រេចដោយចៅក្រម។

យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរទោសសាកល្បងនៃទោស ឱ្យបានជាអតិបរមានូវទោស ដែលបានសម្រេចដាក់ពន្ធនាគារ ក្នុងបទល្មើសមជ្ឈឹម។ ដូច្នេះតាមស្មារតីនេះអាចបញ្ជាក់បានថា មានតែចៅក្រមជំនុំជម្រះតែមួយគត់ដែលមាននូវឆន្ទានុសិទ្ធិនៅក្នុងការសម្រេចដាក់ជនម្នាក់ដែលបានប្រព្រឹត្តនូវបទល្មើសឱ្យមកអនុវត្តនូវការព្យួរទោសសាកល្បងនេះ។ បន្ថែមពីនេះ តុលាការត្រូវចេញសម្រង់សាលក្រមស្ពាពរចំនួន ៣ (បី)ច្បាប់។ ដែលមាន ២ (ពីរ)ច្បាប់ប្រគល់ជូនព្រះរាជអាជ្ញាដើម្បីពិនិត្យនូវការអនុវត្ត និង ១ (មួយ)ច្បាប់ទៀតត្រូវប្រគល់ជូនទណ្ឌិតដើម្បីធ្វើការអនុវត្ត។ នៅក្នុងការអនុវត្តនូវការព្យួរទោសសាកល្បង អ្នកដែលមានភារកិច្ចនៅក្នុងការឃ្លាំមើលឱ្យបុគ្គលដែលមានការព្យួរទោសនោះ គឺមានតែព្រះរាជអាជ្ញាប៉ុណ្ណោះ ក៏មានពេលខ្លះគេអាចចាត់តាំងបុគ្គលណាផ្សេងឱ្យបំពេញការងារជំនួសខ្លួនបាន។ ព្រះរាជអាជ្ញាមានតួនាទីនៅក្នុងការអនុវត្តនូវការព្យួរទោសដូចជា[60]៖

១-ត្រូវដឹកនាំសម្របសម្រួល ការអនុវត្តសេចក្តីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ឱ្យមានប្រសិទ្ធិភាព។

---

[59] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១១៨ ។

[60] សារាចរណែនាំលេខ ០២ កយ.សរ/១៤ ស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤។

២- ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬបំពេញកាតព្វកិច្ច ឱ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគប្បីចាត់តាំង ដូចជានគរបាលប៉ុស្ដិ៍រដ្ឋបាល សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្ថាននីតិសម្បទា...។

៣- ត្រូវបង្គាប់ណែនាំដល់ទណ្ឌិត ឱ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឱ្យតាមដាន។

៤- ត្រូវប្រគល់សម្រង់សាលក្រម ឬសម្រង់សាលដីកាស្ថាពរដល់បុគ្គលដែលត្រូវបានចាត់តាំងឱ្យតាមដានទណ្ឌិត និងធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥- ក្នុងករណីចាំបាច់ ត្រូវបង្គាប់អង្គភាពនគរបាលយុត្តិធម៌ ឱ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងត្រូវធ្វើរបាយការណ៍តាមការកំណត់ ពីការកត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនទៅព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ ឬវិធានការ។

### ខ. វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែករបស់ឡែករបស់ទណ្ឌិត[61]

ចំពោះវិធានការត្រួតពិនិត្យវិញ គឺជាវិធានការដែលតម្រូវទៅលើទណ្ឌិតដោយស្វ័យប្រវត្តិ នៅគ្រប់ករណីដែលតុលាការបានសម្រេចអនុញ្ញាតឱ្យមានការព្យួរទោសសាកល្បង។ ក្នុងរយៈពេលសាកល្បងនេះ ទណ្ឌិតត្រូវគោរពទៅតាមវិធានការត្រួតពិនិត្យ ដែលកំណត់ដោយតុលាការៈ

- ត្រូវចូលខ្លួនទៅតាមដីកាកោះពីព្រះរាជអាជ្ញា (ឬតំណាងព្រះរាជអាជ្ញា)
- ត្រូវទទួលការមកត្រួតពិនិត្យមើលរបស់ព្រះរាជអាជ្ញា
- ត្រូវផ្ដល់ឯកសារ ទៅតាមការបង្គាប់របស់ព្រះរាជអាជ្ញា
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្ដូរអាសយដ្ឋាន ឬការផ្លាស់ប្ដូរមុខរបរ
- ត្រូវសុំការអនុញ្ញាតពីព្រះរាជអាជ្ញាមុននឹងធ្វើដំណើរទៅបរទេស

ក្រៅពីវិធានការទាំងអស់នេះ តុលាការអាចកំណត់ឱ្យទណ្ឌិតគោរពទៅតាមកាតព្វកិច្ចមួយចំនួនផ្សេងទៀត នៅក្នុងរយៈពេលសាកល្បង ដូចជា ៖

- ត្រូវបំពេញសកម្មភាពខាងវិជ្ជាជីវៈ
- ត្រូវទៅរៀន ឬទទួលការបណ្ដុះបណ្ដាលខាងវិជ្ជាជីវៈ
- ត្រូវរស់នៅក្នុងកន្លែងណាមួយជាកំណត់
- ត្រូវទទួលឱ្យពេទ្យធ្វើការពិនិត្យ និងព្យាបាល

[61] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១១៩ ដល់មាត្រា ១២១ ។

- មិនត្រូវមានវត្តមាន នៅទីកន្លែងណាមួយ ដែលកំណត់ដោយតុលាការ
- មិនត្រូវធ្វើសកម្មភាពមួយចំនួន ដូចជា សេពគប់បនល្បែង គ្រឿងស្រវឹង កាន់កាប់ ឬយកអាវុធតាមខ្លួន ឬប្រកបអាជីវកម្មណាមួយ ដែលកំណត់ដោយតុលាការ
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ជាពិសេស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ជាដើម។ ករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

### គ.ការដកហូតការព្យួរទោសសាកល្បង[62]

នៅក្នុងរយៈពេលសាកល្បង ១ (មួយ)ឆ្នាំ ទៅ៣ (បី)ឆ្នាំ ប្រសិនបើជនល្មើសមិនគោរពតាមវិធានការត្រួតពិនិត្យ ឬតាមកាតព្វកិច្ច ដែលកំណត់ដោយតុលាការទេ ការព្យួរទោសនឹងត្រូវលើកចេញវិញ ហើយជនល្មើសត្រូវតែអនុវត្តទោស។ ប្រសិនបើជនល្មើសប្រព្រឹត្តបទល្មើសថ្មីណាមួយទៀត ក្នុងរយៈពេលសាកល្បងនេះ ការព្យួរទោសក៏ត្រូវលើកចេញវិញដូចគ្នាដែរ ហើយជនល្មើសត្រូវអនុវត្តទោស សម្រាប់បទល្មើសទាំងពីរ ដូចករណីព្យួរទោសធម្មតាដែរ។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងទាំងមូល ឬមួយផ្នែកបាន។ នៅក្នុងករណីនេះ ទោសត្រូវតែយកមកអនុវត្តទាំងមូលក៏បាន ឬមួយផ្នែកណាមួយក៏បាន។

### ៣.១.២. ការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោស គឺជាការផ្អាកការប្រកាសដោយតុលាការ នូវទោសណាមួយដើម្បីអាចយកទោសនោះមកអនុវត្តបាន។ ក្រោយពីយល់នូវនិយមន័យនៃការប្រទោសរួចហើយ យើងនឹងធ្វើការសិក្សាទាំងស្រុងនូវលក្ខខណ្ឌនៃការផ្អាកការប្រកាសទោសដែលត្រូវបំពេញ[63]៖

- ភាពច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់
- ជនជាប់ចោទមានការធានាក្នុងការបញ្ជូនឱ្យទៅរស់នៅក្នុងសង្គមវិញ
- ជនជាប់ចោទសុំរយៈពេល ដើម្បីជួសជុលការខូតខាត

គួរគូសបញ្ជាក់ថា លក្ខខណ្ឌទាំងបីនេះ ត្រូវបំពេញព្រមគ្នា។ បន្ថែមពីនេះទៅទៀត ការផ្អាកការប្រកាសទោស អាចធ្វើបានចំពោះតែបទមជ្ឈិមតែប៉ុណ្ណោះ គឺមិនអាចធ្វើបានចំពោះបទល្មើសដទៃទៀតឡើយ។ ដូច្នេះ ការផ្អាកការប្រកាសទោសនេះ សន្មតថាមានការប្រកាសជាមុននូវពិរុទ្ធភាព តែតុលាការពុំទាន់បានប្រកាសទោសនៅឡើយ។

---

[62] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១២២ ។

[63] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១២៤ ។

ការផ្អាកការប្រកាសទោសអាចត្រូវបានបង្គាប់ឱ្យធ្វើបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ។ ការផ្អាកការប្រកាសទោសមានអានុភាពរយៈពេល ១ (មួយ)ឆ្នាំ ពោលគឺសេចក្តីសម្រេចពីទោសត្រូវធ្វើឡើងយ៉ាងច្រើនបំផុតគឺត្រឹម ១ (មួយ)ឆ្នាំ ក្រោយពីមានសេចក្តីសម្រេចឱ្យផ្អាក ដោយតុលាការត្រូវកំណត់នៅក្នុងសាលក្រម ឬសាលដីកានូវកាលបរិច្ឆេទដែលត្រូវសម្រេចពីទោស។ កាលណាសវនាការត្រូវបានបើកឡើង តុលាការសម្រេចអំពីទោសនេះ។[64]

នៅក្នុងក្របខ័ណ្ឌនៃរយៈពេលដែលត្រូវបានប្រគល់ឱ្យក្នុងការផ្អាកការប្រកាសទោស តុលាការនឹងត្រូវពិនិត្យលើកិច្ចខិតខំប្រឹងប្រែងរបស់ជនជាប់ចោទ ចាប់ពីសវនាការលើកទីមួយមក ដែលនៅក្នុងរយៈពេលនេះ ការប្រកាសទោសត្រូវបានផ្អាកសិន។ ជាញឹកញាប់ វិធាននេះ ត្រូវបានប្រើប្រាស់ កាលណាចៅក្រមចង់ទុកឱ្យជនជាប់ចោទនូវរយៈពេលមួយ ដូចជាសម្រាប់ ជួសជុលការខូចខាតជាដើម។ ប្រសិនបើនៅក្នុងសវនាការ ការខូចខាតត្រូវបានជួសជុលទាំងស្រុងហើយ ចៅក្រមពិនិត្យលើស្ថានភាពអនុគ្រោះទាំងនេះ ហើយអាចប្រកាសអនុញ្ញាតឱ្យរួចទោស។ ផ្ទុយមកវិញ ប្រសិនបើជនជាប់ចោទពុំបានខិតខំប្រឹងប្រែងទេនោះ ចៅក្រមអាចទាញចេញជាអំណះអំណាង ដើម្បីផ្តន្ទាទោសឱ្យកាន់តែធ្ងន់ធ្ងរជាងនេះ។

### ៣.១.៣ ទោសពាក់កណ្ដាលសេរីភាព

កាលណាតុលាការប្រកាសទោសជាប់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ)ខែ តុលាការសម្រេចថាទោសនឹងត្រូវអនុវត្តក្រោមរបបពាក់កណ្តាលសេរីភាព។ របបនេះអនុញ្ញាតឱ្យទណ្ឌិតអនុវត្តនូវសកម្មភាពវិជ្ជាជីវៈណាមួយ ទទួលនូវការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាល ទទួលនូវការពិនិត្យព្យាបាលជម្ងឺ ឬជួយឧបត្ថម្ភដល់សេចក្តីត្រូវការរបស់គ្រួសារ។[65]

វិធានការឯកត្តកម្មនេះ អនុញ្ញាតឱ្យទណ្ឌិតរក្សាបាននូវកិច្ចការវិជ្ជាជីវៈរបស់ខ្លួន ទំនាក់ទំនងគ្រួសារ ឬទទួលនូវការបង្ហាត់បង្រៀន ឬការពិនិត្យព្យាបាលជម្ងឺ នៅក្រៅគ្រឹះស្ថានពន្ធនាគារ។ ប៉ុន្តែរបបពាក់កណ្តាលសេរីភាពនេះអាចប្រកាសបាន ចំពោះតែទោសពន្ធនាគាររយៈពេលខ្លី មានន័យថាតិចជាង ឬស្មើ នឹង ៦ (ប្រាំ)ខែ។

កាលណាទណ្ឌិត ដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមរបបពាក់កណ្តាលសេរីភាព ទណ្ឌិតនេះត្រូវបានអនុញ្ញាតឱ្យចាកចេញពីគ្រឹះស្ថានពន្ធនាគារ នៅក្នុងរយៈពេលកំណត់[66] មានន័យថា ការអនុវត្តរបបពាក់កណ្តាលសេរីភាពបង្កភាពងាយស្រួលធ្វើឱ្យទណ្ឌិតអាចនៅក្រៅពន្ធនាគារបាន ក្នុងរយៈពេលដែលបានកំណត់ដោយតុលាការ បានសេចក្តីថា តុលាការត្រូវតែកំណត់ឱ្យត្រឹមត្រូវបំផុតពីថ្ងៃម៉ោងដែលអនុញ្ញាតឱ្យទណ្ឌិតអវត្តមានពី

[64] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១២៥ ។

[65] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១២៧ ។

[66] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១២៧ កថាខណ្ឌទី១ ។

ពន្ធនាគារម្តងៗ។ ដូច្នេះ ចាំបាច់រាល់បែបបទទាំងនេះដូចជាម៉ោងជាដើម ត្រូវតែបញ្ជាក់ដោយគ្មានមន្ទិល នៅក្នុងសេចក្តីសម្រេចរបស់តុលាការ។

ចំណុចសំខាន់មួយទៀតនោះគឺ រយៈពេលនៃរបបពាក់កណ្តាលសេរីភាព ត្រូវបញ្ចូលទៅក្នុងរយៈពេលនៃទោសដែលកំពុងតែអនុវត្ត[67] មានន័យថា រយៈពេលដែលទណ្ឌិតនៅក្រៅឃុំនោះ ត្រូវរាប់គិតផងដែរ ទុកដូចជារយៈពេលនៃការអនុវត្តទោស។ ប៉ុន្តែ ប្រសិនបើទណ្ឌិតពុំអនុវត្តកាតព្វកិច្ចទាំងឡាយដែលត្រូវបានដាក់កំហិត ឬប្រព្រឹត្តអំពើមិនសមរម្យ ចៅក្រមអាចរៀបចំរយៈពេលរបបពាក់កណ្តាលសេរីភាព ឬលុបរបបពាក់កណ្តាលសេរីភាពនេះ បានគ្រប់ពេលវេលា តាមការស្នើសុំរបស់ព្រះរាជអាជ្ញា។[68]

ទន្ទឹមនឹងនេះផងដែរ ព្រះរាជអាជ្ញាអាចចេញបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនព្រមវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃពាក់កណ្តាលសេរីភាព។[69] ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចប្តឹងទៅតុលាការឱ្យលុបចោលវិញនូវការអនុវត្តរបបពាក់កណ្តាលសេរីភាពចំពោះទណ្ឌិតនេះបាន។

### ៣.១.៤. ការបែងចែកទោសជាប្រភាគ

ការបែងចែកទោសជាប្រភាគ គឺសំដៅទៅលើការសម្រេចរបស់តុលាការ ដែលបានអនុញ្ញាតឱ្យមានការអនុវត្តទោសជាដំណាក់កាលដាច់ៗពីគ្នា។ ជាបន្ទាប់មកទៀត ប្រភាគនៃទោសនីមួយៗក៏មិនត្រូវមានរយៈពេលតិចជាង ១(មួយ)ខែ ទេ ហើយរយៈពេលអនុវត្តទោសសរុបក៏មិនអាចលើសពី ២ (ពីរ)ឆ្នាំ បានឡើយដោយត្រូវរាប់បញ្ចូលទាំងការផ្អាកទោសផងដែរ។[70] កាលណាចៅក្រមប្រកាសទោសជាប់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ)ឆ្នាំ ចៅក្រមអាចសម្រេចថាទោសនឹងត្រូវអនុវត្តជាប្រភាគ ដោយមានមូលហេតុធ្ងន់ធ្ងរ មានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ វិជ្ជាជីវៈ ឬជាសង្គម។[71] នេះជាវិធានឯកត្តកម្មតុលាការមួយផ្សេងទៀត ដែលតម្រូវឱ្យអនុវត្តទោសជាប់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ)ឆ្នាំ ដោយប្រភាគ។

ឧទាហរណ៍ ទណ្ឌិតនឹងត្រូវឃុំឃាំង ទៅតាមរយៈពេលវិស្សមកាល ដែលជាហេតុអនុញ្ញាតឱ្យទណ្ឌិតរក្សាការងាររបស់ខ្លួនប្រចាំសប្តាហ៍បាន។

បើប្រៀបធៀបទៅនឹងរបបពាក់កណ្តាលសេរីភាព ការបែងចែកទោសជាប្រភាគនេះ មានលក្ខណៈទូលំទូលាយជាង ពីព្រោះ ថាការបែងចែកជាប្រភាគនេះ អាចអនុវត្តបានចំពោះទោសជាប់ពន្ធនាគាររហូតដល់ទៅ ១ ឆ្នាំ ដោយមិនមែនត្រឹមតែ ៦ (ប្រាំមួយ)ខែ ដូចជាពាក់កណ្តាលសេរីភាពនោះទេ។

---

[67] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១២៩ ។

[68] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៣០ កថាខណ្ឌទី ២ ។

[69] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៣១ ។

[70] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៣៣ កថាខណ្ឌទី ១។

[71] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៣២ ។

ការបែងចែកទោសជាប្រភាគ នាំឱ្យទណ្ឌិតទទួលរងទោសតាមរយៈពេលចន្លោះជាច្រើនដោយការដោះលែងឱ្យមានសេរីភាព។ ហេតុនេះ នៅក្នុងសេចក្តីសម្រេចរបស់តុលាការ នឹងមានកំណត់នូវបែបបទនៃការបែងចែកជាប្រភាគ[72] ប៉ុន្តែរយៈពេលសរុបនៃការអនុវត្តទោសដោយគិតទាំងការផ្អាក ពុំអាចលើសពី ២ (ពីរ)ឆ្នាំ ឡើយ។ ទណ្ឌិតត្រូវអនុវត្តដោយនៅក្នុងពន្ធនាគារក្នុងប្រភាគនៃទោស និងក្រៅពន្ធនាគារនៃប្រភាគនៃទោស ហើយអនុវត្តបន្តបន្ទាប់រហូតដល់គ្រប់រយៈពេលនៃការផ្តន្ទាទោសដែលប្រកាសដោយតុលាការ។

ឧទាហរណ៍ ករណីដែលតុលាការប្រកាសទោសដាក់ពន្ធនាគាររយៈពេល ១ (មួយ)ឆ្នាំ ហើយបែងចែកប្រភាគនៃទោសរយៈពេល ១ (មួយ)ខែ ដូចនេះទណ្ឌិតត្រូវនៅក្នុងពន្ធនាគារ ១ (មួយ)ខែ នៅក្រៅពន្ធនាគារ ១ (មួយ)ខែ បន្ទាប់មកក្នុងពន្ធនាគារ ១ (មួយ)ខែ និងក្រៅពន្ធនាគារ ១ (មួយ)ខែជាបន្តទៀត ហើយអនុវត្តរបៀបនេះរហូតដល់គ្រប់រយៈពេលនៃការផ្តន្ទាទោសដាក់ពន្ធនាគារ ១ (មួយ)ឆ្នាំនោះ។ តាមសម្មតិកម្មខាងលើនេះ ទណ្ឌិតត្រូវប្រើពេលវេលា ២ (ពីរ)ឆ្នាំ ដើម្បីអនុវត្តឱ្យចប់សព្វគ្រប់នូវទោសរបស់ខ្លួន។

លើសពីនេះទៅទៀត នៅគ្រប់ពេលវេលាទាំងអស់ តុលាការក៏អាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគតាមបណ្តឹងរបស់ព្រះរាជអាជ្ញាបាន។ [73]ហេតុដូចនេះ ប្រសិនបើទណ្ឌិតដែលបានទទួលប្រយោជន៍ពីរបបនៃការបែងចែកទោសជាប្រភាគ បែរជាមិនព្រមវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតជាថ្មីទៀតបាន។[74]

## ៣.២. មូលហេតុគតិយុត្តផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស

ជាគោលការណ៍ ទោសដែលត្រូវបានប្រកាសដោយតុលាការត្រូវរលត់ទៅវិញ ដោយសាការអនុវត្តទោសបានចប់សព្វគ្រប់។ ប៉ុន្តែ ការសម្រេចសេចក្តីផ្តន្ទាទោសដោយតុលាការ នៅតែរក្សាទុកជាស្លាកស្នាម និងមានអានុភាពគតិយុត្តជានិច្ច ដោយមូលហេតុថា ទណ្ឌកម្មទាំងនោះត្រូវបានកត់ត្រាទុកយ៉ាងច្បាស់លាស់នៅក្នុងបញ្ជីថ្កោលទោសជាដរាប។[75] ក្រៅពីនេះ នៅមានមូលហេតុគតិយុត្តផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស ឬមូលហេតុនៃការរំលត់ទោសដទៃទៀតជាច្រើនដែលនឹងត្រូវយកមកអនុវត្តនោះ គឺ អាជ្ញាយុកាលនៃទោស (**៣.២.១**) ការអនុគ្រោះទោស (**៣.២.២**) ការលើកលែងទោសជាទូទៅ (**៣.២.៣**) មរណភាពរបស់ជនជាប់ចោទ (**៣.២.៤**) និងមូលហេតុផ្សេងទៀតនៃការរំលត់បណ្តឹងអាជ្ញា (**៣.២.៥**)។

---

[72] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៣៣ កថាខណ្ឌទី ២ ។

[73] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៣៤ កថាខណ្ឌទី ១ ។

[74] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៣៥ ។

[75] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ៤៦២ ។

### ៣.២.១ អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោស គឺជាការរំលត់ទោសដែលពុំត្រូវបានដាក់អនុវត្តក្នុងរយៈពេលណាមួយជាកំណត់ ហើយត្រូវគិតចាប់ពីពេលដែលការផ្តន្ទាទោសដោយតុលាការបានចូលជាស្ថាពរ។ ម៉្យាងវិញទៀតវិធានស្តីពីអាជ្ញាយុកាលត្រូវបានបង្កើតឡើង ពីព្រោះថា ការកន្លងផុតទៅនៃពេលវេលាដ៏យូរអង្វែងពេក បានជម្រុញឱ្យលុបចោលនូវអានុភាពដែលបង្កការរំខាននៃបទល្មើសដល់សង្គមជាតិ ហើយក៏បានធ្វើឱ្យគេលែងមានការចងចាំអំពីការផ្តន្ទាទោសតទៅទៀតដែរ និងជាពិសេស គឺបានបង្ហាញឱ្យឃើញពីអសមត្ថភាពរបស់អាជ្ញាធររដ្ឋក្នុងស្វះស្វែងរកទណ្ឌិត ដើម្បីនាំខ្លួនមកអនុវត្តទោស។ ជាងនេះទៅទៀត ក្នុងរយៈពេលនៃអាជ្ញាយុកាលនៃទោស ទណ្ឌិតប្រាកដជាបានប្រព្រឹត្តតែអំពើត្រឹមត្រូវ ពោលគឺទណ្ឌិតបានកែប្រែខ្លួនឯងដោយស្វ័យប្រវត្តិរួចហើយ ហេតុដូច្នេះ មិនមានការចាំបាច់ត្រូវធ្វើការចាប់បង្ខំយកទណ្ឌិតមកអនុវត្តទោសតទៅទៀតនោះឡើយ។[76] ជាទូទៅ អាជ្ញាយុកាលនៃទោសត្រូវយកមកអនុវត្ត (**៣.២.១.១**) កាលបើរយៈពេលណាមួយជាកំណត់កន្លងផុតទៅ (**៣.២.១.២**)។

#### ៣.២.១.១. ដែនអនុវត្តអាជ្ញាយុកាលនៃទោស

ជាទូទៅ ទោសអាចនឹងត្រូវផុតអាជ្ញាយុកាលបាន ដោយមិនចាំបាច់គិតពីប្រភេទនៃបទល្មើសឡើយ។ ក៏ប៉ុន្តែ ច្បាប់អាចបញ្ញត្តិផ្ទុយទៅវិញថា បទល្មើសខ្លះគ្មានអាជ្ញាយុកាលទេ មានន័យថា ពុំមានទាំងអាជ្ញាយុកាលនៃបណ្តឹង និងពុំមានទាំងអាជ្ញាយុកាលនៃទោស។ ជាក់ស្តែង តាមមាត្រា១៤៣ នៃក្រមព្រហ្មទណ្ឌចែងថា ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ។ ខ្លឹមសារនៃមាត្រានេះបានបន្ថែមថា ក្រៅពីបទល្មើសខាងលើច្បាប់ពិសេសក៏អាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោស ចំពោះបទឧក្រិដ្ឋផ្សេងៗទៀតបានដូចគ្នា។

#### ៣.២.១.២. រយៈពេលអាជ្ញាយុកាលនៃទោស

ជាគោលការណ៍ ក្រមព្រហ្មទណ្ឌបានកំណត់រយៈពេលអាជ្ញាយុកាលនៃទោសយ៉ាងច្បាស់ ដោយត្រូវអនុលោមទៅតាមប្រភេទនៃបទល្មើសដែលជាហេតុនាំឱ្យមានការប្រកាសទោស។ ហេតុនេះទោសដែលប្រកាសដែលជាមូលដ្ឋាននៃការកំណត់រយៈពេលអាជ្ញាយុកាលនៃទោសមាន[77]៖

- ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាលចំនួន ២០ (ម្ភៃ)ឆ្នាំ
- ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាលចំនួន ៥ (ប្រាំ)ឆ្នាំ
- ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាលចំនួន ១ (មួយ)ឆ្នាំ។

---

[76] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ៤៦៤ ។

[77] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៤៤ ។

ម្យ៉ាងវិញទៀត រយៈពេលអាជ្ញាយុកាលនៃទោស ត្រូវចាប់ផ្ដើមគិតពីពេលដែលការផ្ដន្ទាទោសបានចូលជាស្ថាពរ ដោយផ្អែកតាមក្រមព្រហ្មទណ្ឌ។

### ៣.២.២ ការអនុគ្រោះទោស

ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬការលើកលែងទោស ដោយអនុលោមតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកលែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះទោសនោះ។[78] មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ បានកំណត់អំពីព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រក្នុងការបន្ធូរបន្ថយទោស និងលើកលែងទោស។

នៅក្នុងចំនុចខាងលើនេះ មានពាក្យចំនួនពីរដើម្បីបកស្រាយ គឺការបន្ធូរបន្ថយទោស និងការលើកលែងទោស។ ការបន្ធូរបន្ថយទោស ជាការកាត់បន្ថយទោសឱ្យសល់រយៈពេលកាន់តែខ្លី និងឆាប់បញ្ចប់ទោសដែលត្រូវអនុវត្ត។ ការលើកលែងទោសមានពីប្រភេទគឺការលើកលែងទោស និងការលើកលែងទោសជាទូទៅ។ ការលើកលែងទោស គឺត្រូវបានព្រះរាជទានលើកលែងទោសពីព្រះមហាក្សត្រ ចំណែកឯ ការលើកលែងទោសជាទូទៅ គឺសំដៅលើការលើកលែងទោសតាមរយៈច្បាប់អនុម័តរបស់សភា។ ខុសពីការបន្ធូរបន្ថយទោស ការលើលែងទោសនឹងបញ្ចប់ការអនុវត្តទោសដែលនៅសល់ ហើយទណ្ឌិតនឹងមានសេរីភាពវិញ។[79]

ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬការលើកលែងទោស ត្រូវសម្រេចធ្វើឡើងដោយព្រះរាជក្រឹត្យ។ លើសពីនេះទៅទៀត ដើម្បីទទួលបានការអនុគ្រោះទោស ទណ្ឌិតត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន ដូចជាកែប្រែអត្តចរិតឱ្យបានល្អ ហើយទទួលទោសក្នុងពន្ធនាគារបានរយៈពេលកំណត់ណាមួយមុននឹងការទទួលបាននូវការអនុគ្រោះទោស។

#### ៣.២.២.១. លក្ខខណ្ឌនៃការអនុគ្រោះទោស

នាពេលបច្ចុប្បន្ននេះ ពាក់ព័ន្ធនឹងការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬការលើកលែងទោស ច្បាប់ស្ដីពីពន្ធនាគារ ឆ្នាំ២០១១ គឺជាឯកសារជាធរមាន និងចម្បងសម្រាប់ជាមូលដ្ឋានផ្លូវច្បាប់លើការបន្ធូរបន្ថយទោស ឬការលើកលែងទោស។

លក្ខខណ្ឌនៃការលើកលែងទោសដែលត្រូវបានចែកមានពីរគឺ លក្ខខណ្ឌទាក់ទិននឹងកិរិយាមារយាទរបស់ទណ្ឌិត (ក) និងរយៈពេលនៃការទទួលរងទោស (ខ) ។

[78] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៤៧ ។

[79] ព្រឹត្តិបត្រមេធាវីលេខ ១៣, មាស បូរ៉ា, ទណ្ឌិត ឌុច និងសិទ្ធិទទួលបានការលើកលែងទោស ឬការបន្ធូរបន្ថយទោស, ខែ មេសា-ឧសភា ឆ្នាំ២០១៧, ៣ ។

### ក. លក្ខខណ្ឌទាក់ទិននឹងកិរិយាមារយាទរបស់ទណ្ឌិត

លក្ខខណ្ឌទាក់ទិននឹងកិរិយាមារយាទរបស់ទណ្ឌិត គឺទណ្ឌិតម្នាក់ៗខិតខំកសាងកែប្រែគំនិតមាយាទក្លាយជាពលរដ្ឋល្អដើម្បីធ្វើសមហរណកម្មបញ្ចូលទៅក្នុងសង្គមជាតិវិញបាននៅពេលអនាគត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំពោះទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែមិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឱ្យខ្លួន សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅ គណៈកម្មការថ្នាក់ជាតិ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំនៃពន្ធនាគារ។[80]

ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាលមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឱ្យទណ្ឌិតនៅពេលណាក៏បាន។[81]

### ខ. លក្ខខណ្ឌទាក់ទិននឹងរយៈពេលនៃការទទួលរងទោស

យោងតាមមាត្រា ៣ នៃក្រឹត្យ ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ និងក្រមនីតិវិធីព្រហ្មទណ្ឌ ការបន្ធូរបន្ថយទោស ឬការលើកលែងទោសអាចអនុញ្ញាតបាន លុះត្រាតែទណ្ឌិតបានអនុវត្តទោសដាក់ពន្ធនាគារសម្រាប់រយៈពេលណាមួយកំណត់ជាមុនសិន។

ចំពោះករណីការបន្ធូបន្ថយទោស ទណ្ឌិតដែលជាប់ទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ទណ្ឌិតត្រូវទទួលរងនូវការអនុវត្តទោសឱ្យបានមួយភាគបីនៃទោសដាក់ពន្ធនាគារជាមុនសិន ទើបអាចទទួលការបន្ធូបន្ថយទោសបាន។ ចំពោះទណ្ឌិតដែលជាប់ទោសដាក់ពន្ធនាគារអស់មួយជីវិត ទណ្ឌិតត្រូវបានទទួលរងនូវការអនុវត្តទោស ៧ (ប្រាំពីរ)ឆ្នាំ ជាមុនសិន ទើបអាចបន្ធូរបន្ថយទោសបាន។ បន្ថែមពីនេះ ជាគោលការណ៍ រយៈពេលនៃការបន្ធូរបន្ថយទោស ត្រូវបានកំណត់ដូចខាងក្រោម៖

- ចំពោះទណ្ឌិតដែលជាប់ទោសដាក់ពន្ធនាគារកំណត់ពី ១ (មួយ)ឆ្នាំ ដល់ ក្រោម ១០ (ដប់)ឆ្នាំ អាចនឹងបន្ថយរយៈពេលដាក់ពន្ធនាគារចំនួន ៦ (ប្រាំមួយ)ខែ។
- ចំពោះទណ្ឌិតដែលជាប់ទោសដាក់ពន្ធនាគារកំណត់ពី ១០ (ដប់)ឆ្នាំ ដល់ ក្រោម ១៥ (ដប់ប្រាំ)ឆ្នាំ អាចនឹងបន្ថយរយៈពេលដាក់ពន្ធនាគារចំនួន ៩ (ប្រាំបួន)ខែ។
- ចំពោះទណ្ឌិតដែលជាប់ទោសដាក់ពន្ធនាគារកំណត់ពី ១៥ (ដប់ប្រាំ)ឆ្នាំ ដល់ ក្រោម ២០ (ម្ភៃ)ឆ្នាំ អាចនឹងបន្ថយរយៈពេលដាក់ពន្ធនាគារចំនួន ១២ (ដប់ពីរ)ខែ។
- ចំពោះទណ្ឌិតដែលជាប់ទោសដាក់ពន្ធនាគារអស់មួយជីវិត អាចនឹងបន្ថយទោសលើកទី ១ មកត្រឹម ២០ (ម្ភៃ)ឆ្នាំ។

[80] ច្បាប់ស្តីពីពន្ធនាគារ, ២០១១, មាត្រា ៧៦ ។
[81] ច្បាប់ស្តីពីពន្ធនាគារ, ២០១១, មាត្រា ៧៧ ។

ទណ្ឌិតអាចទទួលបានការបន្ធូរបន្ថយទោសបានច្រើនដងបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោសទាំងអស់បានពាក់កណ្តាលនៃទោស ដែលតុលាការបានកំណត់ជាមុនសិន។ ទោះជាយ៉ាងណាក្តី ទណ្ឌិតអាចទទួលបានការបន្ធូរទោសតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ។

ចំពោះករណីការលើកលែងទោសវិញ ទណ្ឌិតដែលត្រូវបានសម្រេចឱ្យជាប់ពន្ធនាគារ ក្នុងរយៈពេលកំណត់ណាមួយ ទណ្ឌិតនោះត្រូវតែបានទទួលរងទោស[82]៖

- ចំនួនពាក់កណ្តាលនៃទោស ប្រសិនបើទោសនោះតិចជាង ឬស្មើ ១(មួយ)ឆ្នាំ
- ពីរភាគបីនៃទោសដាក់ពន្ធនាគារជា ក្នុងករណីផ្សេងទៀត ទើបអាចទទួលបាននូវការលើកលែងទោសបាន។

សម្រាប់ទណ្ឌិតដែកត្រូវបានសម្រេចឱ្យជាប់ពន្ធនាគារអស់មួយជីវិតវិញ ទណ្ឌិតនោះត្រូវតែទទួលរងទោសនៅក្នុងពន្ធនាគារចំនួន ២០ (ម្ភៃ)ឆ្នាំ ជាមុនសិន ទើបអាចទទួលនូវការលើកលែងទោសបាន។

### ៣.២.២.២. នីតិវិធីនៃការអនុគ្រោះទោស

ពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោស និងការលើកលែងទោសត្រូវកំណត់ដោយព្រះរាជក្រឹត្យ។[83] ចំពោះនីតិវិធីនៃការអនុគ្រោះ គឺត្រូវធ្វើឡើងដោយគណៈកម្មការមួយដែលបង្កើតឡើងដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត។ គណៈកម្មការនេះត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការជាតិ យ៉ាងយឺតបំផុត ៣០ (សាមសិប)ថ្ងៃ មុនពេលកំណត់នៃពិធីបុណ្យនីមួយៗ។ បន្ទាប់ពីនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅតាមមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន។[84] គណៈកម្មការនេះត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណៈសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោសនិងលើកលែងទោស បញ្ជូនទៅគណៈកម្មការជាតិ យ៉ាងយឺតបំផុត ៣០ (សាមសិប)ថ្ងៃ មុនពេលកំណត់នៃពិធីបុណ្យនីមួយៗ។ ជាចុងបញ្ចប់ រាជរដ្ឋាភិបាលត្រូវរង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ដែលផ្ញើមកពីគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។ ក្រោយពីបានពិនិត្យវាយតម្លៃរួចហើយ គណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីដាក់

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥១៣ ។

[83] ច្បាប់ស្តីពីពន្ធនាគារ, ២០១១, មាត្រា ៧៨ ។

[84] ច្បាប់ស្តីពីពន្ធនាគារ, ២០១១, មាត្រា ៧៤ ។

សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់)ថ្ងៃមុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។[85]

### ៣.២.៣ ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅ ខុសពីកាលលើកលែងទោសដោយជារាជានុសិទ្ធិរបស់ព្រះមហាក្សត្រ ដែលមានចែងក្នុងច្បាប់ ដែលជាទូទៅធ្វើឡើងជារៀងរាល់ឆ្នាំ ក្នុងឱកាសនៃព្រះរាជពិធីបុណ្យជាតិធំៗ។ ការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា លុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ (**៣.២.៣.១**)។[86] ហេតុនេះ ទោសអាចនឹងត្រូវរលត់តាមរយៈការលើកលែងទោសជាទូទៅ ដែលការលើកលែងទោសនេះ សំដៅលើការធ្វើច្បាប់ដែលអនុម័តដោយរដ្ឋសភា សម្រាប់លើកលែងទោស ឬ លុបចោលនូវប្រភេទបទល្មើសណាមួយដែលនាំឱ្យទោសដែលកំពុងអនុវត្តត្រូវរលត់។ បន្ទាប់ពីច្បាប់ស្ដីពីលើកលែងទោសជាទូទៅចូលជាធរមាន ការលើកលែងទោសជាទូទៅត្រូវមានអានុភាពលុបចោលនូវការសម្រេចទាំងស្រុង (**៣.២.៣.១**) ។

#### ៣.២.៣.១. ច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ

ច្បាប់ស្ដីពីការលើកលែងទោសជាទូទៅតែងតែបានកំណត់ពីដែនអនុវត្តច្បាប់នេះ។ យ៉ាងណាមិញ ច្បាប់ស្ដីពីការលើកលែងទោសជាទូទៅអាចត្រូវបានអនុម័ត ដោយសារតែមូលហេតុចាំបាច់ច្រើនយ៉ាងដូចជា ដើម្បីកាត់បន្ថយចំនួនទណ្ឌិតក្នុងពន្ធនាគារច្រើនពេក ឬហេតុការណ៍សំខាន់ផ្សេងៗក្នុងប្រទេស។[87] ជាក់ស្ដែង ច្បាប់ស្ដីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ត្រូវបានរដ្ឋសភាអនុម័ត និងប្រកាសឱ្យប្រើដោយព្រះរាជក្រមនៅឆ្នាំ១៩៩៤ ត្រូវចាត់ទុកថាជាប្រភេទច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ។ ដោយយោងតាមមាត្រា ៥ នៃច្បាប់នេះ បានបញ្ញត្តថា ច្បាប់នេះអនុគ្រោះទុកពេល ៦ (ប្រាំមួយ)ខែ ក្រោយពីចូលជាធរមាន ឱ្យជនជាសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុមកម្ពុជាប្រជាធិបតេយ្យ វិលត្រលប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរចំពោះបទល្មើសដែលខ្លួនប្រព្រឹត្ត។ មានន័យថា ច្បាប់នេះកំណត់យ៉ាងច្បាស់លាស់ពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសដែលត្រូវលើកលែងទោស។ ព្រមជាមួយគ្នានេះ ច្បាប់នេះក៏បានកំណត់លក្ខខណ្ឌឱ្យសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុម កម្ពុជាប្រជាធិបតេយ្យ ចូលមករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ដើម្បីអាចទទួលបាននូវផលប្រយោជន៍ពីការលើលែងទោសជាទូទៅ។

[85] ច្បាប់ស្ដីពីពន្ធនាគារ, ២០១១, មាត្រា ៧៥ ។

[86] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៤៩ ។

[87] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ៤៧៧ ។

### ៣.២.៣.២. អានុភាពនៃការលើកលែងទោសជាទូទៅ

ជាគោលការណ៍ ច្បាប់ស្ដីពីការលើកលែងទោសជាទូទៅត្រូវមានអានុភាពលុបបំបាត់ចោលទាំងស្រុងនូវទណ្ឌកម្មដែលពាក់ព័ន្ធទាំងអស់។ ហេតុដូច្នេះ ការលើកលែងទោសជាទូទៅមានអានុភាពដូចខាងក្រោម៖

-ចំពោះទោសដែលទទួលបាននូវការលើកលែងទោស ហើយមិនទាន់ត្រូវបានវិនិច្ឆ័យដោយតុលាការនៅឡើយ បណ្ដឹងអាជ្ញាត្រូវរលត់ ហើយតុលាការមិនអាចសម្រេចផ្ដន្ទាទោសលើចារីឡើយ។ ជាមួយគ្នានេះប្រសិនបើការលើកលែងទោសធ្វើឡើង ដោយអនុលោមទៅតាមអត្រាទោសដែលប្រកាស តុលាការត្រូវប្រកាសទោសជាមុនសិនទើបអាចដឹងថា តើទោសដែលមានប្រកាសដោយតុលាការនឹងចូលទៅក្នុងអត្រានៃទោសដែលត្រូវលើកលែង ឬយ៉ាងណា។

-ប្រសិនបើមានការផ្ដន្ទាទោសជាស្ថាពរហើយ ក៏ការផ្ដន្ទាទោសទាំងអស់ត្រូវទុកជាឥតបានការ ដោយមិនអាចយកមកអនុវត្តបានឡើយ។[88] មួយវិញទៀត បើទណ្ឌិតកំពុងតែរងទោសដាក់ ពន្ធនាគារ ទណ្ឌិតនឹងត្រូវទទួលបានការដោះលែងឱ្យមានសេរីភាពឡើងវិញភ្លាម។[89]

ពិសេសជាងនេះទៅទៀត ច្បាប់ស្ដីពីលើកលែងទោសជាទូទៅមានលុបចោលទាំងស្រុងនូវការផ្ដន្ទាទោស ហេតុដូច្នេះ តម្រូវឱ្យមានការលុបការផ្ដន្ទាទោសទាំងអស់ចេញពីថ្កោលទោស។ ប៉ុន្តែ ប្រសិនបើទណ្ឌិតបានបង់ប្រាក់ពិន័យរួចហើយ ទណ្ឌិតពុំអាចទាមទារឱ្យសងវិញបានឡើយ។ បន្ថែមពីនេះ ការលើកលែងទោសជាទូទៅមិនមែនជាការបង្កឧបសគ្គក្នុងការទាមទារសំណងជម្ងឺចិត្តពីសំណាក់ជនរងគ្រោះនោះទេ។[90]

ចំពោះការលើកលែងទោសជាទូទៅមានអានុភាពលុបចោលទោសជាប្រតិសកម្ម ទើបមាត្រា ១៥០ នៃក្រមព្រហ្មទណ្ឌបញ្ញត្តថា កាលបើការព្យួរទោសពីមុន ត្រូវបានដកហូតដោយអានុភាពនៃការផ្ដន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅចំពោះទោសខាងក្រោយនេះបង្កើតឡើងវិញនូវផលប្រយោជន៍នៃការព្យួរទោសដែលមានពីមុន។

### ៣.២.៤ មរណភាពរបស់ជនជាប់ទោស[91]

តាមធម្មតាមរណភាពរបស់ជនជាប់ទោសបណ្ដាលឱ្យទោសដែលបានផ្ដន្ទាទោសដោយតុលាការទាំងអស់ មិនអាចយកទៅអនុវត្តបានទេ។ ជាទូទៅ ការរលត់ទោសដោយមូលហេតុមរណភាព គឺទាញចេញពីគោល

[88] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៤៩ កថាខណ្ឌទី ២ ។

[89] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៤៩ កថាខណ្ឌទី ៣ ។

[90] ក្រមព្រហ្មទណ្ឌ, ២០០៩, មាត្រា ១៥១ ។

[91] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ៤៩២-៤៩៤ ។

ការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលបានបញ្ញត្តថា ទោសត្រូវយកមកអនុវត្តតែចំពោះជនប្រព្រឹត្តកំហុសផ្ទាល់ខ្លួនប៉ុណ្ណោះ។

ទោសដែលបានរលត់គឺជាទោសដាក់ពន្ធនាគារ ចំណែកឯទោសពិន័យជាប្រាក់ និងការរឹបអូសផ្សេងៗទៀតនៅតែអាចបន្តអនុវត្តបានជាដដែល ពីព្រោះថាថ្វីត្បិតតែនៅពេលដែលជនជាប់ទោសបានទទួលមរណភាពហើយក៏ដោយ ក៏បេតិកភណ្ឌរបស់គាត់ទាំងទ្រព្យសកម្ម និងទ្រព្យអកម្មត្រូវតែផ្ទេរទៅឱ្យសន្តតិជនរបស់គាត់តាមច្បាប់។ ហេតុនេះសន្តតិជននៅតែជាប់កាតព្វកិច្ចតម្រូវឱ្យបង់ប្រាក់ពិន័យ និងត្រូវតែប្រគល់វត្ថុដែលត្រូវរឹបអូសតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការដោយខានមិនបានជានិច្ច។

### ៣.២.៥ មូលហេតុផ្សេងទៀតនៃការរំលត់បណ្តឹងអាជ្ញា

ក្រៅពីមូលហេតុនៃការរលត់បណ្តឹងអាជ្ញាដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តទោស ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ញត្តិផងដែរ កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរ[92] ដែលមូលហេតុទាំងនោះមាន ការសម្របសម្រួល (**៣.២.៥.១**) និងការដកពាក្យបណ្តឹង (**៣.២.៥.២**)។

#### ៣.២.៥.១. ការសម្របសម្រួលជាមួយរដ្ឋ[93]

ជាគោលការណ៍ ការសម្របសម្រួលមិនអាចធ្វើទៅបានឡើយ ចំពោះបទល្មើសព្រហ្មទណ្ឌ។ ប៉ុន្តែច្បាប់ពិសេសអាចអនុញ្ញាតឱ្យរំលត់បណ្តឹងអាជ្ញាបានផងដែរ។

ឧទាហរណ៍ មាត្រា២៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ បញ្ញត្តថា ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬបទលហុ ការផ្សះផ្សា ឬសម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង។

ប្រសិនបើការសម្របសម្រួលនាំឱ្យមានការរលត់បណ្តឹងអាជ្ញា នោះការសម្របសម្រួលនោះក៏ទាក់ទិននឹងបណ្តឹងរដ្ឋប្បវេណីដែរ។ ហេតុនេះជាធម្មតា មិនចោទជាបញ្ហាអំពីបណ្តឹងរដ្ឋប្បវេណីឡើយ។ ប៉ុន្តែការរលត់បណ្តឹងអាជ្ញាតាមរូបភាពសម្របសម្រួលនេះ ពុំមែនជាមូលហេតុនៃការរលត់បណ្តឹងរដ្ឋប្បវេណីទេ មានន័យថា ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីនៅតែអាចទាមទារសំណងជម្ងឺចិត្តបាន។

#### ៣.២.៥.២. ការដកពាក្យប្តឹង

ការដកពាក្យប្តឹងដោយជនរងគ្រោះ ពុំអាចធ្វើឱ្យអាជ្ញាយុកាលនៃបណ្តឹងអាជ្ញារលត់ទេ។ ប៉ុន្តែចំពោះបទល្មើសមួយចំនួន ការដកបណ្តឹងរបស់ជនរងគ្រោះ នាំឱ្យរលត់បណ្តឹងអាជ្ញាដែរ។ យោងតាមមាត្រា៨ នៃក្រមនីតិ

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៨ ។

[93] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៨ ចំណុចទី១ ។

វិធីព្រហ្មទណ្ឌ ត្រង់ចំណុចទី២ ចាត់ទុកការដកពាក្យប្តឹងជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញា ក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ។

ការចាត់ទុកដូចជាការដកពាក្យបណ្តឹងដោយជនរងគ្រោះដែរ ករណីដែលមានចែងនៅក្នុងមាត្រា ៣៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដែលបញ្ញត្តិថា ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជន ដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬបទលហុ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវធ្វើការចោទប្រកាន់ជនមុខសញ្ញានោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ។[94]

[94] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៨ ចំណុចទី ២ ។

# ជំពូកទី៤
# នីតិវិធីនៃការអនុវត្តសេចក្តីសម្រេច
# តុលាការពាក់ព័ន្ធនឹងមូលទោស

# ជំពូកទី៤
# នីតិវិធីនៃការអនុវត្តសេចក្តីសម្រេចតុលាការពាក់ព័ន្ធនឹងមូលទោស

សេចក្តីសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សារដេញដោល ឬនៅពេលសវនាការលើកក្រោយ។ នៅក្នុងករណីខាងក្រោយនេះ ប្រធានសវនាការជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមាន អំពីថ្ងៃដែលត្រូវប្រកាសសាលក្រម។[95] គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាសាធារណៈ ដោយប្រធានសវនាការអានដោយសម្លេងខ្លាំងៗផ្នែកនៃសេចក្តីសម្រេចរបស់សាលក្រម។

តុលាការអាចសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម។[96] បន្ទាប់ពីនេះ ប្រសិនបើពិនិត្យឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ[97]។ ហេតុដូច្នេះ សេចក្តីសម្រេចរបស់តុលាការដែលត្រូវបានប្រកាសលើជនជាប់ចោទ ត្រូវតែអនុវត្តតាមសេចក្តីសម្រេចនោះ (**៤.១**) និងដោយព្រមទាំងមានការចូលរួមអនុវត្តសេចក្តីសម្រេចរបស់តុលាការពីសំណាក់អាជ្ញាមានសមត្ថកិច្ច (**៤.២**)។

## ៤.១. ការអនុវត្តសេចក្តីសម្រេចតុលាការ

បន្ទាប់ពីសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ ទណ្ឌិតត្រូវអនុវត្ត ឬត្រូវបង្ខំឱ្យអនុវត្តតាមសេចក្តីសម្រេចនោះ។ ចំពោះសេចក្តីសម្រេចចំពោះរឿងក្តីព្រហ្មទណ្ឌ ទណ្ឌិតត្រូវអនុវត្តមូលទោសទៅតាមការប្រកាសរបស់តុលាការ ដែលមាន ការអនុវត្តទោសដាក់ពន្ធនាគារ (**៤.១.១**) និងទោសពិន័យជាប្រាក់ (**៤.១.២**)។

### ៤.១.១. ការអនុវត្តទោសពន្ធនាគារ

តុលាការប្រកាសផ្តន្ទាទោសជនជាប់ចោទតាមបញ្ញប្បត្តិច្បាប់ ក្រោយពីបានពិនិត្យឃើញមានពិរុទ្ធភាពលើជនជាប់ចោទ។ ប្រសិនបើតុលាការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ១(មួយ)ឆ្នាំ យ៉ាងតិច ដោយគ្មានការព្យួរទេ តុលាការតាមសេចក្តីសម្រេច និងដោយតាមសំអាងហេតុ អាចចេញនៅក្នុងសវនាការ ដីកាបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមានដែលកំពុងជាប់ឃុំ (**៤.១.១.១**) និងដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទដែលអវត្តមានដែលកំពុងនៅក្រៅឃុំ (**៤.១.១.២**)។[98]

---

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៣៤៧ ។

[96] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៣៤៨ ។

[97] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៣៥០ កថាខណ្ឌទី ៣ ។

[98] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៣៥៣ កថាខណ្ឌទី ១ ។

### ៤.១.១.១ ការអនុវត្តទោសចំពោះបុគ្គលជាប់ឃុំ

ចំពោះបុគ្គលជាប់ឃុំដែលត្រូវបានចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដែលជនត្រូវហៅថាជាជនត្រូវចោទ ត្រូវជនជាប់ចោទ ជាបុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការ ដើម្បីជំនុំជម្រះតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងទៅកាន់តុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា ឬតាមកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា។

ការឃុំឃាំងពិរុទ្ធជន ត្រូវធ្វើឡើងតាមអំណាចដីការបស់ចៅក្រម បន្ទាប់ពីចៅក្រមធ្វើការជំនុំជម្រះទៅលើជនជាប់ចោទថាពិតជាមានពិរុទ្ធមែន និងត្រូវរង់ចាំមួយរយៈពេលសម្រាប់ការចេញសេចក្តីសម្រេចជាស្ថាពររបស់តុលាការ ឬបញ្ចប់នីតិវិធីផ្លូវបណ្តឹង (បណ្តឹងទាស់ និងបណ្តឹងឧបាស្រ័យ)។ បន្ទាប់តុលាការប្រកាសសេចក្តីសម្រេចរួចមក ពិរុទ្ធជនដែលត្រូវចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួននោះ ត្រូវតែបានគេនាំទៅបង្ហាញខ្លួនក្នុងរយៈពេលខ្លីបំផុតនៅមុខព្រះរាជអាជ្ញា ជាទីកន្លែងចាប់ខ្លួនដែលឱ្យដំណឹងដល់សាមីខ្លួនអំពីដីកានេះ និងធ្វើការឃុំខ្លួន[99]។

ក្រោយពីសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពររួចហើយ ទណ្ឌិតត្រូវបានឃុំខ្លួនក្នុងមណ្ឌលឃុំឃាំងស្របច្បាប់តាមអំណាចសេចក្តីសម្រេចពីតុលាការមានសមត្ថកិច្ច។ ចំពោះការអនុវត្តទោសពន្ធនាគារ គឺត្រូវធ្វើនៅក្នុងពន្ធនាគាររបស់រដ្ឋ។ ទណ្ឌិតដែលឃុំខ្លួនក្នុងពន្ធនាគារ អនុវត្តការឃុំខ្លួននេះរហូតដល់រយៈពេលដែលទោសត្រូវបានបញ្ចប់។ ចំណែកឯថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងនៅក្នុងថិរវេលានៃទោស ដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា។[100]

ទោសដាក់ពន្ធនាគារ ១ (មួយ)ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន)ម៉ោង។ ទោសដាក់ពន្ធនាគារ ១ (មួយ)ខែ ត្រូវគិត ៣០ (សាមសិប)ថ្ងៃ ទោសដាក់ពន្ធនាគារលើស។ ទោសដាក់ពន្ធនាគារលើសពី ១ (មួយ)ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី១ ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត។ ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង៦ ព្រឹក ដល់ម៉ោង ១៨។[101]

[99] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៣៥៣ កថាខណ្ឌទី ៥ ។

[100] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥០៣ ។

[101] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥០២ ។

**៤.១.១.២ ការអនុវត្តទោសចំពោះបុគ្គលក្រៅឃុំ**

កាលណាសាលក្រមត្រូវបានសម្រេចដោយកំបាំងមុខនោះ ពិរុទ្ធជនដែលសម្រេចចិត្តប្ដឹងទាស់ ត្រូវតែចូលបង្ហាញខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត នៅមុខតុលាការដែលបានប្រកាសសាលក្រម។ ពិរុទ្ធជនអាចធ្វើពាក្យសុំនៅក្រៅឃុំ។ តុលាការត្រូវសម្រេចដូចដែលមានចែងក្នុងមាត្រា ៣០៧ (បណ្ដឹងសុំដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទដែលជាប់ឃុំ) ។[102]

ក្នុងករណីដែលពិរុទ្ធជនមិនបង្ហាញខ្លួន និងក្នុងករណីមានសេចក្ដីសម្រេចផ្ដន្ទាទោសដោយតុលាការ គឺជាសេចក្ដីសម្រេចដែលធ្វើឡើងដោយកំបាំងមុខនោះ សេចក្ដីជូនដំណឹងពីសេចក្ដីសម្រេចនេះតាមលក្ខខណ្ឌដែលច្បាប់បានកំណត់នឹងធ្វើឱ្យសេចក្ដីសម្រេចផ្ដន្ទាទោសរបស់តុលាការក្លាយចូលជាស្ថាពរចំពោះ ទណ្ឌិត។[103]

**៤.១.២. ការអនុវត្តទោសពិន័យ**

ទោសពិន័យជាប្រាក់តម្រូវឱ្យទណ្ឌិតត្រូវតែបង់ប្រាក់ពិន័យឬបានកំណត់ដោយតុលាការ។ ដូច្នេះ ដើម្បីធានាឱ្យបាននូវការបង់ប្រាក់ពិន័យ មានវិធានការពីរយ៉ាងដែលអាចយកមកអនុវត្តបានគឺ ការរឹបអូស និងការបង្ខំដល់រូបកាយ។ ស្របជាមួយគ្នានេះដែរ រាល់ការពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិរបស់ទណ្ឌិត បទបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវតែយកមកអនុវត្ត។ ដោយឡែកវិធានការទីពីរនៃការទាមទារប្រាក់ពិន័យ គឺជាការបង្ខំដល់រូបកាយដែលមានចែកក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ម៉្យាងវិញទៀត ការបង្ខំដល់រូបកាយក៏អាចត្រូវយកមកប្រើប្រាស់ ដើម្បីទាមទារប្រាក់ពន្ធនៃនីតិវិធី ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។[104] ការបង្ខំដល់រូបកាយត្រូវយកមកអនុវត្តដោយពេញលក្ខណៈច្បាប់ មានន័យថា តុលាការពុំបាច់ប្រកាសអំពីការបង្ខំដល់រូបកាយនៅក្នុងសេចក្ដីសម្រេចនោះទេ[105] គឺការបង្ខំដល់រូបកាយនឹងត្រូវតែយកមកអនុវត្តដោយស្វ័យប្រវត្តិ (**៤.១.២.២**) ដោយធ្វើការចាប់ផ្ដើមពីការដាស់តឿនឱ្យបង់ប្រាក់ពិន័យជាមុន (**៤.១.២.១**)។

**៤.១.២.១. ការដាស់តឿនឱ្យបង់ប្រាក់ពិន័យ**[106]

ចំពោះករណី ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យទេ អង្គភាពរតនាគារត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា។ រាល់ការមិនបង់ប្រាក់ពិន័យប្រភេទណាក៏ដោយ គឺសុទ្ធសឹងតែអាចចូលជាកម្មវត្ថុនៃការបង្ខំរូបកាយបានទាំងអស់ ទោះបីជាប្រាក់ពិន័យដែលត្រូវបានប្រកាសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ឬពីបទលហុ។

[102] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៣៥៣ កថាខណ្ឌទី ៦ ។

[103] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៤៨២ ដល់ មាត្រា ៤៩០ ។

[104] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥២៣ ។

[105] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥២៤ ។

[106] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥២៥ ។

ព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលចុងក្រោយបង្អស់ដល់ទណ្ឌិតដើម្បីឱ្យទណ្ឌិតបង់ប្រាក់ពិន័យ ដោយជូនដំណឹងថា ប្រសិនបើទណ្ឌិតមិនព្រមបង់ សាមីខ្លួនអាចនឹងត្រូវបង្ខំដល់រូបកាយ។ ចំណែកឯរយៈពេលដែលព្រះរាជអាជ្ញាកំណត់មិនអាចតិចជាង ១០ (ដប់)ថ្ងៃទេ។ ចំពោះការជូនដំណឹងត្រូវធ្វើឡើងដោយផ្ទាល់មាត់ ឬក៏តាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ បន្ថែមពីនេះទៅទៀត ការឱ្យដំណឹងត្រូវតែមានការធ្វើកំណត់ហេតុដែលត្រូវចុះហត្ថលេខា ឬផ្តិតស្នាមមេដៃដោយទណ្ឌិត ក្នុងករណីដែលទណ្ឌិតមិនចេះចុះហត្ថលេខា។

### ៤.១.២.២. ការបង្ខំដល់រូបកាយ

ក្រោយពីផុតរយៈពេលដែលបានកំណត់ទុកឱ្យទណ្ឌិតដើម្បីបង់ប្រាក់ពិន័យ ព្រះរាជអាជ្ញាត្រូវចេញបញ្ជារឱ្យបង្ខំ និងឱ្យឃុំខ្លួន នៅក្នុងករណីដែលទណ្ឌិតមិនបានបង់ប្រាក់ពិន័យតាមកំណត់។ នៅក្នុងបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន ត្រូវមាននិទ្ទេសដូចតទៅ[107]៖

- អត្តសញ្ញាណនៃទណ្ឌិត
- ប្រភេទ និងកាយោងនៃទណ្ឌកម្ម
- ការយោងនៃដីកាឱ្យដំណឹងដែលមានចែងនៅក្នុងមាត្រា ៥២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ចំនួនទឹកប្រាក់ដែលមិនបានបង់
- ថិរវេលានៃការបង្ខំដល់រូបកាយ។

បញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួនដែលជាសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា អាចជាកម្មវត្ថុនៃការប្តឹងតវ៉ាបាន។ ដោយឡែកទណ្ឌិតដែលបានធ្វើការប្តឹងតវ៉ានឹងបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន នឹងត្រូវបានគេនាំខ្លួនជូនប្រធានតុលាការ។ នៅក្នុងខណៈនោះ ប្រធានតុលាការត្រូវពិនិត្យមើលអំពីនីត្យានុកូលភាពនៃបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន។ បន្ទាប់មក ប្រសិនបើមានការបំពានច្បាប់ ប្រធានតុលាការត្រូវសម្រេចលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន តាមដីការឱ្យដោយមានសំអាងហេតុយ៉ាងត្រឹមត្រូវ។ ទន្ទឹមនឹងនេះផងដែរ សេចក្តីសម្រេចលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន គ្មានអានុភាពអនុវត្តទេក្នុងរយៈពេល ២ (ពីរ)ថ្ងៃ ដែលជារយៈពេលកំណត់ទុក សម្រាប់ការប្តឹងតវ៉ាពីសេចក្តីសម្រេចរបស់ប្រធានតុលាការទៅកាន់ប្រធានសាលាឧទ្ធរណ៍។ នៅពេលដែលបានផុតរយៈពេលខាងលើនេះ ទណ្ឌិតនឹងត្រូវតែសម្រេចដោះលែងឱ្យមានសេរីភាពជាថ្មីឡើងវិញ។[108]

យ៉ាងណាមិញ សេចក្តីសម្រេចរបស់ប្រធានតុលាការអំពីការប្តឹងតវ៉ារបស់ទណ្ឌិតទៅនឹងបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន អាចត្រូវប្តឹងតវ៉ាទៅកាន់ប្រធានសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ (ពីរ)ថ្ងៃ ដោយអគ្គព្រះរាជអាជ្ញា ឬព្រះ

[107] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥២៦ ។

[108] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥២៧ ។

រាជអាជ្ញា ឬក៏ទណ្ឌិត។ ដូច្នេះ ប្រសិនបើមានការប្ដឹងតវ៉ា សេចក្ដីសម្រេចរបស់ប្រធានតុលាការពិតជាពុំមានអានុភាពអនុវត្តទេ ពោលគឺត្រូវរង់ចាំរហូតដល់មានដីកាសម្រេចរបស់ប្រធានសាលាឧទ្ធរណ៍ជាថ្មីទៀត។ ចុងក្រោយបំផុតប្រធានសាលាឧទ្ធរណ៍ត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ និងមានអាចប្ដឹងតវ៉ាបានទៀតឡើយ។

ជាគោលការណ៍ទូទៅ ការកំណត់ចិរវេលានៃការបង្ខំដល់រូបកាយត្រូវតែអនុលោមទៅតាមចំនួនទឹកប្រាក់ដែលត្រូវបានតម្រូវឱ្យបង់។ ចិរវេលានៃការបង្ខំរូបកាយ ត្រូវបានកំណត់ដោយសមាមាត្រទៅនឹងចំនួនទឹកប្រាក់ដូចខាងក្រោមនេះ[109]៖

- ១០(ដប់)ថ្ងៃ កាលបើទឹកប្រាក់ដែលមិនបានបង់នោះមានចំនួនមិនលើសពី ២៥០.០០០(ពីររយហាសិបពាន់) រៀល។
- ២០ថ្ងៃ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២៥០.០០១ រៀល ដល់ ៥០០.០០០ រៀល។
- ១ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥០០.០០១ រៀល ដល់ ១.០០០.០០០ រៀល។
- ២ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១.០០០.០០១ រៀល ដល់ ២.៥០០.០០០ រៀល។
- ៣ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២.៥០០.០០១ រៀល ដល់ ៥.០០០.០០០ រៀល។
- ៦ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥.០០០.០០១ រៀល ដល់ ១០.០០០.០០០ រៀល។
- ១ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១០.០០០.០០១ រៀល ដល់ ២០.៥០០.០០០ រៀល។
- ១៨ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២០.៥០០.០០១ រៀល ដល់ ៥០.៥០០.០០០ រៀល។
- ២ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥០.០០០.០០១ រៀល។

តាមមាត្រា៥៣០ កថាខណ្ឌចុងក្រោយនៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាការបង្ខំដល់រូបកាយធានាការប្រមូលតណទេយ្យច្រើននោះ ចិរវេលានៃការបង្ខំត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម។

ឧទាហរណ៍ : តាមសាលក្រមព្រហ្មទណ្ឌលេខ ០១ ឈ្មោះ ក ត្រូវបានតុលាការសម្រេចឱ្យបង់ប្រាក់ពិន័យចំនួន ៥លានរៀល ពីបទជេរប្រមាថជាសាធារណៈ និងតាមសាលក្រមព្រហ្មទណ្ឌលេខ ០២ លេខ ឈ្មោះ ក ត្រូវបានតុលាការសម្រេចផ្ដន្ទាទោសឱ្យបង់ប្រាក់ពិន័យចំនួន ៦លានរៀល ពីបទបរិហាកេរ្តិ៍ជាសាធារណៈ។ ជាងនេះទៅទៀត ឈ្មោះ ក ក៏ត្រូវបានតុលាការសម្រេចផ្ដន្ទាទោសឱ្យបង់ប្រាក់ពិន័យចំនួន ២លានរៀល ទៀតពីបទជេរប្រមាថជាសាធារណៈតាមសាលក្រមព្រហ្មទណ្ឌលេខ ០៣។ ក្នុងករណីនេះ ចំនួនសរុបនៃទណ្ឌកម្មលើឈ្មោះ ក មានចំនួន ១៣លានរៀល។ ជាលទ្ធផល ការកំណត់ពីចិរវេលានៃការបង្ខំដល់រូបកាយត្រូវគិតគូរទៅតាមចំនួន

[109] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥៣០ ។

សរុបនៃទណ្ឌកម្ម ពោលគឺទៅតាមចំនួននៃប្រាក់ពិន័យជាសរុបគឺ ១៣លានរៀល។ ហេតុដូច្នេះ ឈ្មោះ ក អាចត្រូវបង្ខំដល់រូបកាយសម្រាប់ចិរវេលា ១ (មួយ)ឆ្នាំ។

ការបង្ខំដល់រូបកាយមានលក្ខខណ្ឌដូចគ្នានឹងការជាប់ទោសពន្ធនាគារដែរ មានន័យថា ទណ្ឌិតនឹងត្រូវចាប់ខ្លួនយកទៅឃុំឃាំងនៅក្នុងពន្ធនាគារ ដូចករណីនៃការអនុវត្តទោសដាក់ពន្ធនាគារតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការដែរ។ ការបង្ខំដល់រូបកាយមិនមែនជាមធ្យោបាយសម្រាប់ទូទាត់បំណុលទេ ហេតុដូច្នេះ ទោះបីជាក្នុងលក្ខខណ្ឌដែលទណ្ឌិតបានទទួលការបង្ខំដល់រូបកាយរួចហើយក៏ដោយ ក៏បំណុលនៅតែមានអត្ថិភាពជាដរាប។ ក៏ប៉ុន្តែ ទណ្ឌិតមិនអាចត្រូវទទួលរងនូវការបង្ខំដល់រូបកាយ ចំពោះបំណុលដដែលនេះសារជាថ្មីម្តងទៀតបានទេ។[110]

កាលណាដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលប្រាក់សំណង និងជម្ងឺចិត្តពីទណ្ឌិត ឬពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ព្រះរាជអាជ្ញាឱ្យធ្វើការបង្ខំលើរូបកាយបាន។ ការបង្ខំលើរូបកាយដើម្បីទារសំណង និងជម្ងឺចិត្ត អាចអនុវត្តបានតែនៅលើទណ្ឌិតប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវជូនភស្តុតាងថា ខ្លួនបានប្រើអស់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ ឬអចលនវត្ថុជាដើម។ ព្រះរាជអាជ្ញាអាចហៅដើមបណ្តឹងរដ្ឋប្បវេណីឱ្យធ្វើនីតិវិធីថ្មី ដើម្បីសាកល្បងទារប្រាក់សំណង និងជម្ងឺចិត្តនេះ។

## ៤.២. ការអនុវត្តសេចក្តីសម្រេចតុលាការដោយអាជ្ញាធរមានសមត្ថកិច្ច

នៅក្រោយពេលតុលាការប្រកាសសេចក្តីសម្រេច និងបានចូលជាស្ថាពរ ស្ថាប័នសាធារណៈត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេច ដែលមានស្ថាប័នដូចជា អយ្យការ (**៤.២.១**) កងកម្លាំងសាធារណៈ(**៤.២.២**) អាជ្ញាសាលា(**៤.២.៣**) និងក្រសួងយុត្តិធម៌(**៤.២.៤**) ។

### ៤.២.១. អយ្យការ

ជាទូទៅ ទោសត្រូវចាប់ផ្តើមអនុវត្តនៅពេលដែលសេចក្តីសម្រេចរបស់តុលាការ បានចូលជាស្ថាពរ ។[111] ដោយឡែក អាជ្ញាធរដែលត្រូវទទួលបន្ទុកអនុវត្តទោសគឺ អង្គការអយ្យការ។ ការអនុវត្តទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតផ្តើមរបស់អយ្យការ។ អយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់តុលាការ បានក្លាយទៅជាស្ថាពរ។ ហើយរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ។

[110] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥៣២ ។

[111] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៤៩៧ ។

### ៤.២.២. កងកម្លាំងសាធារណៈ

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអាចស្នើសុំកងកម្លាំងសាធារណៈ ដើម្បីធានារ៉ាប់រងដល់ការអនុវត្តទោស។ ដូចគ្នានេះដែរ បើយោងទៅតាមប្រភេទនៃទោស ការអនុវត្តទោសអាចតម្រូវឱ្យមានស្ថាប័នពាក់ព័ន្ធផ្សេងទៀតចូលរួមផងដែរ។[112]

### ៤.២.៣. អាជ្ញាសាលា

ចំពោះករណីនៃការទាមទារប្រាក់សំណង និងជម្ងឺចិត្តពីទណ្ឌិត ឬពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចមាននីតិវិធីផ្សេងក្រៅពីការការស្នើសុំដល់ព្រះរាជអាជ្ញាឱ្យធ្វើការបង្ខំដល់រូបកាយលើទណ្ឌិត គឺការអនុវត្តដោយបង្ខំ។

ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទាមទារប្រាក់សំណង និងជម្ងឺចិត្តតាមវិធាននៃការអនុវត្តដោយបង្ខំដែលមានបញ្ញត្តនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ បុគ្គលដែលមានសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀត អាចទាមទារឱ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃការអនុវត្តដោយបង្ខំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង។[113] ដូចនេះ ក្នុងករណីដែលសិទ្ធិទាមទារត្រូវអះអាងក្នុងបណ្តឹងរដ្ឋប្បវេណីដែលភ្ជាប់នឹងរឿងក្តីព្រហ្មទណ្ឌ ត្រូវទទួលស្គាល់ នៅក្នុងសាលក្រម ឬសាលដីកាព្រហ្មទណ្ឌ ការអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារក៏ត្រូវធ្វើតាមគន្លឹនៃការអនុវត្តដោយបង្ខំនៃក្រមនីតិវិធីរដ្ឋប្បវេណីនេះដែរ។[114]

យោងតាមកថាខណ្ឌខាងលើ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យសុំដើម្បីអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត។ ស្ថាប័នអនុវត្ត គឺតុលាការអនុវត្ត ឬអាជ្ញាសាលា។[115] អាជ្ញាសាលា គឺជាស្ថាប័នតុលាការដាច់ដោយឡែកមួយ ដែលទទួលបន្ទុកការងារអនុវត្តដោយបង្ខំ និងការងារពាក់ព័ន្ធ ហើយដែលមានមន្ត្រីរាជការដែលមានឈ្មោះថា អាជ្ញាសាលា។ អាជ្ញាសាលា គឺជាស្ថាប័នអនុវត្តមួយឯករាជ្យ មិនមែនជាស្ថាប័នជំនួយនៃតុលាការអនុវត្តនោះទេ។[116] ចំពោះការសម្រេចសេចក្តីរបស់តុលាការអនុវត្ត ត្រូវធ្វើឡើងដោយដីកាសម្រេច។[117] អាជ្ញាសាលាមានអំណាចក្នុងការចាត់ចែងការអនុវត្តតាមរយៈដីកាសម្រេចឱ្យអនុវត្តដោយបង្ខំរបស់តុលាការអនុវត្ត ដោយធ្វើសកម្មភាពដើម្បីអនុវត្តនីតិវិធី ដូចជាការរឹបអូស ការប្តូរជាប្រាក់ ការចែកចំណែក ជាដើម។

[112] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥៩៩ ។

[113] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៣៤ ។

[114] ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី,២០០៧, ៣១២ ។

[115]ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៣៦ កថាខណ្ឌទី២។

[116] ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី,២០០៧, ៣១៣។

[117] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣៣៧ កថាខណ្ឌទី១។

### ៤.២.៤. ក្រសួងយុត្តិធម៌

ក្រសួងយុត្តិធម៌តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុសាលក្រម សាលដីកា និងសេចក្តីសម្រេចទាំងឡាយរបស់តុលាការ និងអយ្យការគ្រប់ជាន់ថ្នាក់។ នៅក្នុងការអនុវត្តសេចក្តីសម្រេចតុលាការ ក្រសួងយុត្តិធម៌ទទួលបន្ទុកត្រួតពិនិត្យមន្ទីរឃុំឃាំង និងពន្ធនាគារក្នុងការអនុវត្តច្បាប់ ហើយតាមដាន និងត្រួតពិនិត្យការងារអនុវត្តទោស។ បន្ថែមពីនេះទៅទៀត នៅពេលដែលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ រាល់សេចក្តីសម្រេចទាំងអស់នោះត្រូវបញ្ជូនទៅដាក់តម្កល់ទុកនៅក្រសួងយុត្តិធម៌ និងស្ថាប័នផ្សេងៗទៀត។

ការចូលជាស្ថាពរនៃសេចក្តីសម្រេចរបស់តុលាការ មានអានុភាពដល់ទណ្ឌិត កាលណាទណ្ឌិតបានទទួលទោសដាក់ពន្ធនាគារ ឬការបង្ខំដល់រូបកាយរួចរាល់ហើយ កាលបរិច្ឆេទនៃការអនុវត្តទោស ឬបង្ខំដល់រូបកាយនេះ ត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីថ្កោលទោស។ បញ្ជីថ្កោលទោសត្រូវបានកាន់កាប់ដោយអង្គភាពមួយនៃក្រសួងយុត្តិធម៌។ ចំពោះបុគ្គលដែលកើតនៅកម្ពុជា បញ្ជីថ្កោលទោសនេះ ទទួលសលាកបត្រដែលកត់ត្រា[118]៖

- គ្រប់ការផ្តន្ទាទោសចំពោះមុខ ការផ្តន្ទាទោសដែលទុកជាចំពោះមុខ និងការផ្តន្ទាទោសដោយកំបាំងមុខទាំងអស់ដែលត្រូវបានប្រកាសដោយតុលាការព្រហ្មទណ្ឌកម្ពុជា
- ការផ្តន្ទាទោសដែលត្រូវបានប្រកាសដោយតុលាការបរទេស ហើយដែលអនុវត្តតាមកិច្ចព្រមព្រៀងអន្តរជាតិ ត្រូវបានជូនដំណឹងមកដល់អាជ្ញាធរកម្ពុជា
- វិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដែលប្រទានដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីសម្រេចក្នុងរឿងដោះលែងដោយមានលក្ខខណ្ឌ
- សេចក្តីសម្រេចស្តីពីការបង្ខំដល់រូបកាយ
- សាលក្រម ឬសាលដីកាដែលប្រកាសការក្ស័យធន
- សេចក្តីសម្រេចឱ្យមានការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ
- សេចក្តីសម្រេចបណ្តេញជនបរទេស ។

ត្រូវដកចេញវិញពីបញ្ជីថ្កោលទោស៖

- ការផ្តន្ទាទោសដែលសម្រេចដោយកំបាំងមុខ កាលណាការផ្តន្ទាទោសនេះត្រូវទុកជាអាសាបង់បន្ទាប់ពីមានបណ្តឹងទាស់
- ការផ្តន្ទាទោសដែលត្រូវបានលុបលាងដោយការលើកលែងទោសជាទូទៅ
- ការផ្តន្ទាទោសដែលកើតមកដោយការភ័ន្តច្រឡំអត្តសញ្ញាណ

[118] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥៤២ ។

- ការផ្តន្ទាទោសដែលត្រូវបានចាត់ទុកជាអាសាបង់ដោយនីតិវិធីនៃបណ្តឹងសើរើ។

ក្រឡាបញ្ជីតុលាការ ត្រូវតែផ្ញើជូនអង្គភាពនៃបញ្ជីថ្កោលទោស ក្រោមការត្រួតពិនិត្យរបស់ប្រធានតុលាការ នូវសលាកបត្រចំពោះសេចក្តីសម្រេចនីមួយៗដែលត្រូវចុះក្នុងបញ្ជីថ្កោលទោស។ ប្រធានពន្ធនាគារជូនដំណឹងដល់អង្គភាពបញ្ជីថ្កោលទោសអំពីកាលបរិច្ឆេទនៃការអនុវត្តទោស ឬការបង្ខំដល់រូបកាយរួចរាល់ហើយ។ អង្គភាពរតនាគារជូនដំណឹងដល់អង្គភាពបញ្ជីថ្កោលទោសអំពីការបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី។ អង្គភាពបញ្ជីថ្កោលទោសរ៉ាប់រងទទួលព័ត៌មាន អំពីវិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដែលប្រទានដោយព្រះមហាក្សត្រ និងសេចក្តីសម្រេចបណ្តេញជនបរទេស។[119]

បន្ថែមពីនេះទៅទៀត កាលណាបុគ្គលណាមួយត្រូវបានផ្តន្ទាទោសដោយខុសអត្តសញ្ញាណ អយ្យការត្រូវតែសុំឱ្យធ្វើការកែតម្រូវបញ្ជីថ្កោលទោសភ្លាម។[120]

ចំពោះទណ្ឌិតដែលទទួលបាននីតិសម្បទាឡើងវិញ នឹងមានអានុភាពលុបចោលទណ្ឌកម្មព្រហ្មទណ្ឌ។ ប៉ុន្តែ ទោសនេះនៅតែមានចុះនៅក្នុងបញ្ជីថ្កោលទោសដដែល ដោយមានចុះនិទ្ទេសថា ត្រូវបាននីតិសម្បទាឡើងវិញ។

[119] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥៤៤ ។

[120] ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧, មាត្រា ៥៥១ ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

នីតិវិធីនៃការអនុវត្តមូលទោស គឺជាវិធានក្នុងការអនុវត្តទោសមួយក្នុងចំណោមទោសទាំងបីដែលមានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌដែលរួមមាន មូលទោស ទោសបន្ថែម និងទោសជំនួស។ ចំពោះមូលទោស គឺមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ដែលត្រូវបង់ចូលក្នុងថវិកាជាតិ។ រីឯទោសមួយទៀតគឺជាទោសបន្ថែម ដែលត្រូវអនុវត្តទៅលើមូលទោសទោសបន្ថែម ដោយតុលាការអាចប្រកាសក៏បាន មិនប្រកាសក៏បាន ហើយទោសបន្ថែមនេះត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។ ចំណែកឯទោសចុងក្រោយជាជំនួសដែលត្រូវយកមកជំនួសមូលទោសក្នុងករណីអតិបរមានៃទោសដាក់ពន្ធនាគារស្មើ ឬតិចជាង ៣ ឆ្នាំ ឬទោសពិន័យជាប្រាក់។ ក្រៅពីការធានានូវយុត្តិធម៌ដល់ជូនរងគ្រោះ ការអនុវត្តទោសក៏ជាវិធានការក្នុងការផ្តល់ឱកាសក្នុងការកែប្រែចំពោះចារីដែលបានប្រព្រឹត្តបទល្មើសឱ្យឈប់ប្រព្រឹត្តបទល្មើស លែងមានហ៊ានប្រព្រឹត្តបទល្មើសតទៅទៀត ដើម្បីឱ្យចារីធ្វើសមាហរណកម្មចូលក្នុងសង្គមវិញ និងជាពិសេសរក្សាសណ្តាប់ធ្នាប់និងសុខសុវត្ថិភាពសាធារណៈ។

បន្ថែមពីនេះ ការអនុវត្តទោសទោសដែលអនុវត្តចំពោះបុគ្គលត្រូវបានកំណត់ក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ដែលមានរូបវន្តបុគ្គល និងនីតិបុគ្គល។ ចំពោះទោសម្រាប់អនុវត្តទៅលើរូបវត្តបុគ្គល គឺត្រូវធ្វើការពិចារណាទៅលើបទល្មើសដែលត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅមានទម្ងន់នៃបទល្មើសនោះ។ គោលបំណងគឺដើម្បីកំណត់បទល្មើសមួយជាបទឧក្រិដ្ឋ ឬជាបទបជ្ឈិម ឬជាបទលហុ គឺត្រូវពិនិត្យមើលទៅលើការប្រកាសមូលទោស មានន័យថាអតិបរមានៃទោសដាក់ពន្ធនាគារដែលក្រមព្រហ្មទណ្ឌកំណត់សម្រាប់បទល្មើសនោះ។ ចំណែកឯការអនុវត្តទោសចំពោះរូបវន្តបុគ្គល គឺត្រូវផ្អែកទៅលើនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលអាចជានីតិជន និងអនីតិជនដែលរបបនៃការអនុវត្តមូលទោសគឺមានភាពខុសពីគ្នាផងដែរ។ រីឯការអនុវត្តទោសចំពោះនីតិបុគ្គលវិញ ឃើញថាមានការអនុវត្តខុសប្លែកពីរូបវន្តបុគ្គល ដោយសារវាមានលក្ខណៈអរូបិយ ប៉ុន្តែក៏ច្បាប់នៅតែកំណត់អំពីការទទួលខុសត្រូវរបស់នីតិបុគ្គលផងដែរ។ ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល គឺទោសពិន័យជាប្រាក់ និងទោសបន្ថែម។ នីតិបុគ្គលដែលទទួលខុសត្រូវព្រហ្មទណ្ឌមានតែនីតិបុគ្គលឯកជនតែប៉ុណ្ណោះ។ ប៉ុន្តែនីតិបុគ្គលសាធារណៈរបស់រដ្ឋដែលទទួលបាននូវអំណាចតាមរយៈប្រតិភូកម្ម និងមានអាចក្នុងដែនរបស់ខ្លួន ហើយធ្វើសកម្មភាពរបស់ខ្លួនដូចនឹងនីតិបុគ្គលឯកជនដើម្បីជាប្រយោជន៍ដែរនោះ ក៏ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែលអាចឱ្យតុលាការប្រកាសមូលទោសបាន។

ម្យ៉ាងវិញទៀត ក្រៅអំពីវិធានក្នុងការអនុវត្តទោសទៅលើរូបវន្តបុគ្គល និងនីតិបុគ្គល ក្រមព្រហ្មទណ្ឌក៏បញ្ញត្តនូវវិធាននៃការអនុវត្តទោស និងមូលហេតុគតិយុត្តផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស។ វិធាននៃការអនុវត្តទោសនោះមានដូចជា ការព្យួរទោស ការផ្អាកការប្រកាសទោស របបពាក់កណ្តាលសេរីភាព

និងការបែងចែកទោសជាប្រភាគ។ រីឯមូលហេតុគតិយុត្តផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តមូលទោស មានដូចជា អាជ្ញាយុកាលនៃទោស ការអនុគ្រោះទោស ការលើកលែងទោសជាទូទៅ មរណៈភាពនៃជនជាប់ចោទ ការសម្រុះសម្រួលជាមួយរដ្ឋ និងការដកពាក្យបណ្តឹង។ វិធាននៃការអនុវត្តទោស និងមូលហេតុគតិយុត្តិដែលរៀបរាប់ខាងលើនេះ ត្រូវបញ្ចប់មុនពេលនូវការអនុវត្តមូលទោសជាពិសេសទោសដាក់ពន្ធនាគារដែលត្រូវបានកំណត់ក្នុងសេចក្តីសម្រេចតុលាការ។

បន្ទាប់ពីតុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទនិងរកឃើញថាជនជាប់ចោទពិតជាមានពិរុទ្ធភាពមែន តុលាការនឹងចេញសេចក្តីសម្រេចប្រកាសផ្តន្ទាទោសទៅតាមបញ្ញត្តិដែលបានកំណត់ក្នុងច្បាប់ និងសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម។ សេចក្តីសម្រេចរបស់តុលាការដែលប្រកាសផ្តន្ទាទោសលើជនជាប់ចោទត្រូវតែអនុវត្តនូវមូលទោស គឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ហើយបុគ្គលដែលត្រូវក្នុងនោះមានបុគ្គលដែលកំពុងជាប់ឃុំ និងបុគ្គលដែលកំពុងនៅក្រៅឃុំ។ ជនជាប់ចោទដែលមានវត្តមាននឹងត្រូវចាប់ខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួនដោយបង្ហាញមុខចំពោះព្រះរាជអាជ្ញា ដើម្បីឱ្យដំណឹងនិងចាប់ផ្តើមអនុវត្តទោសដាក់ពន្ធនាគារ។ រីឯបុគ្គលដែលនៅក្រៅឃុំ ហើយករណីមានសេចក្តីសម្រេចផ្តន្ទាទោសដោយតុលាការ គឺជាសេចក្តីសម្រេចដែលធ្វើឡើងដោយកំបាំងមុខត្រូវបានជូនដំណឹងតាមនីតិវិធី ហើយសេចក្តីសម្រេចនឹងចូលជាស្ថាពរ។ ចំពោះការអនុវត្តការពិន័យតម្រូវឱ្យទណ្ឌិតបង់ប្រាក់ពិន័យទៅតាមការកំណត់ក្នុងសេចក្តីសម្រេច ដោយមានវិធានការអាចយកមកអនុវត្តបានគឺ ការរឹមអូស និងការបង្ខំដល់រូបកាយ។ អាជ្ញាធរមានអំណាចក្នុងការអនុវត្តទោស ហើយត្រូវចាប់ផ្តើមអនុវត្តនៅពេលដែលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរស្របតាម។ អាជ្ញាធរដែលទទួលបន្ទុកអានុវត្តទោសគឺអយ្យការ ដោយមានកិច្ចសហការចូលរួមដោយករកម្លាំងសាធារណៈ។ ស្របជាមួយគ្នានេះដែរ រាល់ការពាក់ព័ន្ធនឹងការរឹមអូសទ្រព្យសម្បត្តិរបស់ទណ្ឌិត បទបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវតែយកមកអនុវត្តដោយបង្ខំតាមរយៈអាជ្ញាសាលានៃតុលាការអនុវត្ត។ ដោយឡែកវិធានការទីពីរនៃការទាមទារប្រាក់ពិន័យគឺជាការបង្ខំដល់រូបកាយដែលមានចែកក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ម៉្យាងទៀត ការបង្ខំដល់រូបកាយក៏អាចត្រូវយកមកប្រើប្រាស់ ដើម្បីទាមទារប្រាក់ពន្ធនៃនីតិវិធី ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ចំណែកឯសេចក្តីសម្រេចដែលបានផ្តន្ទាទោសលើទណ្ឌិតចូលជាស្ថាពររួចហើយ គឺមានអានុភាពលើទណ្ឌិត កាលណាបានទទួលរងទោសដាក់ពន្ធនាគារ ឬត្រូវបង្ខំរូកាយនឹងត្រូវចុះកាលបរិច្ឆេទអំពីទោសពន្ធនាគារ ឬការបង្ខំរូបកាយនៅលើបញ្ជីថ្កោលទោសដែលគ្រប់ដោយក្រសួងយុត្តិធម៌។

សរុបសេចក្ដីមកយើងអាចសន្និដ្ឋានបានថា នីតិវិធីនៃការអនុវត្តមូលទោសនេះមានយន្តការជាច្រើនដែលមានលក្ខណៈផ្ដល់ឱកាសឱ្យទណ្ឌិតមានការកែប្រែ ឬបានសងនូវព្យសនកម្មនូវការខូចខាតទៅសង្គម ឬជនរងគ្រោះជាជាងទទួលរងនូវទោសទណ្ឌ។ យន្តការមួយចំនួនដែលបានរៀបរាប់គន្លងមក គឺជាការធ្វើសមាហរណកម្មរបស់ទណ្ឌិតដែលបានកែប្រែខ្លួនឆាប់បានចូលមករួមរស់ក្នុងសង្គមវិញ ដូចជាយន្តការការព្យួរទោស របបពាក់កណ្ដាលសេរីភាព ការបែងចែកទោសជាប្រភាគ អាជ្ញាយុកាលនៃទោស ការអនុគ្រោះទោស ការលើកលែងទោសជាទូទៅ និងកត្តាផ្សេងៗទៀត។ យន្តការទាំងនេះមានសារៈសំខាន់មិនមែនតែចំពោះទណ្ឌិតនោះទេ គឺជាប្រយោជន៍ដល់សង្គមដែលអាចជាលទ្ធផលនាំឱ្យមានការថមថយចុះនៃកំណើនបទល្មើសនៅក្នុងសង្គម និងជាពិសេសចំពោះរដ្ឋ អាចកាត់បន្ថយចំណាយទៅលើការគ្រប់គ្រងពន្ធនាគារ និងចំណាយផ្សេងៗទៀតក្នុងដំណើរការនីតិវិធីតុលាការ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបកស្រាយនូវប្រធានបទខាងលើនេះយើងឃើញថា ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មានយន្តការជាច្រើនសម្រាប់ការប្រកាសទោសព្រហ្មទណ្ឌ ចំពោះជនដែលបានប្រព្រឹត្តបទល្មើសដូចមានដែលមានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌ។ ប្រភេទទោសដែលមានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌគឺមាន មូលទោស ទោសបន្ថែម និងទោសជំនួស។ បន្ថែមពីនេះក្រមព្រហ្មទណ្ឌក៏មានបញ្ញត្តិនូវរបបផ្សេងដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តទោស ជាពិសេសមូលទោស ដូចជា ការព្យួរទោស របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ និងយន្តការគតិយុត្តមួយចំនួនផ្សេងទៀត ដែលត្រូវបានបញ្ញត្តឡើងដែលមានលក្ខណៈបន្ធូរបន្ថយច្រើនជាងមុនសម្រាប់ទណ្ឌិត។ ទោះបីជាក្រមព្រហ្មទណ្ឌបញ្ញត្តនូវយន្តការទាំងនោះក្តី យើងអាចសង្កេតឃើញថាយន្តការទាំងនេះមិនត្រូវបានអនុវត្តទាំងអស់នោះទេ ពីព្រោះតុលាការគ្រប់ជាន់ថ្នាក់នៅកម្ពុជាភាគច្រើន គឺយកយន្តការការអនុវត្តមូលទោស។ ហេតុផលទាំងនេះហើយ ទើបយន្តការផ្សេងៗទៀតមិនសូវបានយកមកអនុវត្ត និងជាពិសេសនាំឱ្យមានកំណើននូវទណ្ឌិតនៅក្នុងពន្ធនាគារច្រើនលើសលប់ដែលអាចជាបន្ទុករបស់រដ្ឋ។ ចំពោះបញ្ហាប្រឈមដែលមានការលំបាកក្នុងការអនុវត្តចំពោះយន្តការដូចជា ទោសជំនួស (ទោសការងារសហគមន៍ និងការស្តីបន្ទោស) ការបែងចែកទោសជាប្រភាគ និងរបបពាក់ណ្តាលសេរីភាព គឺអាចបណ្តាលមកពីបញ្ហាបច្ចេកទេស ស្ថានភាព ទីកន្លែង ពេលវេលា និងការឃ្លាំមើលជាដើម ដែលសុទ្ធសឹងជាយន្តការថ្មីដែលមានការបារម្ភចំពោះប្រសិទ្ធភាពចំពោះការអនុវត្តយុន្តការទាំងនេះ។

ជាទីបញ្ចប់យើងខ្ញុំសង្ឃឹមថា នាពេលខាងមុខតុលាការនឹងជ្រើសរើសនូវយន្តការដែលមានបញ្ញត្តិក្នុងច្បាប់ដូចជា ទោសជំនួស ការព្យួរទោស របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគមកអនុវត្តចំពោះជនជាប់ចោទ។ វិធានការទាំងអស់នេះ អាចជាការផ្តល់ឱកាសដល់ទណ្ឌិត បើទោះបីជាគាត់បានប្រព្រឹត្តបទល្មើសមែន ប៉ុន្តែអាចជាកំហុសខុសឆ្គងមួយពេល ដូច្នេះយើងអាចផ្តល់ឱកាសឱ្យគាត់ក្នុងការប្រើប្រាស់ជំនាញ និងទេពកោសល្យរបស់គាត់ ក្នុងការជួយដល់សង្គម និងសហគមន៍ ជាជាងយកគាត់មកទុកចោលដោយមិនអាចជួយអ្វីបានទាល់តែសោះដល់សង្គម។ ក៏ប៉ុន្តែការអនុវត្តតាមវិធានការខាងលើមិនមែនមានន័យថាព្រលែងទណ្ឌិតចោល ហើយគាត់ចង់ធ្វើអ្វីបានតាមចិត្ត ឬអាចនាំនូវការបង្កហានិភ័យ ឬក៏គ្រោះថ្នាក់ដល់សង្គមទេ គឺស្ថិតក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងបំផុត។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។

- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ។

- ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១ ។

- ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤ ។

- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ។

- សារាចរណែនាំលេខ ០២ កយ.សរ/១៤ ស្តីពីការអនុវត្តបទប្បញ្ញត្តិនៃការព្យួរទោសសាកល្បង ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៤ ។

## ២. សទ្ទានុក្រម

- សទ្ទានុក្រមច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ នៃទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ ។

- សទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧ ។

- សទ្ទានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៨ ។

## ៣. ឯកសារស្រាវជ្រាវ

- សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ, កែសសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១២ ។

- មេរៀននីតិព្រហ្មទណ្ឌ, អត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ រៀបចំដោយ សហប្រតិបត្តិការបារាំង គម្រោងទ្រទ្រង់នីតិរដ្ឋ ឆ្នាំ២០០៧ ។

- ព្រឹត្តិបត្រមេធាវីលេខ ១៣, ទណ្ឌិត ឧុច និងសិទ្ធិទទួលបានការលើកលែងទោស ឬការបន្ធូរបន្ថយទោសដោយ មាស បូរ៉ា, ខែ មេសា-ឧសភា ឆ្នាំ២០១៧ ។

- អត្ថបទស្តីអំពីទោសប្រហារជីវិតៈ តើកម្ពុជាគួររក្សាការលុបទោសប្រហាជីវិត ឬប្រើទោសប្រភេទនេះឡើងវិញ? ដោយ មាស បូរ៉ា និង នូ ចន្ថា, ២០១៩ ។

- ការផ្សាយរបស់ក្រុមត្រាជូ អត្ថបទសាកល្បងស្តីពីនីតិព្រហ្មទណ្ឌទូទៅ, គោលការណ៍នីត្យានុកូលភាពនៃបទល្មើសនិងទោស, ប្រែសម្រួលដោយ ផៃ ចេងសេង, ២០១៦ ។

- ការផ្សាយរបស់ក្រុមត្រាជូ "ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនិងរបបនៃទោសដែលត្រូវអនុវត្ត" ដោយ ចក សម្បត្តិ, ២០១៥ ។

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយ ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋវេណី, ក្រសួងយុត្តិធម៌, ២០០៧ ។

**៤. បទសម្ភាសន៍**

- ប្រសាសន៍របស់ ឯកឧត្តម ផូវ សំភី អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយ ក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ។

- ប្រសាសន៍របស់ ឯកឧត្តម ប៊ុន ហ៊ុន អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយ ក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ។

- ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយ ក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ។

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធ១៖ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ចាប់ពីមាត្រា៤៣ ដល់មាត្រា១៨២
- ឧបសម្ព័ន្ធ២៖ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាក្រកម្ពុជា ឆ្នាំ២០០៧ ចាប់ពីមាត្រា ៧ ដល់ ៨, មាត្រា ៣៤៧ ដល់ មាត្រា ៣៦០ និង មាត្រា ៤៩៦ ដល់ មាត្រា ៥៥២
- ឧបសម្ព័ន្ធ៣៖ ព្រះរាជក្រឹត្យលេខ នស/រកត/១១១៩/១៦៧២ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការបន្ធូរបន្ថយទោសចំនួន ៦ខែ ឱ្យទណ្ឌិតចំនួន ៥៨ នាក់ ក្នុងឱកាសពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ឆ្នាំ២០១៩ ។
- ឧបសម្ព័ន្ធ៤៖ សារាចរណែនាំលេខ ០២ កយ.សរ/១៤ ស្តីពីការអនុវត្តបទប្បញ្ញត្តិនៃការព្យួរទោសសាកល្បង
- ឧបសម្ព័ន្ធ៥៖ ទម្រង់នៃដីកាសម្រេចរំលត់បណ្តឹងអាជ្ញា
- ឧបសម្ព័ន្ធ៦៖ ទម្រង់នៃសាលក្រម, លិខិតជូនដំណឹង និងលិខិតជូនដំណឹងពីសាលក្រមកំបាំងមុខ
- ឧបសម្ព័ន្ធ៧៖ ទម្រង់នៃដីកាបង្គាប់ឱ្យនាំទណ្ឌិតទៅដាក់គុកបង្ខំដល់រូបកាយ

# ឧបសម្ព័ន្ធ១

# ក្រមព្រហ្មទណ្ឌ

នស/រកម/១១០៩/០២២

# ព្រះរាជក្រម

# យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

# ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

## ជំពូកទី ៤
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣
## ទោស
## ជំពូកទី ១
## ប្រភេទនៃទោស
## ផ្នែកទី ១
## មូលទោស

**មាត្រា ៤៣.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

**មាត្រា ៤៥.-** ការទម្ងន់ទោស និងការសម្រាលទោស

អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចបន្ថែម ឬបន្ថយនៅក្នុងលក្ខខណ្ឌដែលចែងដោយក្រមនេះ ។

**មាត្រា ៤៦.-** និយមន័យនៃបទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ :

១-ជាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៧.-** និយមន័យនៃបទមជ្ឈិម

បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៨.-** និយមន័យនៃបទលហុ

បទល្មើសជាបទលហុ នៅក្នុងករណីដែល :

១-អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

២-បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

**មាត្រា ៤៩.-** ការគណនាអំពីថិរវេលានៃទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ ។

**មាត្រា ៥០.-** លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស

ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ ។

**មាត្រា ៥១.-** ការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងចិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥២.-** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ ។

## ផ្នែកទី ២

## ទោសបន្ថែម

**មាត្រា ៥៣.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការព្យួរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត ។

**មាត្រា ៥៤.-** លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម

ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់ ។

ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។

**មាត្រា ៥៥.-** សិទ្ធិពលរដ្ឋដែលអាចដកបាន

សិទ្ធិពលរដ្ឋដែលអាចដកបានដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ រួមមាន :

១-សិទ្ធិបោះឆ្នោត ។

២-សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។

៣-សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ។

៤-សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬជាអាណត្តិគាហករបស់តុលាការ ។

៥-សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ ។

៦-សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ ។

ទោសនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

**មាត្រា ៥៦.-** ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ

ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ មិនអនុវត្តទៅលើការបំពេញអាណត្តិដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ឬការទទួលខុសត្រូវខាងសហជីពទេ ។ ការហាមឃាត់នេះ មិនអាចអនុវត្តចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មានទេ ។

ទោសនេះអាចជាស្ថាពរ ឬក៏ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

តុលាការត្រូវបញ្ជាក់មុខរបរដែលត្រូវហាមឃាត់ ។

**មាត្រា ៥៧.-** ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការបើកបរយានយន្ត មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ទេ។

**មាត្រា ៥៨.-** ការព្យួរលិខិតបើកបរ

ទោសព្យួរលិខិតបើកបរ មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនទៅក្រឡាបញ្ជីតុលាការ ។ លិខិតបើកបរត្រូវរក្សាទុកតាម

លក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៥៩.-** ការហាមឃាត់ចំពោះការស្នាក់នៅទីកន្លែងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា

ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិត ចំពោះការមានមុខនៅទីកន្លែងខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ទោសនេះមិនអាចលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម ។

តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់ និងកំណត់ចិរវេលានៃការហាមឃាត់ ។

ការហាមឃាត់ការស្នាក់នៅ រួមមានវិធានការតាមដាន ។

ទណ្ឌិតត្រូវតែ :

១-ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលដែលតុលាការបានចាត់តាំង ។

២-ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ ។

តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន ។

សេចក្តីសម្រេចរបស់តុលាការ ត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ៦០.-** ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ។

ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ ។ លិខិតឆ្លងដែននេះ ត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេ ក្នុងរយៈពេលដែលកំពុងទទួលទោសនោះ ។

**មាត្រា ៦១.-** ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដល់ទណ្ឌិតដែលជាជនបរទេស

ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះ នាំឱ្យមានការបណ្តេញទណ្ឌិតឱ្យចេញដោយពេញច្បាប់នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ ។

**មាត្រា ៦២.-** ការរឹបអូស

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចតទៅ :

១-ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

ប៉ុន្តែ ការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

**មាត្រា ៦៣.-** ការចាត់ចែងទ្រព្យសម្បត្តិរឹបអូស

កាលបើការរឹបអូសបានក្លាយទៅជាស្ថាពរ ទ្រព្យសម្បត្តិរឹបអូសក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងអំពីការប្រគល់ផ្សេងពីនេះ ។

រដ្ឋអាចលក់ ឬបំផ្លាញទ្រព្យរឹបអូស តាមនីតិវិធីស្តីពីការលក់ទ្រព្យសម្បត្តិរដ្ឋ ។

**មាត្រា ៦៤.-** ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង

គ្រាប់រំសេវ អាចជាស្លាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៥.-** ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ

ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយ :

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទោសបណ្ដេញចេញនេះអាចជាស្លាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៦៦.-** ការបិទគ្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង ។

ទោសបិទគ្រឹះស្ថាននេះអាចជាស្លាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៦៧.-** ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលត្រូវប្រើប្រាស់ដោយសាធារណជន អាចជាស្លាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៦៨.-** ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស

ទោសបិទផ្សាយសេចក្ដីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ទេ ។ ការបិទផ្សាយអាចធ្វើទាំងស្រុង ឬតាមសម្រង់ ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

ក្នុងករណីមានការបំបាត់ចោល ការលាក់បំបាំង ឬការហែកចោលសេចក្ដីប្រកាសនេះ ត្រូវតែធ្វើការបិទផ្សាយជាថ្មី ។ ការបិទផ្សាយនេះ ត្រូវចេញសោហ៊ុយដោយអ្នកបំបាត់ចោល លាក់បំបាំង ឬអ្នកហែកចោលសេចក្ដីប្រកាសនេះ ។

**មាត្រា ៦៩.-** ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ

ទោសផ្សាយសេចក្ដីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងថិរវេលាដែលកំណត់ដោយតុលាការ ។

សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត ។ ក្នុងករណីមិនគោរពតាម ទណ្ឌិតអាចត្រូវបង្ខឹដល់រូបកាយ ។

បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្ដីសម្រេច សារព័ត៌មានមិនអាចបដិសេធការផ្សព្វផ្សាយនេះបានទេ ។

**មាត្រា ៧០.-** ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍

ទោសផ្សាយជាសាធារណៈនូវសេចក្ដីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ ។ ការផ្សាយនេះមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ទេ ។ ការផ្សាយអាចផ្សាយទាំងស្រុង តាមសម្រង់ ឬតាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

**មាត្រា ៧១.-** ពេលនៃការអនុវត្តទោសបន្ថែម

ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង ៧ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ ត្រូវអនុវត្តនៅពេល

ផុតទោសពន្ធនាគារ លើកលែងតែមានសេចក្ដីសម្រេចផ្ទុយរបស់តុលាការ។

# ផ្នែកទី ៣
# ទោសជំនួស
## កថាភាគទី ១
## ការងារសហគមន៍

**មាត្រា ៧២.-** និយមន័យនៃការងារសហគមន៍

កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍ ។

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃ ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល ។

**មាត្រា ៧៣.-** អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ ។

**មាត្រា ៧៤.-** របបគតិយុត្តនៃការងារសហគមន៍

ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ជាអាទិ៍ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី ។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ ។

**មាត្រា ៧៥.-** គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ

រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍ ។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ ទៅក្នុងសិទ្ធិជនរងគ្រោះ ។

## កថាភាគទី ២
## ការស្ដីបន្ទោស

**មាត្រា ៧៦.-** របបគតិយុត្តនៃការស្ដីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្ដីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ :

-ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើសបានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

## ជំពូកទី ២
## ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស
## ផ្នែកទី ១
## ស្ថានទម្ងន់ទោស
## កថាភាគទី ១
## និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ

**មាត្រា ៧៧.-** ក្រុមមានការចាត់តាំង

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្ដុំដែលបានបង្កើតឡើង ឬជាសន្ធិផ្ចិតភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន ។

**មាត្រា ៧៨.-** ការគិតទុកជាមុន

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស ។

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស

កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។

## ជំពូកទី ៣
## របបនៃការប្រកាសទោស
### ផ្នែកទី ១
### របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

ការស្ដីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្ដីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្ដន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះ ចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម ៖

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា ។

**មាត្រា ១០២.-** ថិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីថិរវេលានៃ

ការងារ និងរយៈពេលដែលត្រូវបំពេញ ។ រយៈពេលនេះមិនអាចលើសពី ១ (មួយ) ឆ្នាំ ទេ ។

**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ។

ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។

## ផ្នែកទី ២
## ការព្យួរទោសធម្មតា
### កថាភាគទី ១
### បទប្បញ្ញត្តិរួម

**មាត្រា ១០៤.-** ការប្រកាសការព្យួរទោស

នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកនេះ តុលាការអាចបង្គាប់ថា ត្រូវព្យួរការអនុវត្តនូវមូលទោស ។

**មាត្រា ១០៥.-** របបនៃការព្យួរទោស

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការព្យួរទោស ត្រូវគិតតែអំពីការផ្ដន្ទាទោសជាស្ថាពរខាងបណ្ដឹងអាជ្ញាប៉ុណ្ណោះ ។

### កថាភាគទី ២
### ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

**មាត្រា ១០៦.-** លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសពីមុន

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្ដល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្ដន្ទាទោស

ជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនអំពើល្មើស ។

**មាត្រា ១០៧.-** ទោសអាចនាំឱ្យមានការព្យួរទោស

ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ ៖

១-ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១០៨.-** ការព្យួរទោសមួយផ្នែក

តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ចិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ។

**មាត្រា ១០៩.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់ ។

ទោសទី ១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី ២ បានឡើយ ។

**មាត្រា ១១០.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុននោះទេ។ សេចក្តីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស ។

**មាត្រា ១១១.-** ការទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ

ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀត ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកថាជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុង ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## កថាភាគទី ៣
## ការចោទប្រកាន់ចំពោះបទលហុ

**មាត្រា ១១២.-** លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាសប្រសិនបើជនជាប់ចោទ មិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយនៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មុនបទល្មើសនេះ ។

**មាត្រា ១១៣.-** ទោសអាចនាំឱ្យមានការព្យួរទោស

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោសដូចតទៅនេះ :

១-ទោសដាក់ពន្ធនាគារ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១១៤.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រួបជាមួយទោសទី ២ ឡើយ ។

**មាត្រា ១១៥.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិនអាចនាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតានេះដែលសម្រេចពីមុននោះទេ។ សេចក្តីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស។

**មាត្រា ១១៦.-** ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុដែលមានការព្យួរទោសធម្មតា គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## ផ្នែកទី ៣
## ការព្យួរទោសសាកល្បង

**មាត្រា ១១៧.-** និយមន័យ និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង

តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ការព្យួរទោសសាកល្បង មានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង ។

**មាត្រា ១១៨.-** រយៈពេលនៃការសាកល្បង

តុលាការកំណត់រយៈពេលនៃការសាកល្បង។ រយៈពេលនេះមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ ទេ ។

**មាត្រា ១១៩.-** វិធានការត្រួតពិនិត្យ

វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ :

១-ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែល

ព្រះរាជអាជ្ញា បានប្រគល់អំណាចឱ្យ ។

២-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញា បានប្រគល់អំណាចឱ្យ ។

៣-ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញា បានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។

៤-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្ដូរអាសយដ្ឋានរបស់ខ្លួន ។

៥-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្ដូរមុខរបររបស់ខ្លួន ។

៦-ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស ។

**មាត្រា ១២០.-** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត

កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅ :

១-បំពេញសកម្មភាពខាងវិជ្ជាជីវៈ ។

២-ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

៣-រស់នៅក្នុងទីកន្លែងណាមួយជាកំណត់ ។

៤-ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល ។

៥-បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។

៦-ធ្វើការជួសជុលការខូចខាតដែលបណ្ដាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន ។

៧-បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្ដន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន ។

៨-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់ ។

៩-មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់ ។

១០-មិនត្រូវសេពគប់បនល្បែង ។

១១-មិនត្រូវសេពគប់គ្រឿងស្រវឹង ។

១២-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ ។

១៣-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត ។

## មាត្រា ១២១.- ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

នៅគ្រប់ពេលវេលា តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន ។

តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

## មាត្រា ១២២.- ការដកហូតការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ :

១-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ ។

២-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត ។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក ។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក ។

តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២៣.-** ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បង ការផ្តន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូតដែលមានសេចក្តីសម្រេចដកហូតទេ ។

## ផ្នែកទី ៤
## ការផ្អាកការប្រកាសទោស

**មាត្រា ១២៤.-** លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

ក្នុងករណីចោទប្រកាន់ពីបទមជ្ឈិម តុលាការក្រោយពីបានប្រកាសថា ជនជាប់ចោទមានពិរុទ្ធ អាចផ្អាកការប្រកាសទោស ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ និង

-ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ។

**មាត្រា ១២៥.-** សេចក្តីសម្រេចនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោសអាចត្រូវបង្គាប់បាន លុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ ។

តុលាការកំណត់នៅក្នុងសាលក្រម ឬសាលដីកានូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស ។

សេចក្តីសម្រេចអំពីទោសត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយសេចក្តីសម្រេចផ្អាក ។

**មាត្រា ១២៦.-** សវនាការពិនិត្យរឿងដែលបង្គង់

នៅពេលសវនាការពិនិត្យរឿងដែលបង្គង់នេះ តុលាការសម្រេចអំពីទោស ។

## ផ្នែកទី ៥
## របបពាក់កណ្ដាលសេរីភាព

**មាត្រា ១២៧.-** លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ តុលាការអាចសម្រេចថា ទោសត្រូវអនុវត្តក្រោមរបបពាក់កណ្ដាលសេរីភាព ដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្ដុះបណ្ដាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ ។

**មាត្រា ១២៨.-** បែបបទនៃរបបពាក់កណ្ដាលសេរីភាព

ទណ្ឌិតដែលស្ថិតនៅក្រោមរបបពាក់កណ្ដាលសេរីភាព ត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារ ក្នុងរយៈពេលជាកំណត់ ។

តុលាការកំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបានអនុញ្ញាតឱ្យមានអវត្តមាននៅក្នុងពន្ធនាគារ ។

**មាត្រា ១២៩.-** ការគិតបញ្ចូលរយៈពេលនៃពាក់កណ្ដាលសេរីភាពទៅក្នុងទោស

រយៈពេលនៃពាក់កណ្ដាលសេរីភាព ត្រូវគិតបញ្ចូលទៅក្នុងថិរវេលានៃទោសដែលកំពុងអនុវត្ត ។

**មាត្រា ១៣០.-** ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព

នៅគ្រប់ពេល តុលាការអាចរៀបចំរយៈពេលនៃពាក់កណ្ដាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្ដាលសេរីភាព តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣១.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃពាក់កណ្ដាលសេរីភាព ។

## ផ្នែកទី ៦
## ការបែងចែកទោសជាប្រភាគ

**មាត្រា ១៣២.-** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ តុលាការអាចសម្រេចថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម។

**មាត្រា ១៣៣.-** បែបបទនៃការបែងចែកទោសជាប្រភាគ

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ (មួយ) ខែ ទេ ។ ចិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី ២ (ពីរ) ឆ្នាំ ទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស ។

តុលាការកំណត់ក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ ។

**មាត្រា ១៣៤.-** ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ

នៅគ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣៥.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មក

ពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស ។

# ជំពូកទី ៤
# វិធានអនុវត្តនៅក្នុងករណីបទល្មើសត្រួតគ្នា
## ផ្នែកទី ១
## វិធានទូទៅ

**មាត្រា ១៣៦.-** បទល្មើសត្រួតគ្នា

មានបទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ មុនពេលដែលបុគ្គលនេះត្រូវបានផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត ។

**មាត្រា ១៣៧.-** ការចោទប្រកាន់តែមួយ

កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវប្រកាសឡើង ។ ប៉ុន្តែ កាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។

ទោសនីមួយៗ ដែលប្រកាសត្រូវចាត់ទុកថាជាទោសរួម ចំពោះបទល្មើសដែលត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ អនុវត្តទៅលើបទល្មើសនីមួយៗ ។

**មាត្រា ១៣៨.-** ការចោទប្រកាន់ដាច់ពីគ្នា

នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។ ប៉ុន្តែ តុលាការចុងក្រោយដែលត្រូវសម្រេច អាចប្រកាសឱ្យអនុវត្តទោសស្រូបបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា ។

ដើម្បីអនុវត្តមាត្រានេះ នៅក្នុងករណីទោសដែលច្បាប់កំណត់ ជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ (សាមសិប) ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ ។

ការព្យួរទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែលត្រួតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោសនៃប្រភេទដូចគ្នាដែលគ្មានការព្យួរទោសទេ ។

## ផ្នែកទី ២
## វិធានដោយឡែក

**មាត្រា ១៣៩.-** អានុភាពនៃការលើកលែងទោស និងការបន្ធូរបន្ថយទោសលើការស្រូបទោស

កាលបើទោសជាកម្មវត្ថុនៃវិធានការលើកលែងទោស និងបន្ធូរបន្ថយទោសដូចមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែគិតគូរអំពីទោសដែលជាលទ្ធផលនៃការលើកលែងទោស និងបន្ធូរបន្ថយទោស ដើម្បីអនុវត្តវិធានស្តីពីការស្រូបបញ្ចូលគ្នានៃទោស ។

ចិរវេលានៃការបន្ធូរបន្ថយទោស ត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃទោសទៅថ្ងៃមុខ ក្រោយការស្រូបទោស ។

**មាត្រា ១៤០.-** ការបូកបញ្ចូលគ្នានៃទោសពិន័យ

ជាបដិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះ ត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យដែលប្រកាសឡើងចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

**មាត្រា ១៤១.-** ការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាសចំពោះករណីរត់ចេញពីពន្ធនាគារ

ក្នុងករណីផ្តន្ទាទោសពីបទរត់ចេញពីពន្ធនាគារ ទោសដែលប្រកាសពីបទនេះ

ត្រូវប្តូកជាមួយនឹងទោសដែលប្រកាសឡើង ចំពោះបទល្មើសដែលនាំឱ្យមានការឃុំខ្លួនជននោះ ដោយមិនអាចមានការស្រូបចូលគ្នា ។

# ជំពូកទី ៥
# មូលហេតុនានាដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស
## ផ្នែកទី ១
## អាជ្ញាយុកាលនៃទោស

**មាត្រា ១៤២.-** អានុភាពនៃអាជ្ញាយុកាល

នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។

**មាត្រា ១៤៣.-** ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន

ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ ។

ក្រៅពីបទល្មើសខាងលើ ច្បាប់ពិសេសអាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបាន ។

**មាត្រា ១៤៤.-** អាជ្ញាយុកាលនៃទោស

ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ ។

ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ ។

ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ ។

**មាត្រា ១៤៥.-** ចំណុចចាប់ផ្តើមនៃថិរវេលា

ថិរវេលា ២០ (ម្ភៃ) ឆ្នាំ ៥ (ប្រាំ) ឆ្នាំ និង ១ (មួយ) ឆ្នាំ ខាងលើ ដែលមានចែងនៅក្នុងមាត្រា ១៤៤ (អាជ្ញាយុកាលនៃទោស) នៃក្រមនេះ ចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោស បានក្លាយទៅជាស្ថាពរ ។

**មាត្រា ១៤៦.-** អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើតចេញពីសេចក្តីសម្រេចព្រហ្មទណ្ឌ

កាតព្វកិច្ចដែលមានប្រភេទជារដ្ឋប្បវេណី និងដែលមានប្រភពចេញមកពីសេចក្តីសម្រេចព្រហ្មទណ្ឌដែលក្លាយជាស្ថាពរ ផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។

## ផ្នែកទី ២
## ការអនុគ្រោះទោស

**មាត្រា ១៤៧.-** អានុភាពនៃការអនុគ្រោះទោស

ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬការលើកលែងទោស ដោយអនុលោមតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកលែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះនោះ ។

**មាត្រា ១៤៨.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការអនុគ្រោះទោស

ការអនុគ្រោះទោសមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៃព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការអនុគ្រោះទោសនោះ។

## ផ្នែកទី ៣
## ការលើកលែងទោសជាទូទៅ

**មាត្រា ១៤៩.-** អានុភាពនៃការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

ទោសមិនអាចយកមកអនុវត្តទេ ។

ទោសដែលកំពុងអនុវត្ត ត្រូវបានបញ្ចប់ ។

ប៉ុន្តែ ចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តី ដែលបានបង់រួចហើយ មិនអាចទារសំណងពីរដ្ឋវិញបានទេ ។

**មាត្រា ១៥០.-** ការលើកលែងទោសជាទូទៅ និងការដកការព្យួរទោស

កាលបើការព្យួរទោសពីមុន ត្រូវបានដកហូតដោយអានុភាពនៃការផ្តន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅចំពោះទោសខាងក្រោយនេះ បង្កើតឡើងវិញនូវផលប្រយោជន៍នៃការព្យួរទោសដែលមានពីមុន ។

**មាត្រា ១៥១.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការលើកលែងទោសជាទូទៅ

លើកលែងតែបទប្បញ្ញត្តិផ្ទុយនៃច្បាប់ ការលើកលែងទោសជាទូទៅ មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងការជួសជុលនៃការខូចខាតឡើយ ។

## ផ្នែកទី ៤
## ការរៀបចំទោស និងការលុបចោលទោសបន្ថែមខ្លះៗ

**មាត្រា ១៥២.-** លក្ខខណ្ឌនៃការកែប្រែទោសបន្ថែមខ្លះៗ

ក្នុងករណីផ្តន្ទាទោសបន្ថែមដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦, ៧, ១៤, ១៥ និង ១៦ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ តុលាការអាចបង្គាប់ឱ្យរៀបចំកែប្រែ ឬលុបចោលទោសមួយ ឬច្រើន ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ ៖

-ភាពច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ឈប់

-ព្យសនកម្ម ត្រូវបានជួសជុល និង

-សេចក្តីសម្រេចរៀបចំកែប្រែ ឬលុបចោល មានលក្ខណៈអនុគ្រោះឱ្យធ្វើការបញ្ចូលជនល្មើសទៅរស់នៅក្នុងសង្គមវិញ ។

តុលាការទទួលពាក្យប្តឹងពីអយ្យការតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមពាក្យប្តឹងរបស់ទណ្ឌិត ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ ទណ្ឌិត និងជាយថាហេតុ មេធាវីរបស់ជននេះ ។

**មាត្រា ១៥៣.-** ការធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ ឬខ្លះៗ

ក្នុងករណីដកសិទ្ធិពលរដ្ឋ តុលាការអាចធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ដែលរៀបរាប់នៅមាត្រា ៥៥ (សិទ្ធិពលរដ្ឋដែលអាចដកបាន) នៃក្រមនេះ ឬក៏សិទ្ធិខ្លះក្នុងចំណោមសិទ្ធិទាំងនេះ ។

**មាត្រា ១៥៤.-** ការរៀបចំកែប្រែ ឬការលុបចោលនូវការហាមឃាត់

តុលាការអាចរៀបចំកែប្រែ ឬលុបចោលនូវ :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ឬសកម្មភាពសង្គម ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ។

**មាត្រា ១៥៥.-** ការប្រគល់ឱ្យវិញនូវលិខិតបើកបរ

ក្នុងករណីព្យួរលិខិតបើកបរ តុលាការអាចបង្គាប់ឱ្យប្រគល់លិខិតបើកបរនេះទៅម្ចាស់វិញ ។

**មាត្រា ១៥៦.-** ការកែប្រែវិធានការនៃការហាមឃាត់ចំពោះការស្នាក់នៅ

ក្នុងករណីផ្តន្ទាទោសហាមឃាត់ចំពោះការស្នាក់នៅ តុលាការអាចកែប្រែបែបបទនៃវិធានការតាមដាន ។

ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យស្នាក់នៅជាបណ្តោះអាសន្នសម្រាប់រយៈពេលដែលមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ នៅក្នុងទីកន្លែងដែលហាមឃាត់ ។ ព្រះរាជអាជ្ញាជូនព័ត៌មានអំពីកិច្ចនេះដល់តុលាការ ។

សេចក្តីសម្រេចរបស់តុលាការ និងព្រះរាជអាជ្ញា ត្រូវបានជូនដំណឹងដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ១៥៧.-** ការកែប្រែការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការអាចលុបចោលការហាមឃាត់ ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ តុលាការអាចគ្រោងទុកនូវលក្ខខណ្ឌខ្លះៗ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ។

**មាត្រា ១៥៨.-** ការកែប្រែការហាមឃាត់ការចូលមកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការអាចលុបចោលការហាមឃាត់ចំពោះការស្នាក់នៅ និងការចូលក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដល់ទណ្ឌិតបរទេស ។

ប៉ុន្តែ ជាបឋម ព្រះរាជអាជ្ញាត្រូវតែទទួលយោបល់ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជូនដំណឹងអំពីយោបល់នេះទៅតុលាការ ។

យោបល់នេះមិនបង្ខំឱ្យតុលាការត្រូវតែអនុវត្តតាមទេ ។

**មាត្រា ១៥៩.-** ការកែប្រែការបណ្តេញចេញ ការបិទ ការហាមឃាត់ការធ្វើអាជីវកម្ម

តុលាការអាចរៀបចំកែប្រែទោស ឬបញ្ចប់នូវទោសដូចខាងក្រោមនេះ :

១-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

២-ការបិទគ្រឹះស្ថាន ។

៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

# ជំពូកទី ៦
# ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្ដន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបាន បន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្ដាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ចិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល

បទប្បញ្ញត្តិស្តីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤-ជួសជុលព្យសនកម្មដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្ដន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។ល

## ផ្នែកទី ២
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែង

សម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ។

## ជំពូកទី ៧
## ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល
### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦៧.-** ទោសដែលត្រូវរងដោយនីតិបុគ្គល

ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលមានដូចតទៅ :

១-ទោសពិន័យក្នុងឋានៈជាមូលទោស ។

២-ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមនេះ ។

### ផ្នែកទី ២
### ទោសបន្ថែម

**មាត្រា ១៦៨.-** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ :

១-ការរំលាយចោល ។

២-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។

៧-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

១១-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន ។

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ ។

**មាត្រា ១៧០.-** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

សេចក្ដីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ សេចក្ដីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។

ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិច អាណត្តិគាហកតុលាការធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្ដឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់យោបល់របស់តំណាងអយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ ។

**មាត្រា ១៧២.-** ការហាមឃាត់ចំពោះការធ្វើសកម្មភាព

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់ចិរវេលា ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់ ។

**មាត្រា ១៧៣.-** ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ

ទោសបណ្ដេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួម ដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំ ដោយ :

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសនេះ អាចជាស្ថាពរ ឬជាបណ្ដោះអាសន្ន សម្រាប់ចិរវេលាមួយមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ១៧៤.-** ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ឱ្យធ្វើការដាក់ប្រាក់សន្សំ

អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ការហាមឃាត់នេះ នាំឱ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវដើម្បីឱ្យដាក់ឧបករណ៍អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុនមូលបត្រ ។

ការហាមឃាត់នេះនាំឱ្យមានការហាមឃាត់ចំពោះការផ្សព្វផ្សាយជាសាធារណៈដែរ ។

**មាត្រា ១៧៥.-** ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន

ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ចំពោះការហាមឃាត់ប្រើប្រាស់បណ្ណទូទាត់ ក៏ដូចគ្នាដែរ ។

**មាត្រា ១៧៦.-** ការបិទគ្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ។

ទោសនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ១៧៧.-** ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយ ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬជាបណ្តោះអាសន្នក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ១៧៨.-** ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស

កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែបទប្បញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត ។

រដ្ឋអាចលក់ ឬបំផ្លាញចោលវត្ថុរឹបអូសនៅក្នុងទម្រង់ដែលមានចែងសម្រាប់ការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ ។ ច្បាប់អាចចែងអំពីការបំផ្លាញចោលនូវវត្ថុខ្លះផងដែរ ។

កាលបើវត្ថុរឹបអូសមិនត្រូវបានចាប់យកទេ ហើយនិងមិនអាចប្រគល់ឱ្យបានទេនោះ ទណ្ឌិតត្រូវចេញសងតម្លៃនៃវត្ថុរឹបអូសនេះ ។ តម្លៃនេះត្រូវបានកំណត់ដោយតុលាការ ។ វិធានការដើម្បីប្រមូលប្រាក់នេះ ត្រូវធ្វើឡើងដូចក្នុងរឿងបង្ខំដល់រូបកាយដែរ ។

## មាត្រា ១៧៩.- ការរឹបអូស និងសិទ្ធិតតិយជន

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចខាងក្រោមនេះ :

១-ឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើតឡើង ។

ក៏ប៉ុន្តែ ការរឹបអូសមិនអាចត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

## មាត្រា ១៨០.- ការបិទផ្សាយសេចក្តីសម្រេច

ការបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រាប់រយៈពេលមួយដែលកំណត់ឡើងដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ។ ការបិទផ្សាយ អាចទាំងស្រុងតាមសម្រង់ ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ក្នុងករណីដែលដកបំបាត់ចេញ លាក់បំបាំង ឬហែកចោលសេចក្តីប្រកាសបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្តងទៀត ។ សោហ៊ុយនៃការបិទផ្សាយនេះត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោល លាក់បំបាំង ឬហែកចោល ។

**មាត្រា ១៨១.-** ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍

ទោសផ្សាយសេចក្តីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ ។ ការផ្សាយនេះ មិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ។ ការផ្សាយនេះ អាចផ្សាយទាំងស្រុង តាមសម្រង់ ឬតាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងថិរវេលាដែលកំណត់ដោយតុលាការ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់នីតិបុគ្គល ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មានមិនអាចបដិសេធការចុះផ្សាយនេះបានទេ ។

**មាត្រា ១៨២.-** ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងរូបវន្តបុគ្គល និងនីតិបុគ្គល

បទប្បញ្ញត្តិនៃមាតិកាទី ១ មាតិកាទី ២ និងមាតិកាទី ៣ នៃគន្ថីទី ១ នៃក្រមនេះដែលទាក់ទងនឹងរូបវន្តបុគ្គល ត្រូវអនុវត្តទៅលើនីតិបុគ្គលក្នុងកម្រិតដែលបទប្បញ្ញត្តិនេះ មិនផ្ទុយជាមួយនឹងបទប្បញ្ញត្តិនៃជំពូកនេះ ។

# ឧបសម្ព័ន្ធ២

# ព្រះរាជក្រម

នស/រកម/០៨០៧/០២៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាម ទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ក្រមនីតិវិធីព្រហ្មទណ្ឌ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៤.** – **ការចាប់ផ្តើមដំណើរការនៃបណ្តឹងអាជ្ញាដោយអយ្យការ**

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ ។

អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ។

**មាត្រា ៥.** – **ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ**

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យប្តឹងដោយមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តដោយមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ ។

យុត្តាធិការព្រហ្មទណ្ឌក៏អាចទទួលបណ្តឹងពីមន្ត្រីរាជការ ឬភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកបានប្រគល់អំណាចឱ្យផងដែរ ។

**មាត្រា ៦.** – **ការដាក់ពាក្យប្តឹងទាមទារដោយជនរងគ្រោះ**

បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចដាក់ពាក្យប្តឹងបាន។ពាក្យប្តឹងសាមញ្ញ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ ។

នៅក្នុងករណីដែលពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទៅតាមរបៀបដូចដែលមានចែងទុកដោយមាត្រា ៤១ (ការតម្កល់រឿងទុកឥតចាត់ការ) នៃក្រមនេះ ។

**មាត្រា ៧.** – **ការរលត់នៃបណ្តឹងអាជ្ញា**

មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ :

១-មរណភាពនៃជនល្មើស ។

២-ការផុតអាជ្ញាយុកាល ។

៣-ការលើកលែងទោសជាទូទៅ ។

៤-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ។

៥-អាជ្ញាអស់ជំនុំ ។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់ ។

**មាត្រា ៨. – មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា**

កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរ ៖

១-ដោយការសម្រុះសម្រួលជាមួយរដ្ឋ ។

២-ដោយការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។

៣-ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្រុះសម្រួល ។

**មាត្រា ៩. – ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់**

បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតអាជ្ញាយុកាលបានទេ ។

**មាត្រា ១០. – អាជ្ញាយុកាលនៃបទល្មើស**

លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះចេញ ថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ ៖

-១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម

-១ (មួយ) ឆ្នាំ ចំពោះបទលហុ

**មាត្រា ១១. – ការផ្តាច់រយៈពេលនៃអាជ្ញាយុកាល**

ថិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស ។ អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្តើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាលតាមការវែកញែកនៃមាត្រា ១០ (អាជ្ញាយុកាលនៃបទល្មើស) នៃក្រមនេះ ។ ថិរវេលាថ្មីអាចយកទៅជំទាស់បាន ចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ ។

**មាត្រា ១២. – អាជ្ញាអស់ជំនុំ**

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ ។

# ជំពូកទី ៤
# សេចក្តីសម្រេច
## ផ្នែកទី ១
## ការប្រកាសសាលក្រម

**មាត្រា ៣៤៧.** – ការប្រកាសសាលក្រម

សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ។ នៅក្នុងករណីខាងក្រោយនេះ ប្រធានសវនាការជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមាន អំពីថ្ងៃដែលត្រូវប្រកាសសាលក្រម ។

**មាត្រា ៣៤៨.** – ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ

តុលាការអាចសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម ។

ក្នុងករណីដែលតុលាការសម្រេចរួមជាក្រុម ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះបង្កើតបានជាបទមជ្ឈិម ឬបទលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជម្រះសេចក្តីដដែល ។

ក្នុងករណីដែលតុលាការសម្រេចដោយមានចៅក្រមតែម្នាក់គត់ ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតបានជាបទឧក្រិដ្ឋ តុលាការនោះបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ ។

**មាត្រា ៣៤៩.** – ដែននៃការប្តឹងទៅតុលាការចំពោះបុគ្គល

តុលាការអាចជំនុំជម្រះបុគ្គលដែលបញ្ជូនទៅចំពោះមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ។

ប្រសិនបើបុគ្គលណាដែលកោះហៅឱ្យចូលទៅចំពោះមុខតុលាការក្នុងឋានៈជាសាក្សី អាចត្រូវចោទប្រកាន់ក្នុងឋានៈជាជនដៃដល់ ឬអ្នកសមគំនិត បុគ្គលនោះនឹងអាចត្រូវជំនុំជម្រះបានក្រោយពីត្រូវបានចោទប្រកាន់ដូចមានចែងនៅមាត្រា ៤៣ (ការចោទប្រកាន់) តែប៉ុណ្ណោះ ។

**មាត្រា ៣៥០.** – ការប្រកាសពីពិរុទ្ធភាព

តុលាការពិនិត្យមើលថា :

-អំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ

-ជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់លើខ្លួនឬទេ ។

ប្រសិនបើពិនិត្យឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ ។

ប្រសិនបើតុលាការយល់ឃើញថាអំពីនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ ។

**មាត្រា ៣៩១.** – អវត្តមានរបស់ជនជាប់ចោទ

វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច ។

ក្នុងករណីជនជាប់ចោទអវត្តមាន តុលាការត្រូវប្រកាសទោសដែលយល់ឃើញថាត្រឹមត្រូវ ប្រសិនបើខ្លួនប្រកាសថាជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់នោះមែន ។

**មាត្រា ៣៩២.** – ការបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ

ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបញ្ចប់នៅពេលប្រកាសសាលក្រម ។

**មាត្រា ៣៩៣.** – ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន ចេញដោយតុលាការ

ប្រសិនបើតុលាការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ យ៉ាងតិច ដោយគ្មានការព្យួរទោស តុលាការតាមសេចក្តីសម្រេចពិសេស និងដោយមានសំអាងហេតុ អាចចេញនៅក្នុងពេលសវនាការ :

-ដីកាបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន

-ដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទអវត្តមាន ។

ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន មានអានុភាពអនុវត្តភ្លាមៗ ។

ដីកាទាំងនោះមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណរបស់ពិរុទ្ធជន

-ប្រភេទនៃទណ្ឌកម្ម និងអត្ថបទច្បាប់ដែលជាមូលដ្ឋាននៃការផ្តន្ទាទោសនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកានេះត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមនេះ និងបោះត្រាផង ។

ពិរុទ្ធជនដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួននោះ ត្រូវតែបានគេនាំទៅបង្ហាញខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុតនៅមុខព្រះរាជអាជ្ញានាទីកន្លែងចាប់ខ្លួនដែលឱ្យដំណឹងដល់សាមីខ្លួនអំពីដីកានេះ និងធ្វើការឃុំខ្លួន ។

កាលណាសាលក្រមត្រូវបានសម្រេចដោយកំបាំងមុខនោះ ពិរុទ្ធជនដែលសម្រេចចិត្តថាប្តឹងទាស់ត្រូវតែចូលបង្ហាញខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត នៅមុខតុលាការដែលបានប្រកាសសាលក្រម ។ ពិរុទ្ធជនអាចធ្វើពាក្យសុំនៅក្រៅឃុំ ។ តុលាការត្រូវសម្រេចដូចដែលមានចែងនៅមាត្រា ៣០៧ (បណ្តឹងសុំដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទដែលជាប់ឃុំ) នៃក្រមនេះ ។

**មាត្រា ៣៩៤. – ការប្រគល់វត្ថុដែលចាប់យក**

តុលាការមានសមត្ថកិច្ចសម្រេចអំពីការប្រគល់វត្ថុដែលចាប់យក ។

**មាត្រា ៣៩៥. – ការសម្រេចអំពីប្រយោជន៍ផ្នែករដ្ឋប្បវេណី**

នៅក្នុងសាលក្រមតែមួយជាមួយរឿងព្រហ្មទណ្ឌ តុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ។ តុលាការវិនិច្ឆ័យអំពីភាពអាចទទួលបាននៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយសម្រេចអំពីពាក្យប្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទៅលើជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ កាលណាតុលាការមិនទាន់អាចសម្រេចបានលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីទេ តុលាការអាចបង្អង់ទៅសវនាការលើកក្រោយ និងអាចសម្រេចឱ្យប្រាក់បណ្ដោះអាសន្ន ។

បុគ្គលដែលត្រូវផ្ដន្ទាទោសក្នុងបទល្មើសតែមួយជាមួយគ្នានោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

**មាត្រា ៣៩៦. – អវត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការ**

ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ញើពាក្យសុំទាមទារសំណងការខូចខាតនៅមុនពេលសវនាការ តែអវត្តមាននៅពេលសវនាការហើយប្រសិនបើតុលាការប្រកាសថាមានពិរុទ្ធលើជនជាប់ចោទ នោះតុលាការត្រូវតែសម្រេចឱ្យសងការខូចខាតដល់ជនរងគ្រោះដោយផ្អែកលើអត្ថន័យនៃសំណុំរឿង ។

**មាត្រា ៣៩៧. – ការសរសេរសាលក្រម : ផ្នែកសំអាងហេតុ និងផ្នែកសម្រេច**

គ្រប់សាលក្រមត្រូវមានពីរផ្នែក :

-ផ្នែកសំអាងហេតុពោលគឺទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្ដីសម្រេច ។

-ផ្នែកសម្រេចពោលគឺសេចក្ដីសម្រេចរបស់តុលាការ ។

អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ ។ តុលាការត្រូវពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកនៅពេលសវនាការ ។

នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី ។

ផ្នែកសេចក្ដីសម្រេចត្រូវចុះនិទ្ទេស អំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តខុស អត្ថបទច្បាប់ដែលអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី ។

**មាត្រា ៣៩៨. – និទ្ទេសដែលត្រូវចុះលើសាលក្រម**

សាលក្រមត្រូវចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជី ។

សាលក្រមត្រូវមានចុះសេចក្ដីដូចតទៅ ៖

-កាលបរិច្ឆេទនៃសវនាការ

-កាលបរិច្ឆេទនៃការប្រកាសសាលក្រម

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជំនុំជម្រះ

-ឈ្មោះ និងឋានៈតំណាងអយ្យការ

-ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី

-ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទ របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

-ឈ្មោះរបស់មេធាវី ។

ក្រោយពីបានចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជីរួច សាលក្រមដើមត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីយ៉ាងយូរបំផុត ៨ (ប្រាំបី) ថ្ងៃ ក្រោយការប្រកាសសាលក្រម ។ ការិយាល័យក្រឡាបញ្ជីត្រូវតែរក្សាទុកសាលក្រមដើមជានិច្ច ។ ក្រឡាបញ្ជីអាចផ្ដល់ច្បាប់ចម្លងនៃសាលក្រមជាអាទិ៍ក្នុងករណីមានឧទ្ធរណ៍ ។

**មាត្រា ៣៥៩.** – ការប្រកាសសាលក្រមនៅក្នុងសវនាការសាធារណៈ

គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ ។ ផ្នែកនៃសេចក្ដីសម្រេចត្រូវអានដោយសម្លេងខ្លាំងៗ ដោយប្រធានសវនាការ ។

## ផ្នែកទី ២
## ប្រភេទនៃសាលក្រម

**មាត្រា ៣៦០.** – សាលក្រមចំពោះមុខ

ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ នោះសាលក្រមជាសាលក្រមចំពោះមុខជនជាប់ចោទ ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវឱ្យដំណឹងដល់ជននេះទេ ។ សាលក្រមចំពោះមុខអាចត្រូវប្ដឹងឧទ្ធរណ៍បាន ។

សាលក្រមនៅតែជាសាលក្រមចំពោះមុខដដែល ទោះបីជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ ។

សាលក្រមក៏ជាសាលក្រមចំពោះមុខដែរ កាលណាជនជាប់ចោទត្រូវបានសួរចម្លើយនៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ៣០៩ (ជនជាប់ចោទដែលពុំអាចចូលបង្ហាញខ្លួន) នៃក្រមនេះ ។

# គន្ថីទី ៨
# នីតិវិធីប្រតិបត្តិ
## មាតិកាទី ១
## បទប្បញ្ញត្តិទូទៅ
### ជំពូកទោល
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៤៩៦. –** ការអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី

ការអនុវត្តទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតផ្តើមរបស់អយ្យការ ។

ការអនុវត្តទណ្ឌកម្មរដ្ឋប្បវេណីត្រូវតែធ្វើតាមគំនិតផ្តើមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

**មាត្រា ៤៩៧. –** សេចក្តីសម្រេចស្ថាពរ

អយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់តុលាការ បានក្លាយទៅជាស្ថាពរ ។

រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ ។

**មាត្រា ៤៩៨. –** ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី

ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារ នៅក្រោមឱវាទរបស់អយ្យការ ។ ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីដែលប្រមូលបាននេះ ត្រូវបង់ចូលថវិការដ្ឋ ។

គ្រប់សេចក្តីសម្រេចផ្តន្ទាទោសជាស្ថាពរ មានតំលៃជាបញ្ជាឱ្យបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី ។

**មាត្រា ៤៩៩. –** ការសុំកងកម្លាំងសាធារណៈ

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា អាចសុំកងកម្លាំងសាធារណៈ ដើម្បីធានារ៉ាប់រងការអនុវត្តទោស ។

**មាត្រា ៥០០. –** ការលំបាកទាក់ទងនឹងការអនុវត្តទោស

ការលំបាកទាំងឡាយដែលទាក់ទងនឹងការអនុវត្តទោស ត្រូវតែលើកជូនតុលាការជាន់ដំបូង ឬតុលាការជាន់ខ្ពស់ ដែលបានសម្រេចផ្តន្ទាទោសនោះ ដោះស្រាយ ។

តុលាការទទួលបណ្តឹង តាមពាក្យប្តឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ ។ តុលាការនេះសម្រេចនៅពេលសវនាការសាធាណៈ ក្រោយពីបានស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ ។

ការអនុវត្តទោសអាចត្រូវបានល្បួរដោយតុលាការ ។

**មាត្រា ៥០១.** – ពាក្យសុំឱ្យស្រួបទោសបញ្ចូលគ្នា

ពាក្យសុំឱ្យស្រួបទោសបញ្ចូលគ្នា ត្រូវលើកនៅមុខតុលាការដែលបានសម្រេចចុងក្រោយគេ ។

តុលាការនេះទទួលបណ្តឹង តាមពាក្យប្តឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ ។

## មាតិកាទី ២

## ការប្រតិបត្តការឃុំខ្លួនបណ្តោះអាសន្ន និងទោសដកហូតសេរីភាព

## ជំពូកទី ១

## វិធាននានាក់ទងនឹងការឃុំខ្លួន

**មាត្រា ៥០២.** – ការគណនាចិរវេលានៃការដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ថ្ងៃ មានចិរវេលា ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ក្នុង ១ (មួយ) ខែ មានចិរវេលា ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី ១ (មួយ) ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត ។

ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច ។

**មាត្រា ៥០៣.** – ការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងចិរវេលានៃទោសដែលបានប្រកាស ឬជាយថាហេតុនៃចិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រួបទោសបញ្ចូលគ្នា ។

**មាត្រា ៥០៤.** – ការរៀបចំពន្ធនាគារ

ការរៀបចំ និងរបបផ្ទៃក្នុងនៃពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងដែលគ្រប់គ្រងពន្ធនាគារ ។

ប្រកាសនេះកំណត់ផងដែរ អំពីលក្ខខណ្ឌនៃការបែងចែកទណ្ឌិតនៅតាមពន្ធនាគារ និងមណ្ឌលឃុំខ្លួននានា អំពីបែបបទអនុវត្តទោសដកហូតសេរីភាព និងអំពីរបបឃុំខ្លួន ។

**មាត្រា ៥០៥. – បញ្ជីជនជាប់ឃុំ**

គ្រប់ពន្ធនាគារ និងមណ្ឌលឃុំខ្លួនទាំងអស់ ត្រូវមានបញ្ជីមួយដែលចុះនិទ្ទេសអំពីអត្តសញ្ញាណបុគ្គលឃុំខ្លួន កាលបរិច្ឆេទឃុំខ្លួន និងកាលបរិច្ឆេទដោះលែង ។ បញ្ជីនេះត្រូវបានត្រួតពិនិត្យជារឿយៗ ដោយអយ្យការ ។ ទំព័រនីមួយៗ ត្រូវតែចុះទិដ្ឋាការដោយអយ្យការ ។

គ្រប់ភ្នាក់ងារនៃរដ្ឋបាលពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវតែជូនបញ្ជីទៅចៅក្រមពិនិត្យមើលតាមការស្នើសុំ ព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ចតាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

**មាត្រា ៥០៦. – លិខិតឃុំខ្លួន**

គ្មានភ្នាក់ងាររដ្ឋបាលពន្ធនាគារណា អាចទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការបានឡើយ ។

ភ្នាក់ងាររដ្ឋបាលពន្ធនាគារណាដែលបានទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការទេនោះ ត្រូវជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់ ។

**មាត្រា ៥០៧. – ការឃុំខ្លួនដោយខុសច្បាប់**

គ្រប់ចៅក្រមទាំងអស់ដែលបានទទួលបណ្តឹងស្តីពីការឃុំខ្លួនបុគ្គលណាម្នាក់ដោយខុសច្បាប់ ត្រូវធ្វើការផ្ទៀងផ្ទាត់ជាចាំបាច់ភ្លាម ។

**មាត្រា ៥០៨. – ការបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំ**

គ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ត្រូវតែបង្ហាញខ្លួនជនជាប់ឃុំដល់ចៅក្រមតាមការស្នើសុំ ព្រមទាំងដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ច តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

**មាត្រា ៥០៩. – អធិការកិច្ចពន្ធនាគារ**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរត្រូវធ្វើអធិការកិច្ចលើពន្ធនាគារជាប្រចាំ ។

**មាត្រា ៥១០. – ការសន្ទនារបស់ជនជាប់ឃុំជាមួយនឹងមេធាវីរបស់ខ្លួន**

ជនជាប់ឃុំត្រូវតែមានសិទ្ធិសន្ទនាជាសម្ងាត់ជាមួយនឹងមេធាវីរបស់ខ្លួន ។

**មាត្រា ៥១១. – ការផ្តល់ដំណឹងដល់ព្រះរាជអាជ្ញាក្នុងករណីមានឧប្បត្តិហេតុធ្ងន់ធ្ងរ**

គ្រប់ឧប្បត្តិហេតុធ្ងន់ធ្ងរនៅក្នុងពន្ធនាគារ ក្នុងមណ្ឌលឃុំខ្លួន ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ។

ក្នុងករណីដែលអ្នកទោសរត់ចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួន នោះព្រះរាជអាជ្ញាចេញបញ្ជាស្វែងរកចាប់ខ្លួន និងចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្តបញ្ជាស្វែងរកចាប់ខ្លួន ដោយអនុលោមតាមបញ្ញត្តិ ដែលចែងក្នុងមាត្រា ១៩៦ (ដីកាបង្គាប់ឱ្យចាប់ខ្លួន) និងមាត្រាបន្តបន្ទាប់ នៃក្រមនេះ ។

## ជំពូកទី ២
## ការដោះលែងដោយមានលក្ខខណ្ឌ

**មាត្រា ៥១២.** – លក្ខខណ្ឌទាក់ទងនឹងគំនិតមារយាទ

គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឱ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន ។

**មាត្រា ៥១៣.** – លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចរាល់ហើយ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ឱ្យដល់ទណ្ឌិត ដែលទទួលរងទោសជាប់ពន្ធនាគារ :

- ចំនួនពាក់កណ្តាលនៃទោស ប្រសិនបើទោសនោះតិចជាង ឬស្មើ ១ (មួយ) ឆ្នាំ
- ចំនួនពីរភាគបីនៃទោស ក្នុងករណីផ្សេងទៀត ។

ទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតបានទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ (ម្ភៃ) ឆ្នាំ រួចមកហើយ ។

**មាត្រា ៥១៤.** – អាជ្ញាធរមានសមត្ថកិច្ចសម្រាប់ផ្តល់ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ ត្រូវផ្តល់ឱ្យដោយប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួន ។ ប្រធានតុលាការនេះ សម្រេចក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌ ។

គណៈកម្មការជាតិរួមមាន :

- សមាជិក ២ (ពីរ) រូប ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែល ១ (មួយ) រូប ជាប្រធាន
- ប្រធានពន្ធនាគារ ឬតំណាង ជាសមាជិក ។

**មាត្រា ៥១៥.** – យោបល់របស់គណៈកម្មការជាតិ

ក្រោយពីបានទទួលពាក្យសុំដោះលែងដោយមានលក្ខខណ្ឌ ប្រធានតុលាការជាន់ដំបូងបញ្ជូនទៅគណៈកម្មការជាតិនូវ :

-ពាក្យសុំ

-សាលក្រម ឬសាលដីកាផ្តន្ទាទោស

-ជាយថាហេតុសាលក្រម និងសាលដីកាទាំងឡាយ ប្រសិនបើទណ្ឌិតទទួលទោសច្រើន

-ព្រឹត្តិបត្រលេខ១ នៃបញ្ជីថ្កោលទោស

-យោបល់ព្រះរាជអាជ្ញា

-គ្រប់លិខិតទាំងអស់ដែលមានប្រយោជន៍ ។

គណៈកម្មការជាតិបញ្ចេញយោបល់របស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ យោបល់នេះធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវធ្វើជូនទៅប្រធានតុលាការជាន់ដំបូងភ្លាម ។

**មាត្រា ៥១៦. – សេចក្តីសម្រេចទាក់ទងនឹងការដោះលែងដោយមានលក្ខខណ្ឌ**

ប្រធានតុលាការជាន់ដំបូងមិនត្រូវជាប់ជំពាក់នឹងយោបល់របស់គណៈកម្មការជាតិទេ ។

ប្រធានតុលាការសម្រេចតាមដីកាដោយមានសំអាងហេតុ ។

សេចក្តីសម្រេចរបស់ប្រធានតុលាការនេះ អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។ បណ្តឹងតវ៉ានេះ អាចធ្វើបានដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញានៃតុលាការសាមីតែប៉ុណ្ណោះ ។

កាលណាប្រធានតុលាការជាន់ដំបូង បង្គាប់ឱ្យដោះលែងដោយមានលក្ខខណ្ឌ សេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្តទេ នៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដែលចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ។ ប្រសិនបើមានការតវ៉ាសេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្តទេ រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍ ។

ប្រធានសាលាឧទ្ធរណ៍សម្រេចតាមដីកាដោយមានសំអាងហេតុ និងមិនអាចតវ៉ាបានឡើយ ។

**មាត្រា ៥១៧. – បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងដោយមានលក្ខខណ្ឌ**

សេចក្តីសម្រេចឱ្យដោះលែងដោយមានលក្ខខណ្ឌ ត្រូវកំណត់បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងទណ្ឌិត ។

សេចក្តីសម្រេចនេះកំណត់រយៈពេលសាកល្បង ដែលមិនអាចលើសពីថិរវេលានៃទោស ដែលនៅសល់មិនទាន់បានទទួលរងឡើយ ។

**មាត្រា ៥១៨. – ការដកហូតសេចក្តីសម្រេច**

ក្នុងករណីមានការផ្តន្ទាទោសជាថ្មី ឬក្នុងករណីមិនគោរពលក្ខខណ្ឌដែលកំណត់ដោយដីកាទេ ប្រធានតុលាការជាន់ដំបូងអាចដកហូតសេចក្តីសម្រេចរបស់ខ្លួនវិញបាន ។

**មាត្រា ៥១៩. – ការចាប់ខ្លួនទណ្ឌិតដែលត្រូវបានដោះលែង**

ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញានៃតុលាការសាមី អាចបង្គាប់ឱ្យចាប់ខ្លួនទណ្ឌិតដែលបានដោះលែងនោះបាន ។ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ប្រធានតុលាការជាន់ដំបូងភ្លាម ។

**មាត្រា ៥២០. – ការដកហូតការដោះលែងដោយមានលក្ខខណ្ឌ**

ក្នុងករណីដកហូតការដោះលែងដោយមានលក្ខខណ្ឌ ទណ្ឌិតត្រូវទទួលទោសរបស់ខ្លួនដែលនៅសេសសល់ ។

រយៈពេលសេសសល់ ត្រូវគិតចាប់ពីពេលដែលទណ្ឌិតបានទទួលសេចក្ដីសម្រេចឱ្យដោះលែងដោយមានលក្ខខណ្ឌ ។

ប្រសិនបើទណ្ឌិតត្រូវបានចាប់ខ្លួនដោយអនុវត្តតាមមាត្រា ៥១៩ (ការចាប់ខ្លួនទណ្ឌិតដែលត្រូវបានដោះលែង) នៃក្រមនេះ រយៈពេលឃុំខ្លួនរហូតមកទល់នឹងសេចក្ដីសម្រេចដកហូតការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវយកមកគិតក្នុងថិរវេលានៃទោសដែលនៅសេសសល់ ។

**មាត្រា ៥២១. – ផលវិបាកនៃការមិនដកហូត**

ប្រសិនបើការដោះលែងដោយមានលក្ខខណ្ឌ មិនត្រូវបានដកហូតក្នុងរយៈពេលសាកល្បងទេ លុះផុតរយៈពេលសាកល្បងដែលកំណត់តាមមាត្រា ៥១៧ (បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងដោយមានលក្ខខណ្ឌ) នៃក្រមនេះ ការដោះលែងក្លាយទៅជាស្ថាពរ ។

ក្នុងករណីនេះទោសត្រូវចាត់ទុកថាបានទទួលតាំងពីថ្ងៃដោះលែងដោយមានលក្ខខណ្ឌមកម្ល៉េះ ។

**មាត្រា ៥២២. – ប្រកាសរបស់ក្រសួងយុត្តិធម៌**

បែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលដោះលែងដោយមានលក្ខខណ្ឌត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តធម៌ ។ ប្រកាសនេះអាចប្រគល់ឱ្យស្ថាប័នសាធារណៈ ឬឯកជន នូវការយកចិត្តទុកដាក់ធានារ៉ាប់រងលើការបញ្ចូលទណ្ឌិតទៅក្នុងសង្គមវិញ ។

## មាតិកាទី ៣
## ការបង្ខំដល់រូបកាយ
## ជំពូកទោល
## ការបង្ខំដល់រូបកាយ

**មាត្រា ៥២៣. – ករណីអនុវត្តការបង្ខំដល់រូបកាយ**

ការបង្ខំដល់រូបកាយត្រូវអនុវត្តលើបុគ្គលដែលត្រូវផ្ដន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ហើយ

ដែលមិនបង់ ៖

-ប្រាក់ពិន័យ

-ប្រាក់ពន្ធនៃនីតិវិធី

-ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

**មាត្រា ៥២៤.** – ការអនុវត្តដោយពេញលក្ខណៈច្បាប់

ការបង្ខំដល់រូបកាយត្រូវអនុវត្តដោយពេញលក្ខណៈច្បាប់ ។ ការបង្ខំដល់រូបកាយមិនចាំបាច់ប្រកាសដោយតុលាការទេ ។

**មាត្រា ៥២៥.** – ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធី

ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង ។

ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិត ដើម្បីបង់ប្រាក់នោះ ហើយឱ្យដំណឹងថាប្រសិនបើមិនបង់ទេនោះ សាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយ ។ រយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃ ទេ ។

ការឱ្យដំណឹងត្រូវធ្វើ ៖

-ដោយផ្ទាល់មាត់ ឬ

-តាមផ្លូវរដ្ឋបាល ឬ

-តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។

ត្រូវតែមានធ្វើកំណត់ហេតុស្តីពីការឱ្យដំណឹងនេះ ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយទណ្ឌិត ។ ប្រសិនបើទណ្ឌិតមិនចេះចុះហត្ថលេខាទេ ទណ្ឌិតត្រូវផ្តិតម្រាមដៃ ។

**មាត្រា ៥២៦.** – បញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន

លុះផុតរយៈពេលកំណត់ ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់នោះទេ ព្រះរាជអាជ្ញាចេញបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន ។ ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបាន ដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពនៃសុខភាពរបស់ទណ្ឌិត ។

បញ្ជាឱ្យបង្ខំនិងឱ្យឃុំខ្លួនមានចុះនិទ្ទេសដូចតទៅ ៖

-អត្តសញ្ញាណនៃទណ្ឌិត

-ប្រភេទ និងការយោងនៃទណ្ឌកម្ម

-ការយោងនៃដីកាឱ្យដំណឹងដែលមានចែងនៅក្នុងមាត្រា ៥២៥ (ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធី) នៃក្រមនេះ

-ចំនួនទឹកប្រាក់ដែលមិនបានបង់

-ថិរវេលានៃការបង្ខិតដល់រូបកាយ ។

បញ្ញានេះត្រូវចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។

ព្រះរាជអាជ្ញាសុំឱ្យកម្លាំងសាធារណៈចាប់ និងឃុំខ្លួនទណ្ឌិត ។

**មាត្រា ៥២៧.** – ការតវ៉ានឹងបញ្ញាឱ្យបង្ខិត និងឱ្យឃុំខ្លួន

ប្រសិនបើពេលចាប់ខ្លួន ឃុំខ្លួន ឬក្រោយមកទណ្ឌិតតវ៉ាអំពីសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញា ទណ្ឌិតត្រូវបានគេនាំខ្លួនទៅជូនប្រធានតុលាការ ។

ប្រធានតុលាការពិនិត្យមើលនីត្យានុកូលភាពនៃបញ្ញាឱ្យបង្ខិត និងឱ្យឃុំខ្លួន ។ ក្នុងករណីមានការបំពានច្បាប់ ប្រធានតុលាការលុបចោលបញ្ញាឱ្យបង្ខិត និងឱ្យឃុំខ្លួននេះ ។

ប្រធានតុលាការសម្រេចតាមដីកាដោយមានសំអាងហេតុ ។

សេចក្ដីសម្រេចរបស់ប្រធានតុលាការជាន់ដំបូង អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ២ (ពីរ) ថ្ងៃ ។ បណ្ដឹងតវ៉ានេះអាចធ្វើបានដោយអគ្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញាអមសាលាដំបូង ឬទណ្ឌិត ។

កាលណាប្រធានតុលាការជាន់ដំបូងលុបចោលបញ្ញាឱ្យបង្ខិត និងឱ្យឃុំខ្លួន សេចក្ដីសម្រេចនេះគ្មានអានុភាពអនុវត្តទេ ក្នុងរយៈពេល ២ (ពីរ) ថ្ងៃ ដូចមានចែងនៅកថាខណ្ឌទី ៤ នៃមាត្រានេះ។ ប្រសិនបើមានការតវ៉ា សេចក្ដីសម្រេចនេះគ្មានអានុភាពអនុវត្ត រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍ ។

ប្រធានសាលាឧទ្ធរណ៍សម្រេចតាមដីកាមានសំអាងហេតុ និងមិនអាចតវ៉ាបាន ។

**មាត្រា ៥២៨.** – ការដោះលែងឱ្យមានសេរីភាពវិញ

ក្នុងករណីលុបចោលបញ្ញាឱ្យបង្ខិត និងឱ្យឃុំខ្លួននោះ ទណ្ឌិតត្រូវដោះលែងឱ្យមានសេរីភាពវិញ ។

**មាត្រា ៥២៩.** – លក្ខខណ្ឌដូចគ្នាទៅនឹងការដាក់ពន្ធនាគារ

ការបង្ខិតដល់រូបកាយមានលក្ខខណ្ឌដូចគ្នានឹងការជាប់ទោសពន្ធនាគារដែរ ។

**មាត្រា ៥៣០.** – ថិរវេលានៃការបង្ខិតដល់រូបកាយ

ថិរវេលានៃការបង្ខិតដល់រូបកាយត្រូវកំណត់ដូចតទៅ :

-១០ (ដប់) ថ្ងៃ កាលណាទឹកប្រាក់ដែលមិនបង់នោះមានចំនួនមិនលើសពី ២៥០,០០០ (ពីរសែនប្រាំម៉ឺន) រៀល ។

-២០ (ម្ភៃ) ថ្ងៃ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២៥០,០០១ (ពីរសែនប្រាំម៉ឺនមួយ) រៀល ដល់ ៥០០,០០០ (ប្រាំសែន) រៀល ។

-១ (មួយ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥០០,០០១ (ប្រាំសែនមួយ) រៀល ដល់ ១,០០០,០០០ (មួយលាន) រៀល ។

-២ (ពីរ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១,០០០,០០១ (មួយលានមួយ) រៀល ដល់ ២,៥០០,០០០ (ពីរលានប្រាំសែន) រៀល ។

-៣ (បី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២,៥០០,០០១ (ពីរលានប្រាំសែនមួយ) រៀល ដល់ ៥,០០០,០០០ (ប្រាំលាន) រៀល ។

-៦ (ប្រាំមួយ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥,០០០,០០១ (ប្រាំលានមួយ) រៀល ដល់ ១០,០០០,០០០ (ដប់លាន) រៀល ។

-១ (មួយ) ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១០,០០០,០០១ (ដប់លានមួយ) រៀល ដល់ ២០,៥០០,០០០ (ម្ភៃលានប្រាំសែន) រៀល។

-១៨ (ដប់ប្រាំបី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២០,៥០០,០០១ (ម្ភៃលានប្រាំសែនមួយ) រៀល ដល់ ៥០,០០០,០០០ (ហាសិបលាន) រៀល ។

-២ (ពីរ) ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនលើសពី ៥០,០០០,០០០ (ហាសិបលាន) រៀល ។

កាលណាការបង្ខិដល់រូបកាយធានាការប្រមូលឥណទេយ្យច្រើននោះ ថិរវេលានៃការបង្ខិនេះត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម ។

## មាត្រា ៥៣១. – ការរួចខ្លួនពីការបង្ខិដល់រូបកាយ

ការបង្ខិដល់រូបកាយ មិនអាចធ្វើទៅលើទណ្ឌិតជាអនីតិជននៅពេលប្រព្រឹត្តបទល្មើស ទៅលើស្ត្រីដែលមានអាយុចាប់ពី ៦៥ (ហុកសិបប្រាំ) ឆ្នាំ ឡើងទៅ និងទៅលើបុរសអាយុចាប់ពី ៧០ (ចិតសិប) ឆ្នាំ ឡើងទៅបានឡើយ ។

ការបង្ខិដល់រូបកាយមិនអាចធ្វើបានព្រមជាមួយគ្នាទៅលើប្តី និងប្រពន្ធបានទេ ទោះបីជាការបង្ខិនេះធ្វើឡើង ដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយ ។

## មាត្រា ៥៣២. – ភាពនៅតែមិនរួចពីបំណុលដដែល

ទណ្ឌិតដែលបានទទួលការបង្ខិរូបកាយរួចហើយនោះ នៅតែជំពាក់ចំនួនទឹកប្រាក់ដែលត្រូវបង់ដដែល ។ ប៉ុន្តែ ទណ្ឌិតនេះមិនត្រូវទទួលរងការបង្ខិរូបកាយចំពោះបំណុលដដែលនេះទៀតទេ ។

**មាត្រា ៩៣៣.** – ការបង្ខំដល់រូបកាយតាមពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

កាលណាដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលប្រាក់សំណង និងជម្ងឺចិត្តពីទណ្ឌិត ឬពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំដល់ព្រះរាជអាជ្ញាឱ្យធ្វើការបង្ខំដល់រូបកាយបាន ។

ការបង្ខំដល់រូបកាយដើម្បីទារសំណង និងជម្ងឺចិត្ត អាចអនុវត្តបានតែនៅលើទណ្ឌិតប៉ុណ្ណោះ ។

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវជូនភស្តុតាងថា ខ្លួនបានប្រើអស់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ ឬអចលនវត្ថុជាដើម ។ ព្រះរាជអាជ្ញាអាចហៅដើមបណ្តឹងរដ្ឋប្បវេណីឱ្យធ្វើនីតិវិធីថ្មី ដើម្បីសាកល្បងទារប្រាក់សំណង និងជម្ងឺចិត្តនេះ ។

ប្រសិនបើទណ្ឌិតមិនព្រមបង់ ការបង្ខំដល់រូបកាយត្រូវយកមកអនុវត្តនៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ៥២៣ (ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធី) ដល់មាត្រា ៥៣២ (ភាពនៅតែមិនរួចពីបំណុលដដែល) នៃក្រមនេះ ។ ក្នុងករណីមានការប្រជែងគ្នារវាងប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្ត នោះប្រាក់សំណង និងជម្ងឺចិត្ត ត្រូវមានអាទិភាពទទួលសងមុនគេ ។

## មាតិកាទី ៤
## ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ
## ជំពូកទី ១
## ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

**មាត្រា ៩៣៤.** – សាលាជម្រះក្តីដែលមានសមត្ថកិច្ចប្រកាសការផ្តល់ឱ្យមាននីតិសម្បទាឡើងវិញ

ការផ្តល់ឱ្យមាននីតិសម្បទាឡើងវិញតាមផ្លូវតុលាការ អាចត្រូវបានផ្តល់ឱ្យ ឬមិនព្រមផ្តល់ឱ្យដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានការប្រកាសផ្តន្ទាទោសដោយតុលាការនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍នេះ ។

**មាត្រា ៩៣៥.** – លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ

ពាក្យសុំឱ្យមាននីតិសម្បទាឡើងវិញ អាចនឹងដាក់ជូនសភាព្រហ្មទណ្ឌពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ :

-៥ (ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៣ (បី) ឆ្នាំ ចំពោះបទមជ្ឈិម

-១ (មួយ) ឆ្នាំ ចំពោះបទលហុ ។

រយៈពេលនេះចាប់ផ្តើមគិត :

-ពីការអនុវត្តទោសរួច

-ពីការអនុវត្តការបង្ខិតលំរូបកាយរួច នៅក្នុងករណីដែលមានចែងនៅក្នុងកថាខ័ណ្ឌទី២ មាត្រា ៥៣៦ (ការផ្តល់ភស្តុតាងចាំបាច់) នៃក្រមនេះ ។

**មាត្រា ៥៣៦.** – ការផ្តល់ភស្តុតាងចាំបាច់

ទណ្ឌិតត្រូវជូនភស្តុតាងដែលបញ្ជាក់ថា ខ្លួនបានបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្តរួចហើយ ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់ចោលមិនទារប្រាក់សំណង និងជម្ងឺចិត្តទេ ទណ្ឌិតត្រូវផ្តល់ការបញ្ជាក់អំពីការបោះបង់នេះ លើកលែងតែរកដើមបណ្តឹងរដ្ឋប្បវេណីមិនឃើញ ។

ប្រសិនបើទណ្ឌិតត្រូវបានបង្ខិតលំរូបកាយ ការមិនបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី ឬប្រាក់សំណង និងជម្ងឺចិត្ត មិនមែនជាឧបសគ្គដល់ការឱ្យមាននីតិសម្បទាឡើងវិញទេ ប្រសិនបើទណ្ឌិតជូនភស្តុតាងថា ខ្លួនស្ថិតក្នុងភាពអសាធនី ។

ប្រសិនបើអ្នកប្តឹងសុំត្រូវបានផ្តន្ទាទោសពីបទនិទ្ទនភាព សាមីខ្លួនត្រូវជូនភស្តុតាងដែលបញ្ជាក់ថាបានទូទាត់ប្រាក់បំណុលនៃការក្ស័យធនរួចហើយ ។ ប្រសិនបើម្ចាស់បំណុលបានបោះបង់ចោលមិនឱ្យទូទាត់ប្រាក់បំណុលនេះទេ ទណ្ឌិតត្រូវផ្តល់ការបញ្ជាក់ពីការបោះបង់នេះ ។

**មាត្រា ៥៣៧.** – ទម្រង់នៃពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ

ទណ្ឌិតធ្វើពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញជូនទៅព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដី ។ ទណ្ឌិតត្រូវចង្អុលបង្ហាញប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅតាំងពីពេលដែលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។

**មាត្រា ៥៣៨.** – ការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញាជូនអគ្គព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាចាត់ធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែង ដែលទណ្ឌិតធ្លាប់បានរស់នៅតាំងពីពេលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។

ព្រះរាជអាជ្ញាសុំឱ្យគេប្រគល់មកខ្លួននូវ :

-លិខិតចម្លងនៃសេចក្តីចម្រេចផ្តន្ទាទោស

-លិខិតជូនដំណឹងអំពីកាលបរិច្ឆេទនៃការអនុវត្តទោសរួចហើយ

-ព្រឹត្តិបត្រលេខ ១ នៃបញ្ជីថ្កោលទោស ។

ព្រះរាជអាជ្ញាបញ្ជូនសំណុំរឿង ដោយមានយោបល់ដែលមានសំអាងហេតុរបស់ខ្លួនភ្ជាប់ជាមួយទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

**មាត្រា ៥៣៩. – នីតិវិធីនៅចំពោះមុខសាលាឧទ្ធរណ៍**

អគ្គព្រះរាជអាជ្ញាប្តឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្តឹងសុំ និងដល់មេធាវី ។

តុលាការត្រូវសម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់ទណ្ឌិត មេធាវី និង អគ្គព្រះរាជអាជ្ញា ។

**មាត្រា ៥៤០. – ការបដិសេធពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ**

ក្នុងករណីដែលតុលាការបដិសេធពាក្យសុំ សាមីជនមិនអាចជូនពាក្យសុំថ្មីទៀត មុនផុតរយៈពេល ២ (ពីរ) ឆ្នាំ បានឡើយ ។

ប៉ុន្តែប្រសិនបើពាក្យសុំលើកទី ១ ត្រូវបានតុលាការបដិសេធមកពីមិនគោរពរយៈពេលដែលចែងនៅមាត្រា ៥៣៥ (លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ) នៃក្រមនេះ ពាក្យសុំថ្មីអាចធ្វើបានចាប់ពីផុតរយៈពេលនោះ ។

## ជំពូកទី ២
## ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

**មាត្រា ៥៤១. – ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់**

នីតិសម្បទាត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់នៅក្នុងករណីដូចតទៅ :

-នៅពេលផុតរយៈពេល ៥ (ប្រាំ) ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចហើយ ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ក្នុងករណីដែលបុគ្គលនោះ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារមិនលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ឬក៏ផ្តន្ទាទោសពិន័យ ។

-នៅពេលផុតរយៈពេល ១០ (ដប់) ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចហើយ ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ក្នុងករណីដែលបុគ្គលនោះ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ ។

## មាតិកាទី ៥
## បញ្ជីថ្កោលទោស
## ជំពូកតោល
## បញ្ជីថ្កោលទោស

**មាត្រា ៥៤២. – ការគ្រប់គ្រងសលាកបត្រផ្តន្ទាទោសនៃបញ្ជីថ្កោលទោស**

បញ្ជីថ្កោលទោសត្រូវបានកាន់កាប់ដោយអង្គភាពមួយនៃក្រសួងយុត្តិធម៌ ។

ចំពោះបុគ្គលដែលកើតនៅកម្ពុជា បញ្ជីថ្កោលទោសនេះ ទទួលសលាកបត្រដែលកត់ត្រា :

-គ្រប់ការផ្តន្ទាទោសចំពោះមុខ ការផ្តន្ទាទោសដែលទុកជាចំពោះមុខ និងការផ្តន្ទាទោសដោយកំបាំងមុខទាំងអស់ដែលត្រូវបានប្រកាសដោយតុលាការព្រហ្មទណ្ឌកម្ពុជា

-ការផ្តន្ទាទោសដែលត្រូវបានប្រកាសដោយតុលាការបរទេស ហើយដែលអនុវត្តតាមកិច្ចព្រមព្រៀងអន្តរជាតិ ត្រូវបានជូនដំណឹងមកដល់អាជ្ញាធរកម្ពុជា

-វិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដែលប្រទានដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សេចក្តីសម្រេចក្នុងរឿងដោះលែងដោយមានលក្ខខណ្ឌ

-សេចក្តីសម្រេចស្តីពីការបង្ខំដល់រូបកាយ

-សាលក្រម ឬសាលដីកាដែលប្រកាសការក្ស័យធន

-សេចក្តីសម្រេចឱ្យមានការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

-សេចក្តីសម្រេចបណ្តេញជនបរទេស ។

កាលណាទណ្ឌិតបានទទួលទោសពន្ធនាគារ ឬការបង្ខំដល់រូបកាយរួចរាល់ហើយ កាលបរិច្ឆេទនៃការអនុវត្តទោស ឬការបង្ខំដល់រូបកាយនេះ ត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីថ្កោលទោស ។

កាលណាទណ្ឌិតបានបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី កាលបរិច្ឆេទនៃការបង់ប្រាក់នេះត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីថ្កោលទោស ។

កាលណាការផ្តន្ទាទោសណាមួយត្រូវបានទទួលនីតិសម្បទាជាថ្មីដោយពេញលក្ខណៈច្បាប់នោះនិទ្ទេសនេះត្រូវចុះនៅក្នុងបញ្ជីថ្កោលទោស ។

ត្រូវដកចេញពីបញ្ជីថ្កោលទោស :

-ការផ្តន្ទាទោសដែលសម្រេចដោយកំបាំងមុខ កាលណាការផ្តន្ទាទោសនេះត្រូវទុកជាអសារបង់បន្ទាប់ពីមានបណ្តឹងទាស់

-ការផ្តន្ទាទោសដែលត្រូវបានលុបលាងដោយការលើកលែងទោសជាទូទៅ

-ការផ្តន្ទាទោសដែលកើតមកដោយការភន្តច្រឡំអត្តសញ្ញាណ

-ការផ្តន្ទាទោសដែលត្រូវបានចាត់ទុកជាអសារបង់ដោយនីតិវិធីនៃបណ្តឹងសើរើ ។

**មាត្រា ៩៨៣. – និទ្ទេសទាក់ទងនឹងអត្តសញ្ញាណ**

បញ្ជីថ្កោលទោសក៏ទទួលផងដែរនូវសលាកបត្រដែលទាក់ទងនឹង :

-បុគ្គលដែលកើតនៅឯបរទេស

-បុគ្គលដែលអត្តសញ្ញាណមិនអាចផ្ទៀងផ្ទាត់មើលបាន ឬដែលគួរឱ្យសង្ស័យ ។

នៅក្នុងករណីទីពីរនេះ ត្រូវចុះនិទ្ទេសពិសេសនៅក្នុងបញ្ជីថ្កោលទោសថា អត្តសញ្ញាណមិនអាចផ្ទៀងផ្ទាត់មើលបាន ឬអត្តសញ្ញាណគួរឱ្យសង្ស័យ ។

**មាត្រា ៩៨៤.** – ព័ត៌មាននៃបញ្ជីថ្កោលទោស

ក្រឡាបញ្ជីតុលាការ ត្រូវតែផ្ញើជូនអង្គភាពនៃបញ្ជីថ្កោលទោស ក្រោមការត្រួតពិនិត្យរបស់ប្រធានតុលាការ នូវសលាកបត្រចំពោះសេចក្តីសម្រេចនីមួយៗដែលត្រូវចុះក្នុងបញ្ជីថ្កោលទោស ។

ប្រធានពន្ធនាគារជូនដំណឹងដល់អង្គភាពបញ្ជីថ្កោលទោសអំពីកាលបរិច្ឆេទនៃការអនុវត្តទោស ឬការបង្ខិដល់រូបកាយរួចរាល់ហើយ ។

អង្គភាពរតនាគារជូនដំណឹងដល់អង្គភាពបញ្ជីថ្កោលទោសអំពីការបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី ។

អង្គភាពបញ្ជីថ្កោលទោសរ៉ាប់រងទទួលព័ត៌មាន អំពីវិធានការលើកលែងទោស និងបន្ធូរបន្ថយទោសដោយព្រះមហាក្សត្រ និងសេចក្តីសម្រេចបណ្តេញជនបរទេស ។

**មាត្រា ៩៨៥.** – ព័ត៌មាននៃបញ្ជីថ្កោលទោសទាក់ទងនឹងនីតិបុគ្គល

បញ្ជីថ្កោលទោសត្រូវទទួលចុះសលាកបត្រទាំងឡាយដែលបញ្ជាក់ពីការផ្តន្ទាទោសគ្រប់ប្រភេទដោយតុលាការព្រហ្មទណ្ឌចំពោះនីតិបុគ្គល ។

**មាត្រា ៩៨៦.** – ការចេញព្រឹត្តិបត្រ

អង្គភាពបញ្ជីថ្កោលទោសអាចចេញព្រឹត្តិបត្របញ្ជីថ្កោលទោស ។ ព្រឹត្តិបត្រគឺជាសំរង់នៃនិទ្ទេសទាំងអស់ ឬមួយផ្នែកដែលមានចុះនៅក្នុងបញ្ជីថ្កោលទោសចំពោះបុគ្គលណាមួយជាកំណត់ ។

**មាត្រា ៩៨៧.** – ព្រឹត្តិបត្រលេខ ១

ព្រឹត្តិបត្រលេខ ១ នៃបញ្ជីថ្កោលទោស រួមមាននិទ្ទេសទាំងអស់ដែលចុះនៅក្នុងបញ្ជីថ្កោលទោសបុគ្គលនីមួយៗ ។

ព្រឹត្តិបត្រលេខ ១ អាចចេញឱ្យដល់អាជ្ញាធរតុលាការតែប៉ុណ្ណោះ ។

**មាត្រា ៩៨៨.** – ព្រឹត្តិបត្រលេខ ២

ព្រឹត្តិបត្រលេខ ២ មាននិទ្ទេសទាំងអស់ដែលចុះនៅក្នុងព្រឹត្តិបត្រលេខ ១ លើកលែងតែ :

-ការផ្តន្ទាទោសដែលត្រូវបានលុបបំបាត់ដោយការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ ឬដោយពេញលក្ខណៈច្បាប់

-ការផ្តន្ទាទោសព្យួរដោយគ្មានការដកហូត

-សាលក្រម ឬសាលដីកាដែលប្រកាសការក្ស័យធនក្នុងករណីទទួលបាននីតិសម្បទាឡើងវិញ ។

ព្រឹត្តិបត្រលេខ ២ ត្រូវចេញឱ្យដល់ :

-អាជ្ញាធរតុលាការ

-អាជ្ញាធរយោធាដែលទទួលពាក្យសុំចូលបំរើក្នុងកងទ័ព

-ភ្នាក់ងារដែលកាន់បញ្ជីពាណិជ្ជកម្ម

ព្រឹត្តប័ត្រលេខ ២ នេះក៏អាចត្រូវចេញឱ្យដល់អភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋផងដែរ :

-កាលណាអភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋបានទទួលពាក្យសុំធ្វើការងាររដ្ឋ

-កាលណាអភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋបានទទួលពាក្យស្នើស្តីពីការងារសាធារណៈ ឬ អាបណសញ្ញាសាធារណៈ

-កាលណាអភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋបានទទួលពាក្យសុំបើកគ្រឹះស្ថានដែលត្រូវតែមានការអនុញ្ញាត

-នៅក្នុងក្របខ័ណ្ឌនៃនីតិវិធីខាងវិន័យ ។

**មាត្រា ៥៤៩.** – ព្រឹត្តិបត្រលេខ ៣

ព្រឹត្តិបត្រលេខ ៣ មានចុះតែការផ្តន្ទាទោសជាប់ពន្ធនាគារដោយគ្មានការព្យួរទោស ដែលប្រកាសទៅលើបុគ្គលណាមួយពីបទឧក្រិដ្ឋ ឬមជ្ឈិមប៉ុណ្ណោះ ។

ប៉ុន្តែ ការផ្តន្ទាទោសដែលបានទទួលនីតិសម្បទាឡើងវិញហើយ គ្មានចុះក្នុងព្រឹត្តិបត្រលេខ ៣ ទេ ។

ព្រឹត្តិបត្រលេខ ៣ ត្រូវចេញឱ្យដល់សាមីជនដែលពាក់ព័ន្ធ ។ ក្នុងករណីណាក៏ដោយ ព្រឹត្តិបត្រលេខ ៣ មិនត្រូវចេញឱ្យដល់តតិយជនទេ ។

**មាត្រា ៥៥០.** – ការប្រព្រឹត្តទៅនៃបញ្ជីថ្កោលទោស : ប្រកាស

ប្រកាសរបស់ក្រសួងយុត្តិធម៌ កំណត់វិធានការទាំងឡាយណាដែលចាំបាច់ សម្រាប់ការប្រព្រឹត្តទៅនៃអង្គភាពបញ្ជីថ្កោលទោស ។ ប្រកាសនេះកំណត់ជាអាទិ៍ នូវលក្ខខណ្ឌទាំងឡាយដែលសលាកបត្រត្រូវបានបង្កើតឡើង ត្រូវបានត្រួតពិនិត្យ និងត្រូវបានបញ្ជូនដោយក្រឡាបញ្ជី ព្រមទាំងលក្ខខណ្ឌទាំងឡាយនៃការបង្កើត ការត្រួតពិនិត្យ និងការចេញព្រឹត្តិបត្រ ។

**មាត្រា ៥៥១.** – ការកែតម្រូវបញ្ជីថ្កោលទោស

កាលណាបុគ្គលណាមួយត្រូវបានផ្តន្ទាទោសដោយមានការខុសអត្តសញ្ញាណ អយ្យការត្រូវតែសុំឱ្យធ្វើការកែតម្រូវបញ្ជីថ្កោលទោសភ្លាម ។

**មាត្រា ៥៥២.** – អានុភាពនៃការទទួលបាននីតិសម្បទាឡើងវិញ

ការឱ្យមាននីតិសម្បទាឡើងវិញ លុបលាងចោលទណ្ឌកម្មព្រហ្មទណ្ឌ ។ ប៉ុន្តែ ទោសនេះនៅតែមានចុះនៅក្នុងបញ្ជីថ្កោលទោសដដែល ដោយមានចុះនិទ្ទេសថា ត្រូវបាននីតិសម្បទាឡើងវិញ ។

## មាតិកាទី ៦
## ប្រាក់ប្រដាប់ក្តី
## ជំពូកតោល
## ប្រាក់ប្រដាប់ក្តី

**មាត្រា ៥៥៣.** – ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់រដ្ឋ ។

បញ្ជីនៃប្រាក់ប្រដាប់ក្តី តារាងតម្លៃនៃប្រាក់ប្រដាប់ក្តី និងវិធីទូទៅត្រូវកំណត់ដោយប្រកាស ។

**មាត្រា ៥៥៤.** – ប្រាក់ពន្ធនៃនីតិវិធី

ទណ្ឌិតម្នាក់ៗ ត្រូវបង់ពន្ធសរុបនៃនីតិវិធីជូនរដ្ឋ ។ ចំនួនប្រាក់ពន្ធនៃនីតិវិធីអាចប្រែប្រួលទៅតាមប្រភេទរឿងក្តី ។

ចំនួនប្រាក់ពន្ធនៃនីតិវិធីត្រូវកំណត់ដោយប្រកាស ។

# ឧបសម្ព័ន្ធ៣

# ព្រះរាជក្រឹត្យ

នស/រកត/១១១៩/១៦៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ៥៨ នាក់ ក្នុងឱកាសពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ឆ្នាំ២០១៩ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម៖

១-ទណ្ឌិតឈ្មោះ **អ៊ុយ សុភាព** ភេទប្រុស អាយុ ៦៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-១២-២០១៣ ពីបទ ស្ទូកប៉ាន់ និងពីបទ រំលោភលើសេចក្តីទុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងៗទៀត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ [illegible]ាចសាលដីកាលេខ ២៧៩ ចុះថ្ងៃទី ២៨-៨-២០១៧ របស់តុលាការកំពូល ។

ROYAUME DU CAMBODGE • LE CABINET DU PALAIS ROYAL

២-ទណ្ឌិតឈ្មោះ **យ៉េម រតនា** ហៅ ខ្ពុយ ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-១០-២០១៦ ពីបទ លួចមានស្ថានទម្ងន់ទោសដោយគាស់ទម្លុះទម្លាយ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៧ "ក្រVស" ចុះថ្ងៃទី ១១-៥-២០១៥ របស់សាលាឧទ្ធរណ៍ ។

៣-ទណ្ឌិតឈ្មោះ **លន ថេត** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៦-២០១៤ ពីបទ អំពើលួចមានស្ថានទម្ងន់ទោសដោយប្រព្រឹត្តអំពើហិង្សា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ៨៩ ចុះថ្ងៃទី ០២-០២-២០១៨ របស់តុលាការកំពូល ។

៤-ទណ្ឌិតឈ្មោះ **សន ចន្ធី** ហៅ យី ជ្រូក ភេទស្រី អាយុ ៥២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-០២-២០១៦ ពីបទ នាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩៦ "គ" ចុះថ្ងៃទី ១៣-១០-២០១៦ របស់សាលាដំបូងខេត្តតាកែវ ។

៥-ទណ្ឌិតឈ្មោះ **ណែម សេង** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-១០-២០១៦ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២៤ "ឆ" ចុះថ្ងៃទី ២២-៦-២០១៧ របស់សាលាដំបូងខេត្តតាកែវ ។

៦-ទណ្ឌិតឈ្មោះ **ផុន ធី** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-១២-២០១៦ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "ខ"/១៧ ចុះថ្ងៃទី ០៨-៨-២០១៧ របស់សាលាដំបូងខេត្តតាកែវ ។

៧-ទណ្ឌិតឈ្មោះ **សុខ ជុំ** ភេទប្រុស អាយុ ១៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-០១-២០១៨ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ០៥១ "ឆ" ចុះថ្ងៃទី ២៦-១០-២០១៨ របស់សាលាដំបូងខេត្តតាកែវ ។

៨-ទណ្ឌិតឈ្មោះ **គុំ ខួច** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៩-២០១៧ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨០ "ង" ចុះថ្ងៃទី ០១-១១-២០១៨ របស់សាលាដំបូងខេត្តតាកែវ ។

៩-ទណ្ឌិតឈ្មោះ **នឹម ឆួន** ហៅ វ៉ាន់ ភេទប្រុស អាយុ ៣៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៦-២០១៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ "ក" ចុះថ្ងៃទី ០៦-១១-២០១៥ របស់សាលាដំបូងខេត្តស្ទឹងត្រែង ។

១០-ទណ្ឌិតឈ្មោះ **ធឿន សុជា** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-៩-២០១៦ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ "ខ" ចុះថ្ងៃទី ០៦-៧-២០១៧ របស់សាលាដំបូងខេត្តព្រះវិហារ ។

១១-ទណ្ឌិតឈ្មោះ **ផាន់ សុផល** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៤-២០១៧ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧០ "ខ" ចុះថ្ងៃទី ០៦-៩-២០១៧ របស់សាលាដំបូងខេត្តកំពត ។

១២-ទណ្ឌិតឈ្មោះ **អ៊ុត ស្រីនាង** ភេទស្រី អាយុ ៣៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៤-២០១៦ ពីបទ ហិង្សាមានស្ថានទម្ងន់ទោសដោយសារមរណភាព នៃជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៩ "គ" ចុះថ្ងៃទី ០៦-៣-២០១៧ របស់សាលាដំបូងខេត្តកំពត ។

១៣-ទណ្ឌិតឈ្មោះ **ម៉ៅ រដ្ឋា** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-៩-២០១៦ ពីបទ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ "ឈ" ចុះថ្ងៃទី ០៨-៦-២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ។

១៤-ទណ្ឌិតឈ្មោះ **ទី រ៉ាន** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៤-៧-២០១៧ ពីបទ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣២ "គ" ចុះថ្ងៃទី ២១-១១-២០១៧ របស់សាលាដំបូងខេត្តកោះកុង ។

១៥-ទណ្ឌិតឈ្មោះ **ហាយ ឡៃន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី [illegible]-២០១៤ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ខ" ចុះថ្ងៃទី ២១-៤-២០១៥ របស់សាលាដំបូងខេត្តស្វាយរៀង ។

១៦-ទណ្ឌិតឈ្មោះ **ឡុង ឆី** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៦-២០១៧ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៦ "ខ" ចុះថ្ងៃទី ១០-១០-២០១៧ របស់សាលាដំបូងខេត្តកំពង់ចាម ។

១៧-ទណ្ឌិតឈ្មោះ **ឆិត្យ គុន** ភេទស្រី អាយុ ៥០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-០២-២០១៤ ពីបទ ឃាតកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ឃ" ចុះថ្ងៃទី ១៧-៣-២០១៥ របស់សាលាដំបូងខេត្តក្រចេះ ។

១៨-ទណ្ឌិតឈ្មោះ **ផូ ស៊ីណាត** ភេទស្រី អាយុ ៤៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-១១-២០១៧ ពីបទ អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ "គ" ចុះថ្ងៃទី ២០-៩-២០១៨ របស់សាលាដំបូងខេត្តក្រចេះ ។

១៩-ទណ្ឌិតឈ្មោះ **សាន រ៉ុន** ភេទប្រុស អាយុ ៤៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៧-២០១៦ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ "ខ" ចុះថ្ងៃទី ២២-៥-២០១៨ របស់សាលាដំបូងខេត្តក្រចេះ ។

២០-ទណ្ឌិតឈ្មោះ **កុយ ខែង** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-១១-២០១៧ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ "គ" ចុះថ្ងៃទី ២៤-៧-២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២១-ទណ្ឌិតឈ្មោះ **ឡុង ហុង** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៤-៧-២០១៧ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៦ "ង" ចុះថ្ងៃទី ៣០-១១-២០១៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២២-ទណ្ឌិតឈ្មោះ **អ៊ិន ប្រាក់** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៥-២០១៦ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ "ដ" ចុះថ្ងៃទី ១៥-៦-២០១៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

២៣-ទណ្ឌិតឈ្មោះ **ឃួយ វាចា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-១០-២០១៦ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ "ញ" ចុះថ្ងៃទី ០៦-៤-២០១៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

២៤-ទណ្ឌិតឈ្មោះ **ឡាន សារឿម** ហៅ ខឹល ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-៣-២០១៨ ពីបទ ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោស) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៦២ "ញ" ចុះថ្ងៃទី ២០-៩-២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២៥-ទណ្ឌិតឈ្មោះ **ខិន ស្រីនី** ភេទស្រី អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៣-១០-២០១៦ ពីបទ ក្លែងបន្លំឯកសារសាធារណៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៦ "ដ" ចុះថ្ងៃទី ២៨-៦-២០១៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២៦-ទណ្ឌិតឈ្មោះ **មួរ ស្រីហ៊ុយ** ភេទស្រី អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-០២-២០១៩ ពីបទ រំលោភលើទំនុកចិត្ត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៤៧ "ដ" ចុះថ្ងៃទី ១២-៧-២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២៧-ទណ្ឌិតឈ្មោះ **ទិច ឧុទ្ធី** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-៣-២០១៨ ពីបទ ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ២៨ "ខ" ចុះថ្ងៃទី ២៣-៨-២០១៨ របស់សាលាដំបូងខេត្តប៉ៃលិន ។

២៨-ទណ្ឌិតឈ្មោះ **នាង ស៊ីម** ហៅ ម៉ែអាប៉ាវ ភេទស្រី អាយុ ៤២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-៩-២០១៦ ពីបទ នាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ "ខ" ចុះថ្ងៃទី ២៤-៥-២០១៧ របស់សាលាដំបូងខេត្តរតនគិរី ។

២៩-ទណ្ឌិតឈ្មោះ **ស្បោង ឌី** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-៣-២០១៦ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ដោយសារមរណភាពនៃជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "ឃ" ចុះថ្ងៃទី ០៩-៥-២០១៧ របស់សាលាដំបូងខេត្តកំពង់ធំ ។

